បញ្ចាឧបសម្បទវិធី

បែបគណៈធម្មយុត្ត

វិធីរៀនដើម្បីបួស

ជាសាមណេរ ភិក្ខុ និងភិក្ខុនី

ភ្ជំពេញ

ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ

សម្រាប់ចែកជាធម្មទាន

ព.ស. ២៥៦០ គ.ស. ២០១៦

បញ្ចាឧបសម្បទវិធី

បែបគណៈធម្មយុត្ត

បព្វជ្ជាឧបសម្បទវិធី
ប៍បកណៈធម្មយុត្ត
នមត្ថុ រតនត្តយស្ស

វិធីរៀនដើម្បីបួសជាសាមណេរ

ធម៌ ៣០ ប្រការ[(១)]

បព្វជ្ជាបេក្ខ: កុលបុត្រអ្នកមានសទ្ធា ប្រាថ្នាចង់បព្វជ្ជាជាសាមណេរ គប្បីសិក្សាធម៌ ៣០ ប្រការនេះជាមុនសិន ។

ឯធម៌ ៣០ ប្រការនោះគឺ សិក្ខាបទ ១០, ទណ្ឌកម្ម ១០, នាសន: ១០ ។

ធម៌ដែលសាមណេរត្រូវសិក្សាហៅថា សិក្ខាបទ ។

សេចក្តីខុសដែលសាមណេរធ្វើឲ្យកន្ធង់ហើយ ភិក្ខុត្រូវធ្វើទោសមានឲ្យដង់ទឹកជាដើម ដើម្បីនឹង់ឲ្យរាង់ចាល ហៅថា ទណ្ឌកម្ម ។

[(១)]តាមច្បាប់ អក្ខរនិទ្ទេស សីលសិក្ខាបទសាមណេរ និងសាមណេរសិក្ខាថាធម៌ ៥០ប្រការគឺ សីល១០ សិក្ខាបទ១០ បារាជិក១០ នាសន:១០ វត្ថុ១០ ត្រូវជាធម៌ ៥០ប្រការ, រូមខ្លីថា សីលគឺសិក្ខាបទ, បារាជិក គឺនាសន:, វត្ថុគឺទណ្ឌកម្ម, ត្រូវជា ៣០ ដដែល ។

អង្គដែលជាហេតុ នឹងត្រូវឲ្យសាមណេរវិនាស គឺឲ្យសឹកចេញ ហៅថា នាសនៈ ។

សិក្ខាបទ១០ នោះគឺ[(១)]

*១) **ចាណាតិចាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះកន្ទ ។*

*២) **អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ។*

*៣) **អព្រហ្មចរិយា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ (គឺសេពមេថុន) ។*

*៤) **មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។*

*៥) **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** ចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្ដីប្រមាទ ព្រោះផឹកនូវទឹកស្រវឹង គឺសុរា និងមេរ៉ាយ ។*

*៦) **វិកាលភោជនា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវអាហារ ក្នុងកាលខុស ។*

(១)មានក្នុងបាលីវិនយបិដកមហាខន្ធកៈ ។

៧) នចូកីតវាជិតវិសូកាជស្សនា វេរមណី *ចេតនាជាហេតុវៀរចាកកិរិយារាំនិងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។*

៨) មាលាតន្ធវិលេបនជារណមណ្ឌានវិភូសនដ្ឋានា វេរម-ណី *ចេតនាជាហេតុវៀរចាក ហេតុជាទីតាំង គឺការទ្រទ្រង់ និងប្រដាប់តាក់តែងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។*

៩) ឧចូាសយនមហាសយនា វេរមណី *ចេតនាជាហេតុវៀរចាក ទីសេនាសន: ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសន: ដ៏ប្រសើរ ។*

១០) ជាតរូបរជតបដិក្គហណា វេរមណី *ចេតនាជាហេតុវៀរចាក កិរិយាទទួលកាន់យកនូវមាសនិងប្រាក់ និងរូបិយគ្រប់បែប ដែលគេសន្មតប្រើទិញដូរជួសមាសនិងប្រាក់ក្នុងប្រទេសនោះៗ ។*

សេចក្តីប្រព្រឹត្ត មិនឲ្យដាច់ធ្ទុះធ្ទាយ ក្នុងសិក្ខាបទទាំង ១០ នេះ គឺប្រព្រឹត្តធ្វើឲ្យបរិសុទ្ធផូរផង់ ហៅថា សីល ។ ទើបច្បាប់ដើមពោលថា សីលគឺសិក្ខាបទ ។

សិក្ខាបទ ១០ ចប់

ទណ្ឌកម្ម[(១)] ១០ នោះគឺ

១) វិកាលភោតី ហោតិ *សាមណេរ បរិភោគនូវភោជនាហារ ក្នុងកាលខុស ។*

២) ឆចូាដិវិសូកឧស្សិកោ ហោតិ *សាមណេររាំច្រៀងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។*

៣) មាលាដិធារណាដិកោ ហោតិ *សាមណេរទ្រទ្រង់នឹងប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយកម្រងផ្កា និងគ្រឿងលាបផ្សេងៗ ។*

៤) ឧចូាសយនាដិកោ ហោតិ *សាមណេរ ដេកអង្គុយលើទីសេនាសន: ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសន: ដ៏ប្រសើរ ។*

៥) ជាតរូបរជតបដិក្គហណាដិកោ ហោតិ *សាមណេរទទួលកាន់យក នូវមាសនិងប្រាក់និងរូបិយគ្រប់បែប ដែលគេសន្មតប្រើទិញដូរជួសមាសប្រាក់ ក្នុងប្រទេសនោះៗ ដោយខ្ជួនឯង ឬប្រើអ្នកដទៃឲ្យទទួលកាន់យក ហើយត្រេកអរ ចំពោះមាសប្រាក់រូបិយនោះ ។*

---

(១)ទណ្ឌកម្ម ៥ សិក្ខាបទខាងដើម អំពីទី ១ដល់ទី ៥ ពុំមានក្នុងបាលីវិនយបិដកមហាខន្ធក:ទេ, តែមាននៅក្នុងតតិយសាមន្តបាសាទិកា អដ្ឋកថាមហាវគ្គ, និងសារត្ថទីបនី.. វិមតិវិនោទនី ដីកាវិន័យ ។ ទណ្ឌកម្ម ៥ ខាងចុង អំពីទី៦ ដល់ ១០ ជាពុទ្ធានុញ្ញាត មានក្នុងបាលីវិនយបិដកមហាខន្ធក: ។ សូមលោកអ្នកសិក្សាពិនិត្យឲ្យបានល្អជាលំដាប់ឡើងទៅទៀតផង ។

៦) ភិក្ខូនំ អលាភាយ បរិសក្ក្ពតិ *សាមណេរព្យាយាម ដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ ។*

៧) ភិក្ខូនំ អនត្ថាយ បរិសក្ក្ពតិ *សាមណេរព្យាយាម ដើម្បីនឹងមិនឲ្យជាប្រយោជន៍ដល់ភិក្ខុទាំងឡាយ ។*

៨) ភិក្ខូនំ អនាវាសាយ បរិសក្ក្ពតិ *សាមណេរព្យាយាមដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបានលំនៅ ។*

៩) ភិក្ខុំ អក្ក្ពោសតិ បរិភាសតិ *សាមណេរ ជេរប្រទេច ភិក្ខុ ។*

១០) ភិក្ខូ ភិក្ខូហិ ភេទេតិ *សាមណេរញ្ជាំងភិក្ខុទាំងឡាយ ឲ្យបែកចាកភិក្ខុទាំងឡាយ ។*

ទណ្ឌកម្ម ១០ ចប់

នាសនៈ[(១)] ១០នោះគឺ

១) ចាណាតិចាតី ហោតិ *សាមណេរ ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្ទង (គឺសម្លាប់សត្វ) ។*

២) អទិន្នាទាយី ហោតិ *សាមណេរ កាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ។*

---

(១) មានក្នុងបាលីវិនយបិដកមហាខន្ធក: ។

៣) **អព្រហ្មចារី ហោតិ** *សាមណេរប្រព្រឹត្តនូវធម៌ មិនប្រសើរ (គឺសេពមេថុនធម្ម) ។*

៤) **មុសាវាទី ហោតិ** *សាមណេរពោលនូវពាក្យកុហក ។*

៥) **មជ្ជចាយី ហោតិ** *សាមណេរផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។*

៦) **ពុទ្ធស្ស អវណ្ណំ ភាសតិ** *សាមណេរពោលតិះដៀលព្រះពុទ្ធ ។*

៧) **ធម្មស្ស អវណ្ណំ ភាសតិ** *សាមណេរពោលតិះដៀលព្រះធម៌ ។*

៨) **សង្ឆស្ស អវណ្ណំ ភាសតិ** *សាមណេរពោលតិះដៀលព្រះសង្ឆ ។*

៩) **មិច្ឆាទិដ្ឋិកោ ហោតិ** *សាមណេរមានទិដ្ឋិខុស ។*

៧០) **ភិក្ខុនីទុស្សកោ ហោតិ** *សាមណេរ ទ្រុស្តនាងភិក្ខុនី ។ (ទី១០នេះ ត្រូវផ្ទាស់ថា* **ថេយ្យសំវាសកោ ហោតិ** *សាមណេរនៅដោយ គេទជាចោរ គឺក្លែងគេទលួចបួស ដោយខ្លួនឯង) ។*

នាសនៈ ១០ ចប់

ធម៌ ៣០ ប្រការសង្ខេបប៉ុណ្ណេះ

សេចក្តីអនុញ្ញាត(១)

អនុញ្ញាសិ ខោ សោ ភគវា សាមណេរានំ ទស-
សិក្ខាបទានិ តេសុ ច សាមណេរេហិ សិក្ខិតុំ "ចា-
ណាតិចាតា វេរមណី អទិន្នាទានា វេរមណី អព្រហ្ម-
ចរិយា វេរមណី មុសាវាទា វេរមណី សុរាមេរយមជ្ជ-
បមាទដ្ឋានា វេរមណី វិកាលភោជនា វេរមណី នច្ច-
គីតវាទិតវិសូកទស្សនា វេរមណី មាលាគន្ធវិលេបន-
ធារណមណ្ឌនវិភូសនដ្ឋានា វេរមណី ឧচ្চាសយនមហា-
សយនា វេរមណី ជាតរូបរជតបដិគ្គហណា វេរមណី"
អនុញ្ញាសិ ខោ សោ ភគវា សាមណេរានំ ឥមានិ
ទស សិក្ខាបទានិ ឥមេសុ ច សាមណេរេហិ សិក្ខិតុំ ។
អនុញ្ញាសិ ខោ សោ ភគវា ទសហង្គេហិ សមន្នាគតំ
សាមណេរំ ជានេតុំ ។ កតមេហិ ទសហិ? "ចា-
ណាតិចាតី ហោតិ អទិន្នាទាយី ហោតិ អព្រហ្មចារី
ហោតិ មុសាវាទី ហោតិ មជ្ជបាយី ហោតិ ពុទ្ធស្ស

---

(១)មានក្នុងបាលីវិនយបិដកមហាខន្ធក: ។ សេចក្តីអនុញ្ញាតនេះ ត្រូវសាមណេរ
សូត្រ រាល់ថ្ងៃ ក្នុងវេលាថ្វាយបង្គំព្រះពេលព្រឹកចប់ហើយ ដើម្បីធ្វើឲ្យស្ទាត់ជំនាញ
ក្នុងធម៌ទាំង ៣០ ប្រការ ខាងដើម ។ ច្បាប់ដើមសរសេរទុកខាងដើមផ្នែករឿង
ទាំងអស់ ។

អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឆស្ស អវណ្ណំ ភាសតិ មិច្ឆាទិដ្ឋិកោ ហោតិ វេយ្យាវ-ច្ចការោ ហោតិ" អនុញ្ញាសិ ខោ សោ ភគវា ឥមេហិ ឧបមាហេ្ហហិ សមណ្ឌ្ហកតំ សាមណេរំ ជានាបេតុំ ។ អនុញ្ញាសិ ខោ សោ ភគវា បញ្ចហេ្ហហិ សមណ្ឌ-ហតស្ស សាមណេរស្ស ឧណ្ហ្ហាភិកម្មំ ការាតុំ ។ ភតមេហិ បញ្ចហិ? ភិក្ខូ ន អលាភាយ បរិសក្ខ្ហតិ ភិក្ខូ ន អន-ត្ថាយ បរិសក្ខ្ហតិ ភិក្ខូ ន អនាវាសាយ បរិសក្ខ្ហតិ ភិក្ខូ ន អក្ខ្ហោសតិ បរិភាសតិ ភិក្ខូ ភិក្ខូហិ ភេទេតិ ។ អនុញ្ញាសិ ខោ សោ ភគវា ឥមេហិ បញ្ចហេ្ហហិ សមណ្ឌ្ហកតស្ស សាមណេរស្ស ឧណ្ហ្ហាភិកម្មំ ការាតុន្តិ[(១)] ។

អក្ខ្ហោ ទេន ជិនេ ការ ជ អ ស ជ ជ ជ ជ ជ
ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ជ ។

សេចក្តីអនុញ្ញាតបាលី ចប់

ឯសេចក្តីអនុញ្ញាតពុំបានប្រែទុកក្នុងទីនេះទេ ព្រោះអាចមាន សេចក្តីអធិប្បាយក្នុងផ្នែកធម៌ ៣០ ប្រការខាងដើមហើយ ។ ទីនេះនឹងប្រែតែបាលីខាងចុងបំផុត មួយគាថាប៉ុណ្ណោះ ។

---

(១)បាលីបន្ទាត់នេះ ធម្មបទដ្ឋកថា ខុទ្ទកនិកាយ ។

អក្កោធេន ជិនេ កោធំ *គប្បីផ្ទាញ់ចិត្តខឹងដោយចិត្តមិនខឹង,*
អសាធុំ សាធុនា ជិនេ *គប្បីផ្ទាញ់មនុស្សអាក្រក់ ដោយធ្វើល្អ,*
ជិនេ កទរិយំ ទានេន *គប្បីផ្ទាញ់មនុស្សកំណាញ់ ដោយឲ្យ,*
សច្ចេនាលិកវាទិនន្តិ *គប្បីផ្ទាញ់មនុស្សកូតករដោយទៀងត្រង់ ។*

ចប់

អង្គសីលគឺសិក្ខាបទ ១០

សេចក្ដីបរិសុទ្ធដែលកើតឡើង អំពីការរក្សាសិក្ខាបទទាំង ១០ ហៅថា "សីល" ទើបមានច្បាប់ចង់ទុកមកថា សិក្ខាបទទាំង ១០ នេះ ឯងជាតួអង្គសីល ទាំងចារឹកសេចក្ដីទុកមកថា "សាមណេរ" គប្បីរក្សាសីលឲ្យបរិសុទ្ធ សូម្បីជីវិតនឹងស្លាប់ក្ដី ក៏កុំបីលះបង់គ្រឿងប្រដាប់គឺសីលនេះឡើយ ។ ព្រោះថាបើ សាមណេរឯណា បួសបានមួយរយព្រះវស្សា ទាំងបានរៀនចេះចប់ ព្រះត្រៃបិដក តែពុំបានប្រព្រឹត្តតាមពុទ្ធោវាទ រក្សាសីលគឺ សិក្ខាបទ ទាំង១០ ឲ្យបរិសុទ្ធផូរផង់ហើយ **និរយំ សោ ឧបបជ្ជតិ** *" សាមណេរនោះធ្លាក់ទៅកើតក្នុងនរក ។*

ម្យ៉ាងទៀត បើមានជីវិតរស់នៅ តែជាមនុស្សទ្រុស្ដសីល ហើយបរិភោគបច្ច័យ ៤ ដែលទាយកឲ្យដោយសទ្ធា ថាបើនឹងស៊ីដុំដែក ដែលឆេះក្រហមនោះវិញ ប្រសើរជាង ។

ឯសីលគឺសិក្ខាបទទាំង ១០ នោះមានអង្គ ៣៨ ប្រការ ដូចមានសេចក្ដីតទៅនេះ ៖

បាណាមានអង្គ ៥

១) **ចាណោ**	*សត្វមានជីវិត*
២) **ចាណាសញ្ញី**	*ដឹងថាសត្វមានជីវិត*
៣) **វធកចិត្តំ**	*ចិត្តគិតនឹងសម្លាប់*

៤) ឧបក្លាមោ ព្យាយាមនឹងសម្ងាប់

៥) តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

អទិន្នាទានមានអង្គ ៥

១) បរបរិក្ខហិតំ ទ្រព្យមានម្ចាស់គេរក្សាទុក

២) បរបរិក្ខហិតសញ្ញី ដឹងថាទ្រព្យមានម្ចាស់គេរក្សាទុក

៣) ថេយ្យចិត្តំ ចិត្តគិតនឹងលួចយក

៤) ឧបក្លាមោ ព្យាយាមនឹងលួចយក

៥) តេន ហរណំ លួចយកបានដោយព្យាយាមនោះ ។

អព្រហ្មចរិយៈ មានអង្គ ៤

១) ភេឧនវត្ថុ វត្ថុជាទីទម្ងាយសីល គឺទ្វាមគ្គទាំង ៣០ ឯណានីមួយ ។

២) សេវនចិត្តំ ចិត្តគិតនឹងសេព

៣) តជ្ជោវាយាមោ ព្យាយាមនឹងសេព

៤) មក្ខេន មក្ខបដិចាឧនំ ញ៉ាំងមគ្គនឹងមគ្គឲ្យដល់គ្នា ។

មុសាវាទ មានអង្គ ៤

១) អតថំ វត្ថុ វត្ថុមិនពិតត្រង់

២) វិសំវាឧនចិត្តំ ចិត្តគិតនឹងនិយាយឲ្យខុស

៣) តជ្ជោវាយាមោ *ព្យាយាមនឹងនិយាយឲ្យខុស*

៤) បរស្ស តជត្តវិជានន៖ *អ្នកដទៃដឹងសេចក្តីក្នុងខណៈនោះ ។*

សុរាមានអង្គ ៤

៣) មជនីយំ វត្ថុ *វត្ថុជាទីតាំងនៃសេចក្តីស្រវឹង*

៤) ចាតុកម្យតា ចិត្តំ *ចិត្តគិតនឹងផឹក*

៣) តជ្ជោវាយាមោ *ព្យាយាមនឹងផឹក*

៤) បិវតិ បវីសន៖ *ផឹកចូលទៅក្នុងបំពង់ក ។*

វិកាលភោជន៖ មានអង្គ ៤

៣) វិកាលោ *ថ្ងៃរសៀល*

៤) យាវកាលិកំ *របស់គួរបរិភោគក្នុងកាល*

៣) តជ្ជោវាយាមោ *ព្យាយាមនឹងបរិភោគ*

៤) អជ្ឈោហរណំ *បរិភោគចូលទៅក្នុងបំពង់ក ។*

នច្ចគីមានអង្គ ៣

៣) នច្ចាទិ *ច្រៀងរាំជាដើម*

៤) តប្បុរេក្ខារតា *នឹងចង់ច្រៀងរាំ*

៣) ជស្ស្នាទិ *ទៅមើលទៅស្តាប់ជាដើម ។*

មាលាមានអង្គ ៣

១) មាលាឌិ *គ្រឿងប្រដាប់មានផ្កាជាដើម*

២) តម្ឃុរេក្ខារតា *នឹងចង់តែងប្រដាប់*

៣) ធារណាឌិ *តែងប្រដាប់ជាដើម ។*

ឧច្ចាសយនៈមានអង្គ ៣

១) អកប្ឃិយសណ្ឋារតា *ទ្រទ្រង់គ្រឿងកម្រាលមិនគួរ*

២) អតីតម្ឃមាណកំ *កន្ធងប្រមាណ*

៣) សយនាសនំ *ដេកអង្គុយ ។*

ជាតរូបរជតៈ មានអង្គ ៣

១) ជាតរូបរជតំ *មាសប្រាក់ (និងរូបិយគ្រប់បែប)*

២) អត្តឧទ្ទិសតា *ចំពោះជារបស់ខ្លួន*

៣) តហណំ *ទទួលទុកដាក់នឹងខ្លួនឯង ឬប្រើគេឲ្យ*

ទុកដាក់ ហើយត្រេកអរ ។

អង្គសីលគឺសិក្ខាបទទាំង ១០ នេះ លុះតែប្រព្រឹត្តព្រមដោយអង្គ ទើបឈ្មោះថា ប្រព្រឹត្តកន្ធង ។

អង្គសីលគឺសិក្ខាបទ ១០ ចប់

កិច្ចវត្តរបស់សាមណេរ

សាមណេរត្រូវធ្វើកិច្ចវត្ត ដូចពណ៌នាតទៅនេះ ៖

ក) ត្រូវប្រតិបត្តិគ្រូ គឺត្រូវរៀបចំឲ្យមានទឹកក្តៅទឹកត្រជាក់ សម្រាប់ធាន់ សម្រាប់ប្រើប្រាស់ និងបោកគក់លាងសង្ឆាដី ចីពរ ស្បង់ ព្រមទាំងបរិក្ខារផ្សេងៗ ។

ខ) ត្រូវបោសសម្អាតទីកន្លែងគ្រូ គឺរៀបចំគ្រែ តាំង ទីសំណឹង បោសសម្អាតកុដិ ទាំងទីបរិវេណកុដិ, សម្អាតវច្ចកុដិ (បង្គន់) អគ្យាគារដ្ឋាន (ពោងភ្លើង ពោងធាន់ ពោងបោកគក់ជ្រលក់បរិក្ខារ) និងទីលានព្រះចេតិយ ព្រះវិហារ ព្រះពោធិព្រឹក្សជាដើម ។

គ) ត្រូវទទួលដំណើរលោកអ្នកមកថ្មី (អាគន្ដុក:) ជូនដំណើរលោកអ្នកមានដំណើរចេញទៅ (គមិក:) និងឧស្សាហ៍ចូលទៅបម្រើលោកអ្នកមានជំងឺ...។

ឃ)បើត្រូវការឲ្យរបស់អ្វីទៅអ្នកណាមួយក្ដី, ចូលទៅស្រុក ទៅភូមិ ទៅព្រៃក្ដី, ការសក់ពុកមាត់ជាដើមក្ដី, បើកបិទទ្វារបង្ហួច អុចប្រទីប លត់ប្រទីបជាដើមក្ដី សូត្ររៀនទន្ទេញបាលីអដ្ឋកថា បទណាមួយក្ដី គប្បីប្ដឹងគ្រូជាមុន ។

កិច្ចវត្តរបស់សាមណេរ ចប់

ប្រយោគក្នុងសិក្ខាបទ ១០

ប្រយោគសម្រាប់ប្រើក្នុងសិក្ខាបទទាំង១០ នោះ មាន២គឺ៖

១) សាហត្ថិកបយោគ ធ្វើខ្លួនឯង ។

២) អាណត្ថិកបយោគ ប្រើអ្នកដទៃឲ្យធ្វើ ។

ក្នុងសិក្ខាបទទី ១ គឺបាណាតិបាត ទី ២ អទិន្នាទាន ទី ១០ ជាតរូប ទាំង៣សិក្ខាបទនេះ ជាអាណត្ថិកប្រយោគ ព្រោះធ្វើខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី ឈ្មោះថាប្រព្រឹត្តកន្ទងដូចគ្នា ។

សិក្ខាបទ ៧ ទៀត តាំងពីសិក្ខាបទទី ៣ គឺអព្រហ្មចរិយ: រហូតដល់សិក្ខាបទទី ៩ គឺឧច្ចាសយនមហា, ទាំង ៧ សិក្ខាបទនេះ ជាសាហត្ថិកប្រយោគ ធ្វើខ្លួនឯងទើបឈ្មោះថាប្រព្រឹត្តកន្ទង ។

ម្យ៉ាងទៀតសិក្ខាបទទាំង ១០ នោះលោកចែកចេញជា ២ ពួកគឺ ៖

សាណត្ថិកបយោគ ១ពួក ។

អនាណត្ថិកបយោគ ១ពួក ។

សិក្ខាបទឯណាដែលជាអាណត្ថិកបយោគ, សិក្ខាបទនោះ ជាសាណត្ថិក: ព្រោះអ្នករក្សាធ្វើខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី ឈ្មោះថាកន្ទងដូចគ្នា ។

សិក្ខាបទឯណាជាសាហត្ថិកបយោគ, សិក្ខាបទនោះជា អនា-ណត្តិក: ព្រោះអ្នករក្សាធ្វើដោយខ្លួនឯង ទើបឈ្មោះថា កន្ទ ១ បើប្រើអ្នកដទៃឲ្យធ្វើ មិនឈ្មោះថាកន្ទ ១ ទេ ។

ប្រយោគក្នុងសិក្ខាបទ ១0 ចប់

បច្ចយសន្និស្សិតសីល(១)

សីលដែលអាស្រ័យនូវបច្ច័យ ហៅថា **បច្ចយសន្និស្សិតសីល** *វត្ថុដែលមនុស្សសត្ត្ব ត្រូវអាស្រ័យបរិភោគប្រើប្រាស់ ហើយទើបរស់នៅបាន ហៅថា "បច្ច័យ" ។ នោះមាន៤យ៉ាងគឺ ៖*

*១) **ចីវរ** គ្រឿងសម្រាប់ស្មៀកដណ្តប់បិទបាំងអត្តភាព*

*២) **បិណ្ឌាចាត** គ្រឿងសម្រាប់បរិភោគចិញ្ចឹមអត្តភាព*

*៣) **សេនាសនៈ** ទីដេកទីអង្គុយសម្រាប់ជ្រកកោនអត្តភាព*

*៤) **គិលានភេសជ្ជៈ** ថ្នាំកែជំងឺសម្រាប់ជំនួយអត្តភាព ។*

ឯបច្ច័យសន្និស្សិតសីលនេះ នឹងបរិសុទ្ធផូរផង់ល្អបានដោយអាស្រ័យការពិចារណាបច្ច័យ ដែលហៅថា "វិធីបច្ចវេក្ខណៈ" ។

វិធីបច្ចវេក្ខណៈ

របៀបពិចារណាបច្ច័យ

ភិក្ខុសាមណេរ អ្នកបរិភោគប្រើប្រាស់បច្ច័យទាំង ៤ ខាងលើនេះ ត្រូវកំណត់ដឹងថា ៖

ក្នុងបច្ច័យមួយៗ មានវិធីបច្ចវេក្ខណៈបួនៗ គឺចីវរបច្ច័យ ៤ បិណ្ឌ-បាតបច្ច័យ ៤ សេនាសនបច្ច័យ ៤ គិលានបច្ច័យ ៤ សឹងមានឈ្មោះថា ធាតុបច្ចវេក្ខណៈ, បដិកូលបច្ចវេក្ខណៈ, តង្ខណិកបច្ចវេក្ខណៈ,

(១)ស្រង់តែគោលខ្លីៗ ពីគម្ពីរវិសុទ្ធិមគ្គសីលនិទ្ទេស មករៀបរៀង ។

អតីតបច្ចវេក្ខណៈ, ដូចគ្នាគ្រប់បច្ច័យទាំង ៤ រួមទាំងអស់ត្រូវជាវិធីបច្ចវេក្ខណៈ ១៦ ។

ក្នុងបច្ច័យមួយៗ មានកាលដែលត្រូវពិចារណាបីៗគឺ៖ កាលដែលកំពុងបានឬកំពុងទទួលនូវបច្ច័យ ហៅថា បដិលាភកាល១, កាលដែលកំពុងបរិភោគប្រើប្រាស់នូវបច្ច័យ ហៅថា បរិភោគកាល១, កាលដែលបរិភោគប្រើប្រាស់កន្លង ទៅហើយ ហៅថា អតីតកាល១, ដូចគ្នាគ្រប់បច្ច័យទាំង៤ រួមទាំងអស់ត្រូវជាកាល ១២ ។ បដិលាភកាល ត្រូវពិចារណា ដោយធាតុបច្ចវេក្ខណៈក៏បាន ដោយបដិកូលបច្ចវេក្ខណៈក៏បាន ។ បរិភោគកាលត្រូវពិចារណាដោយតង្ខណិកបច្ចវេក្ខណៈ ។ អតីតកាល ត្រូវពិចារណាដោយអតីតបច្ចវេក្ខណៈ ។

ទី១)- ធាតុបច្ចវេក្ខណៈ

ការពិចារណាបច្ច័យទាំង ៤ ណាមួយឲ្យឃើញថាជាធាតុ ហៅថា ធាតុបច្ចវេក្ខណៈ ។

១) ក្នុងវេលាទទួលចីវរបច្ច័យ ត្រូវពិចារណាដោយ ធាតុបច្ចវេក្ខណៈថា ៖

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

ចីវរនេះគ្រាន់តែជាធាតុប៉ុណ្ណោះ ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ សូម្បីបុគ្គលគឺអាត្មាជាអ្នកប្រើប្រាស់ចីវរនោះក្តី ក៏គ្រាន់តែជាធាតុប៉ុណ្ណោះ មិនមែនជាសត្វ មិនមែនខ្ជួនប្រាណ មានសភាពសោះសូន្យទទេ ។

២) ក្នុងវេលាទទួលបិណ្ឌបាតបច្ច័យ ត្រូវពិចារណាដោយ ធាតុ-បច្ចវេក្ខណៈថា៖

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ បិណ្ឌាចារោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

អាហារបិណ្ឌបាតនេះគ្រាន់តែជាធាតុប៉ុណ្ណោះ ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ សូម្បីបុគ្គលគឺអាត្មាជាអ្នកបរិភោគអាហារបិណ្ឌបាតនោះក្តី ក៏គ្រាន់តែ ជាធាតុប៉ុណ្ណោះ មិនមែនជាសត្វ មិនមែនខ្ជួនប្រាណ មានសភាព សោះសូន្យទទេ ។

៣) ក្នុងវេលាទទួលសេនាសនបច្ច័យ ត្រូវពិចារណាដោយ ធាតុបច្ចវេក្ខណៈថា៖

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

ទីសេនាសនៈឯណានេះ ទីសេនាសនៈនោះគ្រាន់តែជាធាតុប៉ុណ្ណោះ ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ សូម្បីបុគ្គលគឺអាត្មាជាអ្នកប្រើប្រាស់សេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្ត្ব មិនមែនខ្ជួនប្រាណ មានសភាពសោះសូន្យទទេ ។

៤) ក្នុងវេលាទទួលគិលានភេសជ្ជបច្ច័យ ត្រូវពិចារណាដោយធាតុបច្ចវេក្ខណៈថា៖

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានបច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជកো ច បុគ្គលো ធាតុមត្តកো និស្សត្តো និជ្ជីវো សុញ្ញো ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនេះគ្រាន់តែជាធាតុប៉ុណ្ណោះ ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ សូម្បីបុគ្គលគឺអាត្មា ជាអ្នកបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុប៉ុណ្ណោះ មិនមែនសត្ត្ব មិនមែនខ្ជួនប្រាណ មានសភាពសោះសូន្យទទេ ។

ធាតុបច្ចវេក្ខណៈ ចប់

ទី ២- បដិកូលបច្ចវេក្ខណៈ

ការពិចារណាបច្ច័យទាំង ៤ ណាមួយ ឲ្យឃើញថាជារបស់បដិកូលគួរខ្ពើមរអើម ហៅថាបដិកូលបច្ចវេក្ខណៈ ។

๑) ក្នុងវេលាប្រារព្ធនឹងប្រើប្រាស់នូវចីវរបច្ច័យ ត្រូវពិចារណាដោយបដិកូលបច្ចវេក្ខណៈថា ៖

សញ្ចានិ បន ឥមានិ ចីវានិ អជិកុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិកុច្ឆនីយានិ ជាយន្តិ ។

ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ (ប៉ុន្តែ) លុះប៉ះពាល់ដល់កាយស្អុយនេះហើយ ក៏កើតទៅជារបស់គួរខ្ពើមរអើមយ៉ាងក្រៃលែង ។

๒)- ក្នុងវេលាប្រារព្ធនឹងបរិភោគនូវបិណ្ឌបាតបច្ច័យ ត្រូវពិចារណាដោយបដិកូលបច្ចវេក្ខណៈថា ៖

សញ្ចោ បនាយំ បិណ្ឌចាតោ អជិកុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិកុច្ឆនីយោ ជាយតិ ។

អាហារបិណ្ឌបាតទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ (ប៉ុន្តែ) លុះប៉ះពាល់ដល់កាយស្អុយនេះហើយ ក៏កើតទៅជារបស់គួរខ្ពើមរអើមយ៉ាងក្រៃលែង ។

๓)- ក្នុងវេលាប្រារព្ធនឹងប្រើប្រាស់នូវសេនាសនបច្ច័យ ត្រូវពិចារណាដោយបដិកូលបច្ចវេក្ខណៈថា ៖

សញ្ចានិ បន ឥមានិ សេនាសនានិ អជិកុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិកុច្ឆនីយានិ ជាយន្តិ ។

ទីសេនាសនៈទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ (ប៉ុន្តែ) លុះប៉ះពាល់ដល់កាយស្អុយនេះហើយ ក៏កើតទៅជារបស់គួរខ្ពើមរអើមយ៉ាងក្រៃលែង ។

៤) ក្នុងវេលាប្រារព្ធនឹងបរិភោគនូវគិលានបច្ច័យ ត្រូវពិចារណាដោយបដិកូលបច្ចវេក្ខណៈថា ៖

សញ្ញោ បនាយំ កិលានបច្ចយភេសជ្ជបរិក្ខារោ អជិគុច្ឆនីយោ ឥមំ ឫតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើម ឡើយ (ប៉ុន្តែ) លុះប៉ះពាល់ដល់កាយស្អុយនេះហើយ ក៏កើតទៅជារបស់ គួរខ្ពើមរអើមយ៉ាងក្រៃលែង ។

បដិកូលបច្ចវេក្ខណៈចប់

ទី ៣-ធាតុណិកបច្ចវេក្ខណៈ

ការពិចារណាបច្ច័យទាំង ៤ ណាមួយក្នុងខណៈដែលបរិភោគប្រើប្រាស់ ហៅថា ធាតុណិកបច្ចវេក្ខណៈ ។

១)- ក្នុងវេលាប្រើប្រាស់នូវចីវរបច្ច័យ ត្រូវពិចារណាដោយធាតុណិកបច្ចវេក្ខណៈថា ៖

បដិសង្ខា យោនិសោ ចីវរំ បដិសេវামি យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនបដិច្ឆាទនត្ថំ ។

(ភិក្ខុសាមណេរ) គប្បីពិចារណាដោយឧបាយថា អាត្មាស្មៀកដណ្តប់នូវចីវរកំណត់គ្រាន់តែ ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្សនៃរបោម, មូស, ខ្យល់, កម្តៅថ្ងៃ និងពស់តូច, ពស់ធំទាំងឡាយ កំណត់ត្រឹមតែដើម្បីនឹងបិទបាំងនូវអវយវៈដែលធ្វើនូវសេចក្តីអៀនខ្មាសឲ្យកម្រើក ។

២) ក្នុងវេលាបរិភោគនូវបិណ្ឌបាតបច្ច័យ ត្រូវពិចារណាដោយតង្ខណិកបច្ចវេក្ខណៈថា ៖

បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវামি នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិបុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្ផាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

(ភិក្ខុសាមណេរ) គប្បីពិចារណាដោយឧបាយថា អាត្មាបរិភោគនូវអាហារបិណ្ឌបាត ដើម្បីនឹងលេងក៏ទេ ដើម្បីនឹងឲ្យកើតសេចក្តីស្រវឹងក៏ទេ ដើម្បីនឹងតាក់តែងរាងកាយក៏ទេ ដើម្បីនឹងធ្វើពណ៌សម្បុរឲ្យផ្ទរផង់ក៏ទេ បរិភោគកំណត់គ្រាន់តែ ដើម្បីនឹង តម្កល់កាយនេះទុក ដើម្បីនឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ អាត្មានឹងកម្ចាត់បង់នូវវេទនាចាស់ផង នឹងមិនឲ្យវេទនាថ្មីកើតឡើងបានផង ការប្រព្រឹត្តទៅនៃតរិយាបថទាំង ៤ ក្តី ការមិនមានទោសក្តី ការនៅជាសុខសប្បាយក្តី នឹងមានដល់អាត្មា ដោយបានបរិភោគនូវ អាហារ បិណ្ឌបាតនេះ ។

៣) ក្នុងវេលាប្រើប្រាស់នូវសេនាសនបច្ច័យ ត្រូវពិចារណាដោយតង្ហណិកបច្ចវេក្ខណៈថា ៖

បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។

(ភិក្ខុសាមណេរ) គប្បីពិចារណាដោយឧបាយថា អាត្មាប្រើប្រាស់នូវទីសេនាសនៈកំណត់គ្រាន់តែ ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីការពារនូវសម្ផស្សនៃរបោម, មូស, ខ្យល់,កម្តៅថ្ងៃ

និងពស់តូចពស់ធំទាំងឡាយ កំណត់គ្រាន់តែដើម្បីនឹង បន្ទោបង់នូវ ក្រវល់ក្រវាយដែលកើតអំពីរដូវ ហើយត្រេកអរ ពួននៅក្នុងកម្មដ្ឋាន ។

៤) ក្នុងវេលាបរិភោគនូវគិលានបច្ច័យ ត្រូវពិចារណាដោយ តង្ខណិកបច្ចវេក្ខណៈថា ៖

បដិសង្ខា យោនិសោ កិលានបច្ចយភេសជ្ជបរិក្ខារំ បដិសេវាមិ យាវទេវ ឧប្ផន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឌបរមតាយាតិ ។

(ភិក្ខុសាមណេរ) គប្បីពិចារណាដោយឧបាយថា អាត្មាបរិភោគ នូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ គ្រាន់តែ ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ កើតឡើងហើយ ដើម្បីប្រាសចាកទុក្ខយ៉ាងធ្ងន់ ។

តង្ខណិកបច្ចវេក្ខណៈ ចប់

ទី៤- អតីតបច្ចវេក្ខណៈ

ការពិចារណានូវបច្ច័យទាំង ៤ ណាមួយ ក្នុងកាលដែលបរិភោគ រួចហើយ ហៅថា អតីតបច្ចវេក្ខណៈ។ នោះ ត្រូវពិចារណា បានតែក្នុង ថ្ងៃនោះ គឺក្នុង ១ យប់ ១ ថ្ងៃ កុំទុកឲ្យព្រះអាទិត្យរះទាន់ ឡើយ ។

១)- វេលាពិចារណានូវចីវរបច្ច័យ ត្រូវពិចារណាដោយ អតីត-បច្ចវេក្ខណៈថា ៖

អជ្ជ មយា អបច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនបដិច្ឆាទនត្ថំ ។

ចីវរឯណាដែលអាត្មាមិនបានពិចារណា ស្លៀកដណ្តប់រួចហើយ ក្នុងថ្ងៃនេះ ចីវរនោះអាត្មាស្លៀកដណ្តប់ កំណត់គ្រាន់តែ ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្ស នៃរបោម, មូស, ខ្យល់, កម្តៅថ្ងៃ និងពស់តូច, ពស់ធំទាំងឡាយ កំណត់គ្រាន់តែដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីអៀនខ្មាសឲ្យកម្រើក ។

២)- ក្នុងវេលាពិចារណានូវបិណ្ឌបាតបច្ច័យ ត្រូវពិចារណា ដោយ អតីតបច្ចវេក្ខណៈថា ៖

អជ្ជ មយា អបច្ចវេក្ខិត្វា យោ បិណ្ឌាចាតោ បរិភុត្តោ សោ នេវឌាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិបុរាណញ្ច វេទនំ បដិហង្ខាមិ

ជរញ្ជ វេឌនំ ន ឧប្ផាឌេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

អាហារបិណ្ឌបាតឯណាដែលអាត្មា មិនបានពិចារណា បរិភោគ រួចហើយក្នុងថ្ងៃនេះ អាហារបិណ្ឌបាតនោះ អាត្មាបរិភោគ ដើម្បីនឹងលេងក៏ទេ ដើម្បីនឹងឲ្យកើតសេចក្ដីស្រវឹងក៏ទេ ដើម្បីនឹងតាក់តែងរាងកាយក៏ទេ ដើម្បីនឹងធ្វើពណ៌សម្បុរឲ្យផូរផង់ក៏ទេ បរិភោគ កំណត់គ្រាន់តែដើម្បីនឹងតម្កល់កាយនេះទុក ដើម្បីនឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្ដីលំបាក ដើម្បីនឹងអនុគ្រោះ ដល់ព្រហ្មចារ្យ អាត្មានឹងកម្ចាត់បង់នូវវេទនាចាស់ផង និងមិនឲ្យវេទនាថ្មីកើតឡើងបានផង ការប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្ដី ការមិនមានទោសក្ដី ការនៅជាសុខសប្បាយក្ដី នឹងមានដល់អាត្មា ដោយបានបរិភោគនូវអាហារបិណ្ឌបាតនេះ ។

៣)- ក្នុងវេលាពិចារណានូវសេនាសនៈបច្ច័យ ត្រូវពិចារណាដោយអតីតបច្ចវេក្ខណៈថា ៖

អជ្ជ មយា អបច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។

ទីសេនាសនៈឯណា ដែលអាត្មាមិនបានពិចារណា ប្រើប្រាស់រួច ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អាត្មាប្រើប្រាស់ កំណត់គ្រាន់តែ ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារ នូវសម្ផស្សនៃរបោម, មូស, ខ្យល់, កម្តៅថ្ងៃ និងពស់តូច, ពស់ធំទាំងឡាយ កំណត់គ្រាន់តែ ដើម្បីនឹង បន្ទោរបង់នូវក្រវល់-ក្រវាយ ដែលកើតអំពីរដូវ ហើយត្រេកអរ ពួននៅក្នុងកម្មដ្ឋាន ។

២) ក្នុងវេលាពិចារណានូវគិលានបច្ច័យ ត្រូវពិចារណាដោយ អតីតបច្ចវេក្ខណៈថា ៖

អជ្ជ មយា អបច្ចវេក្ខិត្វា យោ កិលានបច្ចយភេសជ្ជ-បរិក្ខារោ បរិភុត្តោ សោ យាវទេវ ឧប្ផន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ជបរមតាយាតិ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណា ដែលអាត្មាមិនបានពិចារណា បរិភោគរួចហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារ ជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អាត្មាបរិភោគកំណត់ គ្រាន់តែ ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ កើតឡើងហើយ ដើម្បីប្រាសចាកទុក្ខ យ៉ាងខ្លាំងប៉ុណ្ណោះ ។

វិធីបច្ចវេក្ខណៈ ចប់

បច្ចយសន្និស្សិតសីល សង្ខេបប៉ុណ្ណោះ

បព្វជ្ជាវិធី

កុលបុត្រអ្នកមានសទ្ធាជ្រះថ្លា ប្រាថ្នាបព្វជ្ជាឧបសម្បទ ក្នុងព្រះ-ពុទ្ធសាសនា គប្បីធ្វើខ្ជួនឲ្យស្អាតបរិសុទ្ធផុតអំពីឧបស័គ្គ (ការជាប់-ជំពាក់) ផ្សេងៗ ដែលព្រះវិន័យត្រូវហាម និងគប្បីធ្វើ ខ្ជួនឲ្យផុតអំពីបលិពោធ (កិច្ចកង្វល់)ផ្សេងៗ មានគ្រប់គ្រងគ្រួសារ ធ្វើអាជីវកម្ម ផ្ទះសម្បែង ទ្រព្យសម្បត្តិជាដើម, គឺធ្វើខ្ជួនឲ្យមាន ឱកាសល្អ គួរទទួលនូវបព្វជិតភេទបានដោយស្រួល និងត្រូវសិក្សា សិក្ខាវិន័យ សម្រាប់បព្វជិត ឲ្យចេះចាំស្ទាត់ជាមុន និងមានគ្រឿង បរិក្ខារឲ្យគ្រប់គ្រាន់ ។

កាលដល់ថ្ងៃកំណត់ហើយ គប្បីកាន់យកនូវត្រៃចីវរបរិក្ខារ ផ្កាឈើ ទៀនធូបជាដើម ទៅកាន់អារាមតាមទំនៀម បើពុំទាន់ការសក់ពុកមាត់ទេ គប្បីចូលទៅរកព្រះឧបជ្ឈាយ៍ប្រាប់សូមភណ្ឌុកម្ម កាលសម្រេចកិច្ចការកេសាហើយ គប្បីចូលទៅកាន់ព្រះវិហារធ្វើសក្ការបូជាថ្វាយបង្គំព្រះរតនត្រៃដោយសេចក្តីសង្ខេប ឬ ពិស្តារ តាមសមគួរដល់ពេលវេលា ។ កាលព្រះសង្ឆប្រជុំព្រមហើយ បព្វជ្ជាបេក្ខ: ឬឧប-សម្បទាបេក្ខ:នោះ ត្រូវបីត្រៃចីវរចូលទៅកាន់ ទីជំនុំសង្ឆ ហើយដាក់ត្រៃចីវរចុះខាងធ្វេងដៃ ទទួលគ្រឿងសក្ការ: ប្រគេនព្រះឧបជ្ឈាយ៍ និងថ្វាយបង្គំដោយគោរព ប្រកបដោយអង្គប្រាំ រួចហើយបីត្រៃចីវរ

ប្រណម្យដៃ អង្គុយលុតជង្គង់ ឬឈរបង្អោនខ្ជូនបន្តិច ចំពោះមុខ ព្រះឧបជ្ឈាយ៍ ហើយបញ្ចេញវាចា សូមដល់សរណៈ និងសូមបព្វជ្ជា ដោយមគធភាសា ដូចមានវិធីជារបៀបហូរហែ តទៅនេះ ៖

ទី១- សុំដល់សរណៈ សូត្របាលីថាដូច្នេះ ៖

ឯសាហំ ភន្តេ សុចិរបរិនិព្ធុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ, ធម្មញ្ច ភិក្ខុសង្ឆញ្ច, លភេយ្យាហំ ភន្តេ, តស្ស ភគវតោ ធម្មវិនយេ បព្វជ្ជំ[(១)] ។

ឧតិយម្បាហំ ភន្តេ សុចិរបរិនិព្ធុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ, ធម្មញ្ច ភិក្ខុសង្ឆញ្ច, លភេយ្យាហំ ភន្តេ, តស្ស ភគវតោ ធម្មវិនយេ បព្វជ្ជំ ។

តតិយម្បាហំ ភន្តេ សុចិរបរិនិព្ធុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ, ធម្មញ្ច ភិក្ខុសង្ឆញ្ច, លភេយ្យាហំ ភន្តេ, តស្ស ភគវតោ ធម្មវិនយេ បព្វជ្ជំ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំសូមដល់នូវព្រះដ៏មានបុណ្យនោះ សូម្បីព្រះអង្គបរិនិព្វានទៅជាយូរអង្វែងហើយ ព្រះធម៌ផងព្រះសង្ឆផង

(១) បើបូសភិក្ខុជាប់ផង ត្រូវសូត្រថា "លភេយ្យំ ឧបសម្បទំ" ថែមទៀត បន្តអំពីបាលីថា "បព្វជ្ជំ, ទៅ ។ ប្រែថាខ្ញុំគប្បីបាននូវឧបសម្បទ ។

ថាជាទីពឹងស្មើដោយជីវិត, ខ្ញុំគប្បីបាននូវបព្វជ្ជាក្នុង ធម៌វិន័យ នៃព្រះ ដ៏មានបុណ្យនោះ ។

ទី ២- សុំបព្វជ្ជា

បព្វជ្ជាបេក្ខ: ត្រូវអង្គុយលុតជង្គង់ លើកដៃប្រណម្យ សូត្រ បាលី ថាដូច្នេះ ៖

អហំ ភន្តេ បព្វជ្ជំ យាចាមិ ។

ទុតិយម្ពិ អហំ ភន្តេ បព្វជ្ជំ យាចាមិ ។

តតិយម្ពិ អហំ ភន្តេ បព្វជ្ជំ យាចាមិ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំសូមនូវបព្វជ្ជា ។

ទី ៣- ប្រគេនត្រៃចីវរទៅព្រះឧបជ្ឈាយ៍ សុំឲ្យលោកបំបួស

បព្វជ្ជាបេក្ខ: គប្បីប្រគេនត្រៃចីវរទៅព្រះឧបជ្ឈាយ៍មុន ហើយ ទូលសុំឲ្យលោកអនុគ្រោះឲ្យនូវសំពត់កាសាវពស្ត្រទាំងឡាយនេះ ទាំង សុំឲ្យលោកបំបួសខ្ជួនជាសាមណេរ ដើម្បីប្រយោជន៍ធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វាន ជាទីរលាស់ចាកទុក្ខ ទាំងពួង ។

ដោយសូត្របាលីសុំថាដូច្នេះ ៖

សព្វឧុក្ខនិស្សរណនិព្វានសច្ឆិការណត្ថាយ ឯតានិ កាសាយានិ វត្ថានិ ឧត្វា, បព្វាជេថ មំ ភន្តេ, អនុកម្បំ ឧចាជាយ ។ (*សូត្របីដង*)

កាលព្រះឧបជ្ឈាយ៍ឲ្យត្រៃចីវរមកបព្វជ្ជាបេក្ខ:ៗ ត្រូវសូត្របាលីនេះ តទៅទៀតថា ៖

សព្វឧុក្ខនិស្សរណនិព្វានសច្ឆិការណត្ថាយ ឥមានិ កាសាយានិ វត្ថានិ ភហេត្វា, បព្វាជេថ មំ ភន្តេ, អនុកម្បំ ឧចាជាយ ។ (*សូត្របីដង*)

បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាអនុគ្រោះកាន់យក នូវសំពត់កាសាវពស្ត្រទាំងឡាយនេះ ហើយមេត្តាបំបួសខ្ញុំជាសាមណេរចុះ ដើម្បីប្រយោជន៍ធ្វើឲ្យច្បាស់នូវព្រះនិព្វានជាទីរលាស់ ចាកទុក្ខទាំងពួង ។

ទី ៤- ព្រះឧបជ្ឈាយ៍ប្រដៅតចបញ្ចកកម្មដ្ឋាន

កាលបើបព្វជ្ជាបេក្ខ:សូត្រប្រកាសសុំឲ្យបំបួសចប់ហើយ ឧបជ្ឈាយ៍ត្រូវប្រគល់ត្រៃចីវរដល់បព្វជ្ជាបេក្ខ:វិញ ហើយបំពាក់អង្សីកនៅក ប្រាប់ "តចបញ្ចកកម្មដ្ឋាន" ទាំង៥ ជាអនុលោម បដិលោម ដូច្នេះថា ៖

"**ឥសា** សក់, **លោមា** រោម, **ឆវា** ក្រចក, **ឧន្តា** ធ្មេញ, **តចោ** ស្បែក, **តចោ** ស្បែក, **ឧន្តា** ធ្មេញ, **ឆវា** ក្រចក, **លោមា** រោម, **ឥសា** សក់" ។

ពន្យល់ប្រាប់បពូជ្ជាបេក្ខ:ថា ទាំង៥នេះ ហៅថា "មូលកម្មដ្ឋាន" ឬហៅថា "តចបញ្ចកកម្មដ្ឋាន" កម្មដ្ឋានមានស្បែកជាគម្រប់ ៥ គឺ សក់, រោម, ក្រចក, ធ្មេញ, ស្បែក អាការ:ទាំង ៥ នេះ មិនមែនសត្វមិនមែនបុគ្គលខ្ជូនប្រាណឡើយ គ្រាន់តែជាសក់, រោម, ក្រចក, ធ្មេញ, ស្បែក, ប៉ុណ្ណោះ ហើយជារបស់បដិកូល មុខគួរខ្ពើមរអើមពេកណាស់ ។

ហេតុនេះ កាលអ្នកបានបួសជាបពូជិតរួចហើយ គប្បីឧស្សាហ៍ពិចារណា "បដិកូលកម្មដ្ឋាន" នោះ ឲ្យរឿយៗ ទៅ ហើយអ្នកគួរត្រេកអរក្នុងភេទបពូជិតនេះចុះ ទើបរលាស់ខ្ជូនឲ្យរួចចាកទុក្ខទាំងពួងបាន ។

លុះពន្យល់ចប់ហើយ បង្គាប់ឲ្យយកត្រៃចីវរក្នុងដៃចេញទៅក្រៅទីប្រជុំ ស្ងៀកដណ្តប់ឲ្យជាបរិមណ្ឌល ហើយឲ្យចូលមកសុំសរណ-គមន៍ និងសីល ។

ទី ៥- សុំសរណគមន៍ និងសីល

លុះបពូជ្ជាបេក្ខ: ស្ងៀកដណ្តាប់ស្បង់ចីពរជាបរិមណ្ឌលសមរម្យ ហើយ ត្រូវចូលទៅអង្គុយលុតជង្គង់ ចំពោះមុខព្រះមហាថេរជា ឧបជ្ឈាយ៍ក្តី ជាអាចារ្យក្តី សុំសរណ(គមន៍) និងសីល ដោយសូត្រ បាលីថាដូច្នេះ

អហំ ភន្តេ សរណសីលំ យាចាមិ ។

ទុតិយម្បិ អហំ ភន្តេ សរណសីលំ យាចាមិ ។

តតិយម្បិ អហំ ភន្តេ សរណសីលំ យាចាមិ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំសុំសរណ: និងសីល ។

រួចសូត្របាលីនមស្សការ ៣ បទថា ៖

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ទី ៦- ឲ្យព្រះត្រៃសរណគមន៍ និងសីល

*ឧបជ្ឈាយ៍ ឬ អាចារ្យ មុននឹងឲ្យ សរណ: និងសីល គប្បីសូត្រ "នមោ..." ៣ បទសិន ។ រួចប្រាប់បពូជ្ជាបេក្ខ:ថា "យើងពោលនូវ ពាក្យឯណា អ្នកចូរពោលនូវពាក្យនោះតាម" ហើយសូត្របាលីនេះ ថា "**យមហំ វទាមិ តំ វទេហិ, ឯវំ វទេហិ**" ។ បពូជ្ជាបេក្ខ: ទទួលថា "**អាម ភន្តេ**" ។*

ក)- ឲ្យព្រះត្រៃសរណ (គមន៍)

ឧបជ្ឈាយ៍ ឬអាចារ្យ ប្រាប់ព្រះត្រៃសរណគមន៍ ឲ្យបព្វជ្ជាបេក្ខ: ទទួលថាតាមថា ៖

ពុទ្ធំ សរណំ កច្ឆាមិ ។ ធម្មំ សរណំ កច្ឆាមិ ។ សង្ឆ្យំ សរណំ កច្ឆាមិ ។

ទុតិយម្ឋិ ពុទ្ធំ សរណំ កច្ឆាមិ ។ ទុតិយម្ឋិ ធម្មំ សរណំ កច្ឆាមិ ។ ទុតិយម្ឋិ សង្ឆ្យំ សរណំ កច្ឆាមិ ។

តតិយម្ឋិ ពុទ្ធំ សរណំ កច្ឆាមិ ។ តតិយម្ឋិ ធម្មំ សរណំ កច្ឆាមិ ។ តតិយម្ឋិ សង្ឆ្យំ សរណំ កច្ឆាមិ[(១)] ។

ខ្ញុំសូមដល់ព្រះពុទ្ធ... ព្រះធម៌... ព្រះសង្ឆ... ជាទីពឹងទីរលឹក (ស្មើដោយជីវិត) ។

ពុទ្ធម[(២)] សរណម កច្ឆាមិ ។ ធម្មម សរណម កច្ឆាមិ ។ សំឃម សរណំ កច្ឆាមិ ។

---

(១)សរណគមន៍ឃ្លាដើមគឺ ពុទ្ធំ.. មានក្នុងបាលីវិនយបិដកមហាខន្ធក:, ឃ្លាចុងគឺ ពុទ្ធម..,ពុំឃើញមានទេ ។ តែក្នុងបាលីវេយ្យាករណ៍ ត្រង់វិធីអក្ខរ: ពោលនិគ្គហិតទុក ជាពីរ ជាអនុនាសិកន្ត: អានឲ្យមានតួសំឡេងដូចតួអក្សរ "ង" នៅខាងចុង ពុទ្ធំ សរណំ.. ជាមការន្ត អានឲ្យមានសូរសំឡេងដូចអក្សរ "ម" នៅខាងចុង ពុទ្ធម សរណម..។ សរណគមន៍ខាងចុងមានក្នុងតតិយសាមន្តបាសាទិកា អដ្ឋកថាមហាវគ្គ ។

(២)ឲ្យអានថា ពុទ្ធ័ម

ទុតិយម្បិ ពុទ្ធម សរណម កច្ឆាមិ ។ ទុតិយម្បិ ធម្មម សរណម កច្ឆាមិ ។ ទុតិយម្បិ សំឃម សរណម កច្ឆាមិ ។

តតិយម្បិ ពុទ្ធម សរណម កច្ឆាមិ ។ តតិយម្បិ ធម្មម សរណម កច្ឆាមិ ។ តតិយម្បិ សំឃម សរណម កច្ឆាមិ ។

*ឧបជ្ឌាយ៍ ឬអាចារ្យសូត្រថា "**តិសរណគមនំ និដ្ឋិតំ**" បព្វជ្ជាបេក្ខ: ទទួលថា "**អាម ភន្តេ**" ។*

ចប់ត្រៃសរណគមន៍ហើយ ភេទសាមណេរសម្រេចដល់បព្វជ្ជ-បេក្ខ:នោះភ្លាម ឈ្មោះថាសាមណេរសម្រេចឡើង ដោយព្រះត្រៃ-សរណគមន៍ ជាឧកតោសុទ្ធិ "បរិសុទ្ធទាំងពីរខាង" គឺអ្នកឲ្យនិងអ្នកទទួល ពោលបាលីត្រឹមត្រូវតាមអក្ខរវិធីដូចគ្នាទាំងពីររូប ។

២)- ឲ្យសីល[១]

ឧបជ្ឌាយ៍ ឬអាចារ្យ ប្រាប់សិក្ខាបទ ១០ ឲ្យបព្វជ្ជាបេក្ខ: ទទួលថាតាមថា ៖

---

(១) វិធីឲ្យសីល ១០ ដល់សាមណេរ តាមបាលីវិនយបិដកមហាខន្ធក: ថាត្រឹមតែ "បាណាតិបាតា វេរមណី" គ្រប់សិក្ខាបទទាំង ១០ ពុំមាន "សិក្ខាបទំ សមាទិយামি" ទេ ។ តែអដ្ឋកថាខុទ្ទកបាឋ:ថាគួរថែម "សិក្ខាបទំ សមាទិយামি" ផង ព្រោះពុំជាហេតុធ្វើឲ្យកម្រើក ឬវិបត្តិដល់សីលឡើយ ថែមមកគ្រាន់តែដើម្បីសេចក្ដីពិរោះស្ដាប់ប៉ុណ្ណោះ ទើបនិយមប្រើតៗមក ។

ចាណាតិចាតា វេរមណីសិក្ខាបទំ សមាទិយামি ។

អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយামি ។

អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយামি ។

មុសាវាទា វេរមណីសិក្ខាបទំ សមាទិយামি ។

សុរាមេរយមជ្ជបមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយামি ។

វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយামি ។

នច្ចគីតវាទិតវិសូកទស្សនា វេរមណីសិក្ខាបទំ សមាទិយামি ។

មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយামি ។

ឧច្চាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយামি ។

ជាតរូបរជតបដិគ្គហណា វេរមណីសិក្ខាបទំ សមាទិយামি ។

ឥមានិ ទស សិក្ខាបទានិ សមាទិយামি[1] ។ (*៣ចប់*)

សរណគមន៍ និងសីល ចប់

(១) លោកអ្នកឲ្យ សូត្រ ១ចប់, យើងអ្នកទទួល ត្រូវសូត្រ ៣ចប់ ។

ទី ៧- សុំនិស្ស័យ

លុះបានភេទជាសាមណេរស្រេចហើយ ត្រូវសុំនៅអាស្រ័យ ដោយសូត្របាលីជាដូច្នេះ ៖

អហំ ភន្តេ និស្សយំ យាចាមិ ។

ទុតិយម្បិ អហំ ភន្តេ និស្សយំ យាចាមិ ។

តតិយម្បិ អហំ ភន្តេ និស្សយំ យាចាមិ ។

ខ្ញុំសុំនូវនិស្ស័យ (គឺសុំនៅអាស្រ័យ) ។

រួចសុំលោកធ្វើជាឧបជ្ឈាយ៍ ដោយសូត្របាលីនេះថា ៖

ឧបជ្ឈាយោ មេ ភន្តេ ហោហិ *។ ៣ដង ។*

*ឧបជ្ឈាយ៍ប្រាប់ថា "***បដិរូបំ***" ឬថា "***ចាសាទិកេន សម្បាទេហិ***" ឬថា "***ឱចាយិកំ***" ។ សាមណេរត្រូវទទួលថា "***សាធុ ភន្តេ***" ។*

តអំពីនេះ សាមណេរគប្បីពោលទទួលធុរៈ ចំពោះលោកតទៅថា **អជ្ជតគ្គេទានិ ថេរោ មយ្ហំ ភារោ អហំបិ ថេរស្ស ភារោ ។** *(សូត្រ ៣ដង)*

ចាប់ពីថ្ងៃនេះទៅ ព្រះថេរៈជាភារៈ របស់ខ្ញុំ ខ្ញុំជាភារៈរបស់ព្រះថេរៈ ។

ម៉ាងទៀត សាមណេរក្តី ភិក្ខុក្តី កាលចូលទៅនៅក្នុងសំណាក់ភិក្ខុដទៃ ក្រៅពីឧបជ្ឈាយ៍ គប្បីសុំនៅអាស្រ័យ ទាំងសុំលោកធ្វើជាអាចារ្យ ដោយសូត្របាលីថាដូច្នេះ ៖

អហំ ភន្តេ និស្សយំ យាចាមិ ។

ឧតិយម្ឯិ អហំ ភន្តេ និស្សយំ យាចាមិ ។

តតិយម្ឯិ អហំ ភន្តេ និស្សយំ យាចាមិ ។

អាចរិយោ មេ ភន្តេ ហោហិ, អាយស្មតោ និស្សាយ វច្ឆាមិ *។ (សូត្រ ៣ ដង)*

*រួចហើយសូត្រ "***អជ្ជតគ្គេឧានិ ថេរោ...ភារោ***" ៣ ដង ។*

សុំនិស្សយ ចប់

កាលបពូជ្ជាបេក្ខ: បានធ្វើកិច្ចសពូគ្រប់យ៉ាងនេះហើយ ឈ្មោះថាបានភេទជាសាមណេរពេញបរិបូណ៍ តទៅត្រូវខំរក្សាសិក្ខាបទ ១០ ឲ្យបរិសុទ្ធប្រពៃឡើង, ទាំងត្រូវឧស្សាហ៍ធ្វើ កិច្ចវត្តផ្សេងៗទៀត ។

ម៉ាងទៀតតាមសេចក្តីពន្យល់ក្នុង វិមតិវិនោទនី ដីកាវិនយមហាខន្ធក: ថា អ្នកបួសបានជាសាមណេរហើយ ត្រូវប្រព្រឹត្តប្រតិបត្តិតាមខបញ្ញត្តិ ក្នុងសេខិយវត្តផង និងខន្ធកវត្តទាំងឡាយផង ទាំងក្នុងមាត្រា

ហាមដែលជាលោកវជ្ជ:ផង, បើពុំប្រព្រឹត្តតាមទេ, សាមណេរនោះ ឈ្មោះថាជាអលជ្ជីផង គួរទទួលទណ្ឌកម្មផង ។

ដំណើរនេះហើយ បានជាសាមណេរត្រូវតែស្ងៀក ដណ្តប់ គ្រង ឃ្ងុំស្បង់ចីពរ ឲ្យមានរបៀបជាបរិមណ្ឌល ដូចគ្នានឹងភិក្ខុដែរ ។

បញ្ចជ្ជាវិធីសង្ខេបប៉ុណ្ណោះ
វិធីរៀនដើម្បីបួសជាសាមណេរចប់

អញ្ញាបជ្ឈំ សុខំ លោកេ

សេចក្តីមិនបៀតបៀនគ្នា ជាសុខក្នុងលោក ។

នមត្ថុ រតនត្តយស្ស

វិធីរៀនដើម្បីឧបសម្បទ[(១)]

ធម៌ ៧ ប្រការ

រតនត្តយំ រន្ទិត្វា បុព្ធសិក្ខំ រជាមិហំ
សិក្ខន្តានំ សុភំ ហោតុ រឌ្ឍន្ត្ុ ពុជ្ធសាសនេ ។

ខ្ញុំសូមថ្វាយបង្គំព្រះរតនត្រៃ ហើយនិងពោលនូវបុព្ធសិក្ខា (វិធីរៀនដើម្បីឧបសម្បទ) សូមសុភមង្គលចូរកើតមាន ដល់អ្នកសិក្សាទាំងឡាយ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ។

កុលបុត្រអ្នកមានសទ្ធាជ្រះថ្លា ប្រាថ្នាឧបសម្បទជាភិក្ខុគប្បីសិក្សាធម៌៧[(២)]ប្រការ នេះជាមុន ។

ឯធម៌ ៧ ប្រការនោះគឺ ៖

១) រតនត្តយបព្ធ: *ពោលដោយគុណព្រះរតនត្រៃ ។*

២) អាបត្តិនាមាធិបព្ធ: *ពោលដោយឈ្មោះនៃអាបត្តិ ជាដើម ។*

---

(១)ស្រង់ពីបុព្ធសិក្ខាសង្ខេប របស់សម្តេចព្រះសុគន្ធាសង្ឃរាជាធិបតីសង្ឃនាយកគណ:ធម្មយុត្ត ព្រះនាម "បញ្ញាសីលោ" ប៉ាន ។ តែមានថែម បំពេញខ្លះ ទៀត ។
(២)ក្នុងបុព្ធសិក្ខាសង្ខេបថា គប្បីសិក្សាសេចក្តី ៧ ប្រការ នេះជាមុន ហើយទាំងពុំបាន រាយមាតិកាទុកដូចនេះទេ ។

៣) បដិបត្តិមុខបញ្ជ: *ពោលដោយសិក្ខាបទជាប្រធាននៃផ្លូវបដិបត្តិ ។*

៤) អភិសមាចារបញ្ជ: *ពោលដោយក្បួនទំនៀមទម្លាប់ ដែលភិក្ខុគួរប្រព្រឹត្តមានមកក្រៅចាកព្រះបាតិមោក្ខ ។*

៥) កាលិកបញ្ជ: *ពោលដោយកាលិក គឺវត្ថុដែលនឹងគប្បី លេបចូលទៅតាមកំណត់កាល ។*

៦) ពិន្ធាធិដ្ឋានាធិបញ្ជ: *ពោលដោយវិធីមានពិន្ទុ អធិដ្ឋានជាដើម ។*

៧) ឧចោសថាធិបញ្ជ: *ពោលដោយកម្ម មានឧបោសថកម្ម ជាដើម ។*

ទី ១- រតនត្តយបញ្ជ:

ពោលដោយគុណព្រះរតនត្រៃ

សេចក្តីថាព្រះមានព្រះភាគនោះ ព្រះអង្គកើតជាមនុស្ស អរិយក: ក្នុងមជ្ឈិមប្រទេស ដោយព្រះជាតិជាក្សត្រិយ៍ ដោយព្រះគោត្រជាគោតមគោត្រ ជាបុត្រសាក្យរាជត្រកូល បានបួសហើយ ព្រះអង្គស្វែងសន្តិវរបទ គឺធម៌ស្ងប់ដ៏ប្រសើរ ពុំមានអ្នកឯណាលើសព្រះអង្គឡើយ ព្រះអង្គលះនីវរណធម៌ទាំង ៥ ជាអំពើរាំងរាចិត្ត ធ្វើប្រាជ្ញាឲ្យបង់កម្ទាំង មានព្រះទ័យស្ថិតខ្ជាប់ក្នុងសតិបដ្ឋានទាំង ៤, ចម្រើនពោជ្ឌង្គ

ទាំង ៧ ឲ្យជាក់ច្បាស់ ត្រាស់ដឹងនូវសម្មាសម្ពោធិធម៌ដោយព្រះអង្គ ឯង ក្រោមដើមអសត្ថព្រឹក្សមហាពោធិស្ថាន ប្រហនៃ្ធ្ងរស្ទឹងនេរញ្ជរា ។ កិត្តិស័ព្ទដ៏ប្រពៃ នៃព្រះមានព្រះភាគខ្ជីរខ្ជាទៅថា ៖

ឥតិបិ ពិតដូច្នេះ **សោ ភគវា** ព្រះមានព្រះភាគនោះ **អរហំ** ព្រះអង្គឆ្ងាយចាកកិលេសហើយ **សម្មាសម្ពុទ្ធោ** ព្រះអង្គត្រាស់ដឹងឯងប្រពៃហើយ **វិជ្ជាចរណសម្បន្នោ** ព្រះអង្គប្រកបដោយវិជ្ជានិងចរណៈហើយ **សុគតោ** ព្រះអង្គយាងទៅកាន់ទីដ៏ប្រពៃ គឺព្រះនិព្វាន **លោកវិទូ** ព្រះអង្គជ្រាបច្បាស់នូវលោក **អនុត្តរោ បុរិសទម្មសារថិ** ព្រះអង្គទូន្មានបុរសដ៏គួរទូន្មាន ពុំមានអ្នកឯណាស្មើ **សត្ថា ទេវមនុស្សានំ** ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សសត្វផងទាំងឡាយ **ពុទ្ធោ** ព្រះអង្គមានព្រះគុណរីកពេញហើយ **ភគវា** ព្រះអង្គញែកចេញសម្តែងនូវមគ្គផល ដល់សត្វទាំងឡាយពុំមានរើសមុខ ។

ធម្មោ សេចក្តីប្រពៃពិត គឺព្រះបរិយត្តិមគ្គផល ព្រះនិព្វាន **স্বাক্খাতো ភគវតា** ព្រះមានព្រះភាគត្រាស់ទុកប្រពៃហើយ **សន្ទិដ្ឋិកោ** ជាធម៌គឺអ្នកប្រតិបត្តិ គប្បីឃើញឯងច្បាស់ **អកាលិកោ** ជាធម៌ឲ្យផលពុំមានកាលខណ្ឌ **ឯហិបស្សិកោ** ជាធម៌មានអាការបើដូចជានឹងហៅថា អ្នកចូលមកមើលបាន **ឱបនយិកោ** ជាធម៌គួរ

បង្ហោនមកដាក់ក្នុង (កាយវាចា) ចិត្តបាន **បច្ចត្តំ** **វេទិតព្វោ** **វិញ្ញូហិ** *ជាធម៌គឺអ្នកដែលដឹងវិសេសទាំងឡាយ គប្បីដឹងចំពោះខ្លួន ។*

ភគវតោ **សាវកសំឃោ** *ព្រះសង្ឆសាវកនៃព្រះដ៏មានព្រះភាគ* **សុបដិបន្នោ** *លោកប្រតិបត្តិប្រពៃហើយ* **ឧជុបដិបន្នោ** *លោកប្រតិបត្តិត្រង់ហើយ* **ញាយបដិបន្នោ** *លោកប្រតិបត្តិចេញចាកសង្សារទុក្ខហើយ* **សាមីចិបដិបន្នោ** *លោកប្រតិបត្តិសមគួរនឹងព្រះនិញ្ជានហើយ* **យទិទំ** *ព្រះសង្ឆសាវកនេះដូចម្តេច?* **ចត្តារិ** **បុរិសយុគានិ** *រាប់ដោយគូ មាន ៤ គូ* **អដ្ឋបុរិសបុគ្គលា** *រាប់រៀងខ្លួនមាន ៨* **សោតាបន្នោ** *លោកទើបដល់ប្រឡាយព្រះនិញ្ជាន* **សកទាគាមី** *លោកមកកាន់កាមធាតុម្តងទៀត* **អនាគាមី** *លោកមិនបានមកទៀតឡើយ* **អរហំ** *លោកធ្វាយចាកកិលេសហើយ* **ឯស** *លោកនេះ* **ភគវតោ** **សាវកសំឃោ** *ព្រះសង្ឆសាវកនៃព្រះដ៏មានព្រះភាគ* **អាហុនេយ្យោ** *លោកគួរទទួលរបស់ដែលគេនាំមកបូជា* **ទាហុនេយ្យោ** *លោកគួរទទួលរបស់ដែលគេនាំមកទទួលភ្ជៀវ* **ទក្ខិណេយ្យោ** *លោកគួរទទួលទក្ខិណាទាន* **អញ្ជលិករណីយោ** *លោកគួរធ្វើអញ្ជលីប្រណម្យ* **អនុត្តរំ** **បុញ្ញក្ខេត្តំ** **លោកស្ស** *ជាស្រែបុណ្យនៃលោកពុំមានវត្ថុអ្វីលើស ។*

រតនត្តយបព្ជ: ចប់

ទី ២- អាបត្តិនាមាទិបញ្ចៈ(១)

ពោលដោយឈ្មោះនៃអាបត្តិជាដើម

អនុសាសនៈ ពាក្យប្រៀនប្រដៅមាន ៨ យ៉ាងគឺ ៖ និស្សយ ៤ អករណីយកិច្ច ៤ ។

បច្ច័យគ្រឿងអាស្រ័យរបស់បព្វជិត ហៅថា និស្សយមាន ៤ គឺ ៖

បិណ្ឌាចាតចរណំ *ត្រាច់ទៅបិណ្ឌបាត ១*

បំសុកូលចីវរំ *ស្លៀកដណ្តប់សំពត់បង្សុកូល ១*

រុក្ខមូលសេនាសនំ *អាស្រ័យក្រោមដើមឈើជាសេនាសនៈ ១*

ឬតិមុត្តភេសជ្ជំ *អាស្រ័យទឹកនោមផ្អូមជាថ្នាំ ១*

ឬហៅថា ករណីយកិច្ចជាកិច្ចដែលបព្វជិតគួរធ្វើ ។

កិច្ចដែលបព្វជិតមិនគួរធ្វើ ហៅថាអករណីយកិច្ចមាន ៤ គឺ៖

មេថុនសេវនៈ *សេពមេថុន ១,* **អទិន្នាទានៈ** *លួចទ្រព្យគេ ១,* **សញ្ចិច្ចបាណៈ** *សម្លាប់សត្ត ១,* **ឧត្តរិមនុស្សធម្មៈ** *អួតគុណវិសេសដែលពុំមានក្នុងខ្លួន ១ ។*

អនុសាសនៈ ៨ យ៉ាងចប់

---

(១)បុព្វសិក្ខាសង្ខេបថា"គម្រប់ពីរពោលដោយវិនយមុខដែលជាផ្លូវបដិបត្តិនៃបព្វជិត។

សិក្ខានៃភិក្ខុមាន ៣ គឺ

សីល ១, **សមាធិ** ១, **បញ្ញា** ១ ។

សេចក្តីសង្រួមកាយវាចាឲ្យល្អជាប្រក្រតី ហៅថា **សីល** ។

សេចក្តីរក្សាចិត្ត ឲ្យនឹងល្អ ហៅថា **សមាធិ** ។

សេចក្តីដឹងច្បាស់ដល់សង្ខារ ហៅថា **បញ្ញា** ។

អាបត្តិ

ទោសដែលកើតឡើងព្រោះល្មើសព្រះពុទ្ធបញ្ញត្តិហៅថា អាបត្តិ ។ ពោលដោយឈ្មោះមាន ៧ គឺ ៖

ចារាជិក ១ **សំឃាទិសេស** ១ **ថុល្លច្ចយ** ១ **ចាចិត្តិយ** ១ **ចាដិទេសនីយ** ១ **ទុក្កដ** ១ **ទុព្ភាសិត** ១ ។

ចារាជិក *ជាអតេកិច្ចា ភិក្ខុត្រូវហើយរក្សាតទៅមិនបាន ក្រៅពីនោះ ៦ ជាសតេកិច្ចា ភិក្ខុត្រូវហើយ រក្សាតទៅបាន ។*

ចារាជិក សំឃាទិសេស *ជាគរុកាបត្តិ គឺអាបត្តិធ្ងន់ក្រៅពីនោះ ៥ ជាលហុកាបត្តិ គឺអាបត្តិស្រាល ។*

សំឃាទិសេស *ជាវុដ្ឋានគាមិនី រួចបានដោយនៅបរិវាសកម្ម, ក្រៅនោះ ៥ ជាទេសនាគាមិនី រួចបានដោយសម្តែង ។*

សិក្ខាបទទាំងអស់ពោលដោយចិត្តមាន ២គឺ ៖

សចិត្តក: *ក្ងែង ១,* **អចិត្តក:** *មិនក្ងែង ១ ។*

ដោយទោសមានពីរ គឺ៖

លោកវជ្ជ: *ទោសតាមធម្មតាលោក ១,* **បណ្ណត្តិវជ្ជ:** *ទោសព្រោះព្រះបញ្ញត្តិ ១ ។*

សមុដ្ឋានទីកើតនៃអាបត្តិមាន ៦ គឺ ៖

កាយ ១, វាចា ១, កាយវាចា ១, កាយចិត្ត ១, វាចាចិត្ត ១, កាយវាចាចិត្ត ១ *។ ៣ខាងដើមជាអចិត្តកសមុដ្ឋាន, ៣ខាងចុងជាសចិត្តកសមុដ្ឋាន ។*

អាការដែលភិក្ខុនឹងត្រូវអាបត្តិមាន ៦ យ៉ាងគឺ ៖

អលជ្ជិតា *ត្រូវដោយមិនអៀនអន់ ១*

អញ្ញាណតា *ត្រូវដោយមិនដឹងបញ្ញត្តិ ១*

កុក្កុចូបកតតា *ត្រូវដោយរង្កៀសហើយធ្វើ ១*

អកប្បិយេ កប្បិយសញ្ញិតា *ត្រូវដោយសម្គាល់ថាគួរក្នុងវត្ថុមិនគួរ ១*

កប្បិយេ អកប្បិយសញ្ញិតា *ត្រូវដោយសម្គាល់ថាមិនគួរក្នុងវត្ថុគួរ ១*

សតិសម្មោសា *ត្រូវដោយភ្ជេចស្មារតី ១ ។*

អាបត្តិនាមាទិបញ្ចៈចប់

ទី៣- បដិបត្តិមុខសិក្ខាបទបញ្ចៈ(១)

ពោលដោយសិក្ខាបទជាប្រធាននៃផ្លូវបដិបត្តិ

ព្រះពុទ្ធបញ្ញត្តិ ដែលលើកឡើងជាសិក្ខាបទ មានមកក្នុងព្រះបាតិមោក្ខ ១ មិនមានមកក្នុងព្រះបាតិមោក្ខ ១ ។

សិក្ខាបទដែលមានមកក្នុងព្រះបាតិមោក្ខគឺ **ចារាជិក ៤ សំឃាទិសេស ១៣ អនិយត ២ និស្សត្តិយចាចិត្តិយ ៣០ សុទ្ធិកចាចិត្តិយ ៩២ ចាជិទេសនីយ ៤ សេខិយ ៧៥** *រួមជា ២២០ រាប់ទាំងអធិករណសមថផងត្រូវជា ២២៧ ។*

បារាជិក ៤

១) **មេថុនសិក្ខាបទ** *ភិក្ខុសេពមេថុនធម្ម ត្រូវបារាជិក ។*

២) **អទិន្នាទាន...** *ភិក្ខុលួចខ្លួនឯង ឬប្រើគេឲ្យលួចនូវទ្រព្យមានតម្លៃពី ៥មាសកឡើងទៅត្រូវបារាជិក ។*

---

(១) ក្នុងបុព្វសិក្ខាសង្ខេបថា "គម្រប់ ៣ដោយសិក្ខាបទ" ។

៣) **មនុស្សវិត្តហ...** *ភិក្ខុក្ងែងសម្ងាប់មនុស្សឲ្យស្ងាប់ ត្រូវបារាជិក ។*

៤) **ឧត្តរិមនុស្សធម្ម...** *ភិក្ខុអួតឧត្តរិមនុស្សធម្ម (គឺធម៌ដ៏លើសលុបនៃមនុស្ស) ដែលគ្មានក្នុងខ្លួនត្រូវបារាជិក ។*

ចប់ បារាជិក

សំឃាទិសេស ១៣

៧) **សញ្ចេតនិកាសិក្ខាបទ** *ភិក្ខុក្ងែងព្យាយាមឯង ឬប្រើគេឲ្យព្យាយាម ក្នុងអង្គជាតខ្លួនឲ្យអសុចិចេញ ត្រូវសំឃាទិសេស ។*

៨) **កាយសំសត្ត...** *ភិក្ខុមានចិត្តតម្រេក ហើយចាប់ពាល់កាយស្ត្រី ត្រូវសំឃាទិសេស ។*

៣) **ទុដ្ឋុល្ងវាច...** *ភិក្ខុមានចិត្តតម្រេក ពោលពាក្យចែចង់ស្ត្រី ត្រូវសំឃាទិសេស ។*

៤) **អត្តកាមចារិចរិយ...** *ភិក្ខុមានចិត្តតម្រេក ពោលពាក្យលួងលោម ឲ្យស្ត្រីបម្រើខ្លួនដោយកាម ត្រូវសំឃាទិសេស ។*

៥) **សញ្ចរិត្ត...** *ភិក្ខុនាំការឲ្យបុរសស្ត្រី ជាស្វាមីភរិយាគ្នា ត្រូវសំឃាទិសេស ។*

៦) ឧជិការ... *ភិក្ខុសាងកុដិបូកដោយកំបោរ ដែលគ្មានម្ចាស់ចំពោះជាលំនៅរបស់ខ្លួន គប្បីធ្វើបណ្តោយប្រវែង ១២ ចំអាម ទទឹង ៧ចំអាម ដោយចំអាមព្រះសុគត ហើយត្រូវឲ្យសង្ឃសម្តែងទី ជាមុន បើមិនឲ្យសង្ឃសម្តែងទីក្តី ធ្វើឲ្យហួសប្រមាណក្តី ត្រូវសំឃាទិសេស ។*

៧) មហល្ជក... *ភិក្ខុនឹងសាងលំនៅនោះ បើមានទាយក ជាម្ចាស់ ធ្វើឲ្យហួសប្រមាណនោះបាន តែគប្បីឲ្យសង្ឃសម្តែងទី ជាមុន បើមិនឲ្យសង្ឃសម្តែងទីឲ្យត្រូវសំឃាទិសេស ។*

៨) អមូលក... *ភិក្ខុខឹងនឹងភិក្ខុ ក្ងែងចោទដោយអាបត្តិបារាជិក មិនមានមូល ត្រូវសំឃាទិសេស ។*

៩) អញ្ញភាតិយ... *ភិក្ខុខឹងនឹងភិក្ខុ ក្ងែងរកឧបាយចោទដោយ អាបត្តិបារាជិក ត្រូវសំឃាទិសេស ។*

១០) សំឃភេជ... *ភិក្ខុព្យាយាមដើម្បីទម្ងាយសង្ឃ ឲ្យបែកគ្នា ភិក្ខុដទៃហាមឃាត់មិនស្តាប់ សង្ឃសូត្រសមនុភាសនកម្ម ដើម្បីឲ្យលះ សេចក្តីប្រព្រឹត្តនោះ បើមិនលះត្រូវសំឃាទិសេស ។*

១១) ភេជានុវត្តក... *ភិក្ខុប្រព្រឹត្តតាមភិក្ខុដែលទម្ងាយសង្ឃនោះ ភិក្ខុដទៃហាមឃាត់មិនស្តាប់ សង្ឃសូត្រសមនុភាសនកម្មដើម្បីឲ្យលះ សេចក្តីប្រព្រឹត្តនោះ បើមិនលះត្រូវសំឃាទិសេស ។*

១២) ឧព្ធចជាតិក... *ភិក្ខុប្រដៅក្រ ភិក្ខុដទៃហាមឃាត់មិនស្តាប់ សង្ឈសូត្រសមនុភាសនកម្ម ដើម្បីឲ្យលះសេចក្តីប្រព្រឹត្តនោះ បើមិនលះត្រូវសំឃាទិសេស ។*

១៣) កុលឧូសក... *ភិក្ខុប្រទូស្តវ៉ាយត្រកូល គឺប្រចុបគ្រហស្ត សង្ឈដេញចេញចាកអាវាស ត្រឡប់និន្ទាសង្ឈ ភិក្ខុដទៃហាមឃាត់មិនស្តាប់ សង្ឈសូត្រសមនុភាសនកម្ម ដើម្បីឲ្យលះសេចក្តីប្រព្រឹត្តនោះ ចេញ បើមិនលះ ត្រូវសំឃាទិសេស ។*

ក្នុងសំឃាទិសេសទាំង ១៣ សិក្ខាបទនេះ ៩ខាងដើមឈ្មោះ បឋមាបត្តិកា ត្រូវក្នុងខណៈដែលកន្ធងនោះ ៤ ខាងចុងឈ្មោះ យាវតតិយកា ត្រូវក្នុងខណៈសង្ឈសូត្រសមនុភាសនកម្ម ចប់ ៣ដង ។

ចប់ សំឃាទិសេស

អនិយត: ២

១) អលំកម្មនិយសិក្ខាបទ *ភិក្ខុអង្គុយក្នុងទីកំបាំងភ្នែក ជាមួយនឹងស្ត្រី តែមួយនឹងមួយ បើមានមនុស្សដែលគួរជឿ មកចោទដោយអាបត្តិ ៣ យ៉ាងគឺ អាបត្តិបារាជិក ឬសំឃាទិសេស ឬក៏បាចិត្តិយ អាបត្តិ ៣ នេះ ឯណានីមួយ ភិក្ខុទទួលយ៉ាងណា ឲ្យកាត់យ៉ាងនោះ ឬគេចោទចំពោះអាបត្តិណា ឲ្យកាត់តាមអាបត្តិនោះ ។*

២) ឌាលំកម្មនិយ... *កិក្ខុអង្គុយក្នុងទីវាលកំបាំងត្រចៀក ជាមួយស្ត្រី តែមួយនឹងមួយ បើមានមនុស្សដែលគួរជឿបាន មកចោទដោយអាបត្តិ ២យ៉ាងគឺ អាបត្តិសំឃាទិសេស, ឬ បាចិត្តិយ, ឯណានីមួយ កិក្ខុទទួលយ៉ាងណា ឲ្យកាត់យ៉ាងនោះ ឬ គេចោទចំពោះអាបត្តិណា ឲ្យកាត់តាមអាបត្តិនោះ ។*

ចប់ អនិយតៈ

និស្សគ្គិយបាចិត្តិយៈ ៣០

ចែកជា ៣ វគ្គ ក្នុង ១ វគ្គមាន ១០សិក្ខាបទ

ចីវរវគ្គទី ១

១) បឋមកឋិនសិក្ខាបទ *កិក្ខុកាលអានិសង្សកឋិនអស់ហើយ ទុកអតិរេកចីវរឲ្យកន្ធង ១០ថ្ងៃទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

២) ទុតិយកឋិនសិក្ខាបទ *កិក្ខុកាលអានិសង្សកឋិនអស់ហើយ នៅប្រាសចាកត្រៃចីវរឯណានីមួយ សូម្បី ១រាត្រី ត្រូវនិស្សគ្គិយ-បាចិត្តិយ រៀរតែបានសម្មតិ ។*

៣) តតិយកឋិន... *កាលអានិសង្សកឋិនអស់ហើយ បើសំពត់កើតឡើងដល់កិក្ខុ ប្រាថ្នានឹងធ្វើចីវរតែមិនគ្រាន់ បើនៅមានប្រាថ្នាថា*

នឹងបានមកទៀតទុកបាន ១ខែ បើទុកឲ្យកន្ធង់ពី ១ខែទៅ សូម្បីនៅមានប្រាជ្ញាទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។

៤) បុរាណចីវរ... *ភិក្ខុប្រើនាងភិក្ខុនីមិនជាញាតិ ឲ្យគក់ក្តី ជ្រលក់ក្តី ឲ្យបោកក្តី នូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៥) ចីវរបដិគ្គហណ... *ភិក្ខុទទួលចីវរអំពីដៃនាងភិក្ខុនី មិនជាញាតិ រៀងតែផ្ទាស់ប្តូរគ្នា ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៦) អញ្ញាតកវិញ្ញត្តិ... *ភិក្ខុសូមចីវរពីគ្រហស្ថមិនជាញាតិ មិនបានបវារណា ត្រូវនិស្សគ្គិយបាចិត្តិយ រៀងលែងតែមានសម័យគឺមានចីវរ ចោរលួច ឬបាត់ទៅ ។*

៧) តុត្តរិ... *បើមានសម័យដូច្នោះ ភិក្ខុនឹងសូមគេបានត្រឹមតែអន្តរវាសកនិងឧត្តរាសង្គ៦ប៉ុណ្ណោះ បើសូមឲ្យលើសជាងនោះបានមក ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៨) បឋមឧបក្ខ... *បើគ្រហស្ថមិនជាញាតិ មិនបានបវារណា គេនិយាយថា នឹងថ្វាយចីវរដល់ភិក្ខុឈ្មោះនេះ ភិក្ខុដឹងសេចក្តីហើយ ចូលទៅនិយាយឲ្យគេថ្វាយចីវរយ៉ាងនោះយ៉ាងនេះ ដែលមានតម្លៃថ្លៃជាង ល្អជាង កំណត់ដើម បានមក ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៩) ទុតិយឧបក្ខ... *បើគ្រហស្ថនឹងថ្វាយចីវរដល់ភិក្ខុ មានម្ចាស់ច្រើនគ្នា តែគេមិនជាញាតិមិនបានបវារណា ភិក្ខុទៅនិយាយឲ្យគេរួម*

តម្លៃជាមួយគ្នា ដើម្បីទិញចីវរដែលថ្ងៃជាង ល្អជាងកំណត់ដើម បានមក ត្រូវនិស្សគ្គិយបាចិត្តិយ ។

១០) ភ៨... បើគេនាំយកតម្លៃចីវរមកហើយ សួរភិក្ខុថាអ្នកណាជាវេយ្យាវច្ចករព្រះករុណា បើភិក្ខុត្រូវការចីវរគប្បីប្រាប់ថា ញោមវត្ត ឬឧបាសកជាវេយ្យាវច្ចករ បើគេប្រគល់តម្លៃឲ្យវេយ្យាវច្ចករនោះហើយ ប្រាប់ភិក្ខុនោះថាបើព្រះករុណាត្រូវការចីវរ ចូរទៅរកវេយ្យាវច្ចករ ភិក្ខុនោះគប្បីទារយកថា: យើងត្រូវការចីវរដូច្នេះបានបីដង បើមិនបានគប្បីទៅឈរតែល្មមឲ្យគេឃើញបាន ៦ដង, បើមិនបានខំទៅទារឲ្យលើស ៣ដង ឈរឲ្យលើស ៦ដង បានមក ត្រូវនិស្សគ្គិយបាចិត្តិយ ។

បើទៅទារទៅឈរគ្រប់កំណត់ហើយមិនបាន គប្បីទៅប្រាប់ដល់ម្ចាស់ដើមថា របស់នោះមិនសម្រេចប្រយោជន៍ដល់អាត្មាទេ ឲ្យគេទារយករបស់គេវិញ ។ នេះជាសាមីចិកម្ម គឺការល្អក្នុងរឿងនេះ ។

កោសិយវគ្គ ទី២

*១) **កោសិយសិក្ខាបទ** ភិក្ខុធ្វើសន្ថ័តដោយរោមចៀមលាយដោយសូត្រ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

*២) **សុទ្ធកាឡក**... ភិក្ខុធ្វើសន្ថ័តលាយដោយរោមចៀមខ្មៅសុទ្ធ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៣) ទ្វេភាគ... *ភិក្ខុធ្វើសន្ទ្ធតថ្មី គប្បីយកពោមចៀមខ្មៅ ២ភាគ ស ១ភាគ ក្រហម ១ភាគ បើយកពណ៌ខ្មៅឲ្យលើសពី ២ភាគឡើងទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៤) ឆព្វស្ស...*ភិក្ខុធ្វើសន្ទ្ធតថ្មីគប្បីប្រើឲ្យបាន ៦ ឆ្នាំ បើមិនទាន់ដល់ ៦ ឆ្នាំ ធ្វើថ្មីទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៥) ឯិ**ឡ**ីឧ**ណ**ាសន្ត**ត**... *ភិក្ខុនឹងធ្វើសន្ទ្ធត គប្បីកាត់យកសន្ទ្ធតចាស់ ១ ចំអាមដោយជុំវិញ មកលាយក្នុងសន្ទ្ធតដែលធ្វើថ្មី ដើម្បីរំលាយពណ៌ បើមិនដូច្នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៦) ឯឬ**ក**ាលោ**ម**... *កាលភិក្ខុដើរផ្លូវឆ្ងាយ បើមានគេថ្វាយពោមចៀម បើត្រូវការទទួលបាន បើគ្មានគេនាំមក នាំមកដោយខ្លួនឯង បានត្រឹម ៣យោជន៍ បើឲ្យលើសពី ៣យោជន៍ ត្រូវនិស្សគ្គិយ-បាចិត្តិយ ។*

៧) ណោ**ភ**ាម**ន**... *ភិក្ខុប្រើនាងភិក្ខុនីមិនជាញាតិ ឲ្យគក់ក្តី ឲ្យជ្រលក់ក្តី ឲ្យសិតក្តីនូវពោមចៀម ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៨) រូ**ប**ិ**យ**ប**ដ**ិ**ក្ខ**ហ**ាណ**ា... *ភិក្ខុទទួលឯងក្តី ប្រើគេឲ្យទទួលក្តី នូវមាសនិងប្រាក់ ឬត្រេកអរចំពោះមាសនិងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន ត្រូវនិស្សគ្គិយបាចិត្តិយ ។*

៩) **រូបិយសំវោហារ**... *ភិក្ខុទិញដូរដោយរូបិយ គឺរបស់ដែលគេសន្មតថាជាមាសនិងប្រាក់ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

១០) **កយវិក្កយ**... *ភិក្ខុផ្ទាស់ប្តូរគឺទិញដូរកប្បិយវត្ថុ និងកប្បិយ-វត្ថុនឹងគ្រហស្ថត្រូវនិស្សគ្គិយបាចិត្តិយ ។*

បត្តវគ្គទី ៣

១) **អតិរេកបត្តសិក្ខាបទ** *បាត្រដែលមិនទាន់អធិដ្ឋាន រិកប្ប ឈ្មោះអតិរេកបាត្រៗ នោះ ភិក្ខុទុកបានត្រឹម ១០ថ្ងៃ បើឲ្យកន្ទងពី ១០ថ្ងៃទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

២) **ឧនបញ្ចពន្ធន**.. *ភិក្ខុមានបាត្រប្រេះស្រាំមិនទាន់ដល់ ៥អន្ធើ សូមបាត្រថ្មីពីគ្រហស្ថមិនមែនជាញាតិមិនបានបវារណា បានមកត្រូវ និស្សគ្គិយបាចិត្តិយ ។*

៣) **ភេសជ្ជ**... *ភិក្ខុទទួលភេសជ្ជ:ទាំង ៥គឺ* **សប្បិ** *ខ្លាញ់រាវ,* **នវនីត** *ខ្លាញ់ខាប់,* **តេលំ** *ប្រេង,* **មធុ** *ទឹកឃ្មុំ,* **ផាណិត** *ស្ករអំពៅ, ហើយទុកឆាន់បានត្រឹម ៧ ថ្ងៃ បើឲ្យកន្ទងត្រឹម ៧ ថ្ងៃទៅ ត្រូវនិស្សគ្គិយ បាចិត្តិយ ។*

៤) **វស្សិកសាដក**... *កាលគិម្ហន្តរដូវនៅសល់ ១ខែ គឺអំពី ១រោចខែដេស្ឋ ទើបគួរស្វែងរកសំពត់ងូតទឹកភ្ជៀងបាន, កាលគិម្ហន្ត-*

រដូវនៅសល់កន្ទុះខែទៀត គឺពី ១ កើតខែអាសាធ ទើបគួរធ្វើ
ស្ទៀកបាន, បើស្វែងរក ឬធ្វើស្ទៀកឲ្យថយអំពីកំណត់នោះចុះមក
ត្រូវ និស្សគ្គិយបាចិត្តិយ ។

*៤) **ចីវរច្ឆិន្ទន**... កិក្ខុឲ្យចីវរដល់កិក្ខុដទៃហើយ ក្រោធខឹងដណ្តើម*
យកមកខ្លួនឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ ។

*៦) **សុត្តវិញ្ញត្តិ** កិក្ខុសូមអម្ចាស់អំពីគ្រហស្ថមិនជាញាតិ មិនបាន*
បវារណា យកមកឲ្យជាងតម្បាញត្បាញជាចីវរ ត្រូវនិស្សគ្គិយ-
បាចិត្តិយ ។

*៧) **មហាបេសការសិក្ខាបទ** បើគ្រហស្ថមិនជាញាតិ មិន*
បានបវារណា បង្គាប់ឲ្យជាងតម្បាញត្បាញចីវរ ដើម្បីថ្វាយដល់កិក្ខុ
បើកិក្ខុ ទៅកំណត់ ឲ្យគេធ្វើឲ្យល្អឡើង នឹងថែមថ្លៃឲ្យគេ ត្រូវនិស្សគ្គិយ-
បាចិត្តិយ ។

*៨) **អច្ចេកចីវរ**... បើ ១០ ថ្ងៃទៀតទើបដល់ថ្ងៃបវារណា គឺពី*
៦កើត ខែអស្សុជ បើទាយកប្រញាប់នឹងថ្វាយ សំពត់ចំណាំវស្សា កិក្ខុ
ទទួលទុកបាន បើទុកឲ្យកន្ធង់កាលចីវរទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

កាលចីវរនោះដូច្នេះ បើកិក្ខុចាំវស្សាហើយមិនបានក្រាលកឋិន
រាប់ពីថ្ងៃ បវារណាទៅ ១ ខែ អំពី ១ រោច ខែអស្សុជ ដល់ពេញបូណ៌មី

ខែកត្តិក ។ បើបានក្រាលកឋិនរាប់ពីថ្ងៃបវារណាទៅ៥ខែ គឺពី ១ពេចខែ អស្សុជដល់ពេញបូណ៌មីខែផល្គុន ។

៩) សាសង្ក... *ភិក្ខុចាំវស្សាហើយ ហួសពេញបូណ៌មី ខែកត្តិក ហើយនៅក្នុងសេនាសនៈ ព្រៃស្ងាត់ ប្រាថ្នានឹងទុកត្រៃចីវរឯណានីមួយ ក្នុងភូមិ កាលបើមានហេតុ ទុកបានត្រឹម ៦រាត្រី បើទុកឲ្យកន្ទងពី ៦រាត្រីទៅ ត្រូវនិស្សគ្គិយបាចិត្តិយ រៀរលែងតែបានសម្មត ។*

១០) បរិណាមន... *ភិក្ខុដឹងហើយបង្ហោនលាភសង្ឆដែលគេនឹងថ្វាយសង្ឆ មកដើម្បីខ្លួន ត្រូវនិស្សគ្គិយបាចិត្តិយ ។*

ពាក្យថា ត្រូវនិស្សគ្គិយបាចិត្តិយនោះ គប្បីដឹងថាវត្ថុដែលបានមកនោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

ចប់ និស្សគ្គិយបាចិត្តិយ

សុទ្ធិកបាចិត្តិយ ៩២ សិក្ខាបទ

ចែកជា ៩វគ្គ ក្នុង ១វគ្គ មាន ១០សិក្ខាបទ ប្លែកតែវគ្គទី៨ មាន១២ សិក្ខាបទ ។

មុសាវាទវគ្គទី ១

១) មុសាវាទសិក្ខាបទ *ភិក្ខុនិយាយកុហក ត្រូវបាចិត្តិយ ។*

២) **ឱមសវាទ**... *ភិក្ខុជេរភិក្ខុ ត្រូវបាចិត្តិយ ។*

៣) **បេសុញ្ញ**... *ភិក្ខុពោលពាក្យញុះញង់ភិក្ខុ ត្រូវបាចិត្តិយ ។*

៤) **បទសោធម្ម**... *ភិក្ខុប្រដៅធម៌អនុបសម្បន្នដោយបទ បើពោលព្រមគ្នា ត្រូវបាចិត្តិយ ។*

៥) **បឋមសហសេយ្យ**... *ភិក្ខុដេកក្នុងទីប្រក់ចាំងជាមួយ អនុ-បសម្បន្ន កន្ទុង ៣ រាត្រីឡើងទៅ ត្រូវបាចិត្តិយ ។*

៦) **ទុតិយសហសេយ្យ**... *ភិក្ខុដេកក្នុងទីប្រក់ចាំងជាមួយមាតុគ្រាម សូម្បី ១រាត្រី ត្រូវបាចិត្តិយ ។*

៧) **ធម្មទេសនា**... *ភិក្ខុសម្តែងធម៌ដល់មាតុគ្រាម លើសពី៦ម៉ាត់ទៅ ត្រូវបាចិត្តិយ រៀរតែមានបុរសដឹងក្តីនៅផង ។*

៨) **ភូតារោចន**... *ភិក្ខុប្រាប់ឧត្តរិមនុស្សធម៌ ដែលមានពិតដល់អនុបសម្បន្ន ត្រូវបាចិត្តិយ ។*

៩) **ទុដ្ឋុល្លារោចន**... *ភិក្ខុប្រាប់អាបត្តិអាក្រក់គឺសំឃាទិសេសនៃភិក្ខុដទៃដល់អនុបសម្បន្ន ត្រូវបាចិត្តិយ រៀរតែបានសម្មត ។*

១០) **បឋវីខន**... *ភិក្ខុជីកខ្លួនឯង ឬប្រើគេឲ្យជីកនូវផែនដី ត្រូវបាចិត្តិយ ។*

ភូតគាមវគ្គទី ២

១) **ភូតគាមសិក្ខាបទ** *កិក្ខុធ្វើភូតគាមគឺ ដើមឈើ ដើមស្មៅ ឲ្យកម្រើកចាកទី ត្រូវបាចិត្តិយ ។*

២) **អញ្ញវាទក**... *កិក្ខុប្រព្រឹត្តអនាចារ សង្ឆសួរហើយ ក្លែងនិយាយបិទបាំងក្តី ស្ងៀមក្តី បើសង្ឆសូត្រប្រកាសកម្មនោះចប់ ត្រូវបាចិត្តិយ ។*

៣) **ឧជ្ឈាបន**... *កិក្ខុលើកទោសកិក្ខុដទៃ ដែលសង្ឆសន្ទុត ឲ្យជាអ្នកធ្វើការសង្ឆ បើកិក្ខុនោះធ្វើដោយធម៌ ត្រូវបាចិត្តិយ ។*

៤) **បឋមសេនាសន**... *កិក្ខុយកគ្រែ, តាំង, ពួក, កៅអី, របស់សង្ឆទៅប្រើប្រាស់ក្នុងទីវាល កាលចៀសចេញទៅ មិនរើទុកខ្ជួនឯង មិនប្រើអ្នកដទៃឲ្យទុកក្តី មិនផ្តាំក្តី ត្រូវបាចិត្តិយ ។*

៥) **ឧតិយសេនាសន**... *កិក្ខុយកទីដំណេករបស់សង្ឆ ទៅក្រាលដេកក្នុងកុដិសង្ឆហើយ កាលចៀសចេញទៅមិនរើទុកខ្ជួនឯងក្តី មិនប្រើអ្នកដទៃឲ្យទុកក្តី មិនផ្តាំក្តី ត្រូវបាចិត្តិយ ។*

៦) **អនូបខ្ជ**... *កិក្ខុដឹងថា កុដិនេះមានកិក្ខុនៅមុនហើយ ក្លែងទៅដេកបៀតច្រៀត បំណងនឹងឲ្យគេចង្អៀតចង្អល់ ហើយនឹងចៀសចេញទៅ ត្រូវបាចិត្តិយ ។*

៧) និកឌ្ឍន... *កិក្ខុក្រោធ នឹងកិក្ខុដទៃ ទង់ទាញបណ្តោញ ចាកកុដិសង្ឆ ត្រូវបាចិត្តិយ ។*

៨) វហាសកុដិ... *កិក្ខុអង្គុយក្តី, ដេកក្តី, លើគ្រែក្តី, លើតាំងក្តី ដែលមានជើងមិនបានដោតឲ្យមាំ គេតម្កល់ទុកលើធ្នឹម លើរត ដែលគេ ទុកដាក់ក្នុងកុដិសង្ឆ ត្រូវបាចិត្តិយ ។*

៩) មហល្ហក... *កិក្ខុយកដីឬកំបោរ បូកដំបូលកុដិ គប្បីបូកបាន ត្រឹម ៣ជាន់ បើបូកឲ្យលើសជាងនោះទៅ ត្រូវបាចិត្តិយ ។*

១០) សប្បាណក... *កិក្ខុដឹងថាទឹកមានតួសត្វហើយ យក ស្រោចឯងក្តី, ប្រើគេឲ្យស្រោចក្តី នូវស្មៅ នូវដី ត្រូវបាចិត្តិយ ។*

ឱវាទវគ្គទី ៣

១) ឱវាទសិក្ខាបទ *កិក្ខុដែលសង្ឆមិនបានសន្មត ទៅប្រដៅ នាងកិក្ខុនី ត្រូវបាចិត្តិយ ។*

២) អដ្ឋង្គត... *សូម្បីកិក្ខុដែលសង្ឆសន្មតហើយ តាំងអំពី ព្រះអាទិត្យលិចហើយ ទៅប្រដៅនាងកិក្ខុនី ត្រូវបាចិត្តិយ ។*

៣) កិក្ខុនូបស្សយ... *កិក្ខុចូលទៅប្រដៅនាងកិក្ខុនី ដល់ទីលំនៅ ត្រូវបាចិត្តិយ រៀរតែនាងកិក្ខុនីឈឺ ។*

៤) អាមិស... *កិក្ខុតិះដៀលកិក្ខុដទៃថា ប្រដៅនាងកិក្ខុនី ព្រោះ ឃើញតែលាភ ត្រូវបាចិត្តិយ ។*

៥) **ចីវរទាន...** *កិក្ខុឲ្យចីវរដល់នាងកិក្ខុនី មិនជាញាតិ ត្រូវបាចិត្តិយ ។*

៦) **ចីវរសិព្វន..** *កិក្ខុដេរឯងក្តី ប្រើគេឲ្យដេរក្តី នូវចីវរនាងកិក្ខុនី មិនជាញាតិ ត្រូវបាចិត្តិយ ។*

៧) **សំវិធាន...** *កិក្ខុបបួលនាងកិក្ខុនីឲ្យដើរផ្លូវជាមួយគ្នា សូម្បីអស់លង្វែកភូមិមួយ ត្រូវបាចិត្តិយ រៀងតែផ្លូវស្ងាត់មានអន្តរាយ ។*

៨) **នាវាភិរូហាន...** *កិក្ខុបបួលនាងកិក្ខុនីជិះទូកជាមួយគ្នា ច្រាសទឹកក្តី បណ្តោយទឹកក្តី ត្រូវបាចិត្តិយ រៀងតែធ្ងងទទឹង ។*

៩) **បរិចាចន...** *កិក្ខុដឹងហើយធាន់បិណ្ឌបាត ដែលនាងកិក្ខុនីឲ្យគ្រហស្ថគេថ្វាយ ត្រូវបាចិត្តិយ រៀងលែងតែគ្រហស្ថគេប្រារព្ធទុកជាមុន ។*

១០) **រហោនិសជ្ជ...** *កិក្ខុអង្គុយក្នុងទីកំបាំងនឹងនាងកិក្ខុនីតែមួយនឹងមួយ ត្រូវបាចិត្តិយ ។*

ភោជនវគ្គទី ៤

១) **អាសនបិណ្ឌាសិក្ខាបទ** *កិក្ខុមិនឈឺទៅធាន់អាហារក្នុងរោងទាន ដែលគេមិនថ្វាយចំពោះបុគ្គល ធាន់បានតែម្តង បើធាន់ឲ្យលើសទៅ ត្រូវបាចិត្តិយ ។*

២) ឥណភោជន... *បើទាយកគេមកនិមន្តចេញឈ្មោះ ភោជន ទាំង៥ គឺ* **ឱទនោ** *បាយ,* **ឥុម្មាសោ** *នំស្រស់,* **សត្តុ** *នំក្រៀម,* **មច្ឆោ** *ត្រី,* **មំសំ** *សាច់ឯណានីមួយ បើទទួលរបស់នោះមកធាន់ព្រមគ្នា ពី ៤ អង្គឡើងទៅត្រូវបាចិត្តិយ រៀរលែងតែមានសម័យ ៧ប្រការ គឺ* **ភិលានសមយ** *រវលាឈឺ ១,* **ចីវរទានសមយ** *រវលាថ្វាយចីវរ ១,* **ចីវរការសមយ** *រវលាធ្វើចីវរ ១,* **អទ្ធានគមនសមយ** *រវលាដើរផ្លូវឆ្ងាយ ១,* **នាវាភិរូហនសមយ** *រវលាជិះទូក ១,* **មហាសមយ** *រវលាភិក្ខុនៅច្រើនគ្នា ១,* **សមណភត្តសមយ** *រវលាភត្តនោះជារបស់សមណ: ១ ។*

៣) បរម្បរភោជន... *ភិក្ខុទទួលនិមន្តន៍ទាយកដោយភោជន ទាំង ៥ ឯណានីមួយមុនហើយ ទៅធាន់ភោជនទាយកអ្នកនិមន្តក្រោយ ត្រូវបាចិត្តិយ រៀរតែមានសម័យ ៣ ប្រការ គឺ* **ភិលានសមយ ១,** **ចីវរទានសមយ ១,** **ចីវរការសមយ ១ ។**

៤) ការណមាតា... *ភិក្ខុចូលទៅបិណ្ឌបាតក្នុងភូមិ ទាយកគេយកនំមកប្រគេនជាច្រើន ទទួលបានត្រឹមតែ ៣បាត្រ បើទទួលឲ្យលើសជាងនោះ ត្រូវបាចិត្តិយ របស់ដែលទទួលមកច្រើននោះ គប្បីចែកឲ្យភិក្ខុដទៃ ។*

៥) បឋមបវារណា... *កិក្ខុកំពុងធាន់ មានទាយកនាំ ភោជនទាំង ៥ ឯណានីមួយ ចូលមកប្រគេន កិក្ខុហាមហើយក្រោកចាកទីនោះ ហើយធាន់ខាទនីយភោជនីយាហារ ដែលមិនជាសំណល់កិក្ខុឈឺ ឬមិនបានធ្វើវិនយកម្ម ត្រូវបាចិត្តិយ ។*

៦) ឧតិយបវារណា... *កិក្ខុដឹងថា កិក្ខុដទៃហាមភោជនហើយ គិតនឹងលើកទោសក្ងែងយកខាទនីយភោជនីយាហារ ដែលជាសំណល់ កិក្ខុឈឺ ទៅឲ្យកិក្ខុនោះធាន់ កាលកិក្ខុនោះធាន់ហើយ ត្រូវបាចិត្តិយ ។*

៧) វិកាលភោជន... *កិក្ខុធាន់អាហារក្នុងវេលាវិកាល គឺតាំងពីព្រះអាទិត្យជ្រេទៅហើយ ដរាបដល់អរុណរះថ្មី ត្រូវបាចិត្តិយ ។*

៨) សន្និធិការកសិក្ខាបឧ *កិក្ខុធាន់អាហារដែលទទួលប្រគេនទុកឲ្យកន្ងងរាត្រី ត្រូវបាចិត្តិយ ។*

៩) បណីតភោជន... *កិក្ខុសូមភោជនដ៏ប្រណីតបញ្ចង់ គឺបាយ លាយដោយរបស់ ៩យ៉ាងគឺ សប្បិ, នវនីត, ប្រេង, ទឹកឃ្មុំ, ស្ករអំពៅ, ត្រី, សាច់, ទឹកដោះស្រស់ , ទឹកដោះជូរ, អំពីគ្រហស្ថមិនជាញាតិមិនបានបវារណាមកធាន់ ត្រូវបាចិត្តិយ ។*

១០) ឧន្ទចោន... *កិក្ខុធាន់អាហារ ដែលគេមិនទាន់ប្រគេន លេបឲ្យកន្ងងបំពង់កចូលទៅ ត្រូវបាចិត្តិយ រៀរតែទឹកនិងឈើស្ងន់ ។*

អចេលកវគ្គទី ៥

១) **អចេលកសិក្ខាបទ** *ភិក្ខុឲ្យខាទនីយភោជនីយាហារ ដល់អ្នកបួសក្រៅសាសនាដោយដៃខ្លួនឯង ត្រូវបាចិត្តិយ ។*

២) **ឧយ្យោជន...** *ភិក្ខុបបួលភិក្ខុដទៃទៅបិណ្ឌបាតជាមួយគ្នា បំណងនឹងប្រព្រឹត្តអនាចារ បណ្តេញឲ្យភិក្ខុនោះត្រឡប់មកវិញ ត្រូវបាចិត្តិយ ។*

៣) **សភោជន...** *ភិក្ខុចូលទៅអង្គុយក្នុងផ្ទះដែលមានតែស្វាមី និងភរិយានៅជាមួយគ្នាប៉ុណ្ណោះ ត្រូវបាចិត្តិយ ។*

៤) **បឋមរហោនិសជ្ជ...** *ភិក្ខុម្នាក់ឯងអង្គុយក្នុងទីកំបាំងភ្នែក ជាមួយនឹងស្ត្រី ត្រូវបាចិត្តិយ ។*

៥) **ឧតិយរហោនិសជ្ជ...** *ភិក្ខុអង្គុយក្នុងទីកំបាំងត្រចៀក ជាមួយនឹងស្ត្រី តែមួយនឹងមួយ ត្រូវបាចិត្តិយ ។*

៦) **ចារិត្ត...** *ភិក្ខុទទួលនិមន្តន៍ដោយភោជនទាំង ៥ ហើយ នឹងទៅក្នុងទីដទៃចាកទីនិមន្តនោះ ក្នុងវេលាបុរេភត្តមុនធាន់ក្តី បច្ឆាភត្ត ក្រោយធាន់ក្តី គប្បីលាភិក្ខុដែលមាននៅក្នុងអាវាសជាមុន ទើបទៅបាន បើមិនលាហើយទៅ ត្រូវបាចិត្តិយ រឿងតែមានសម័យ ២ គឺ* **ចីវរទានសមយ ១ ចីវរការសមយ ១** *។*

៧) មហាគាម... *បើទាយកគេបវារណា ដោយបច្ច័យ ៤ កំណត់ត្រឹម ៤ខែ គប្បីសូមគេបានត្រឹមកំណត់ប៉ុណ្ណោះ បើសូមឲ្យលើសពីកំណត់នោះទៅ ត្រូវបាចិត្តិយ រៀងតែគេបវារណាទៀត ឬបវារណាជានិច្ច ។*

៨) ឧយ្យុត្ត... *ភិក្ខុទៅមើលកងទ័ព ដែលគេលើកទៅច្បាំងគ្នា ត្រូវបាចិត្តិយ រៀងតែមានហេតុនឹងគប្បីទៅ ។*

៩) សេនាវាស... *បើមានហេតុគួរនឹងទៅ គប្បីទៅនៅបានកំណត់ត្រឹម ៣ថ្ងៃ បើនៅឲ្យលើសកំណត់នោះទៅ ត្រូវបាចិត្តិយ ។*

១០) ឧយ្យោធិក... *វេលាដែលនៅក្នុងកងទ័ពតាមកំណត់នោះ បើទៅមើលគេច្បាំងគ្នាក្តី មើលគេត្រួតពលក្តី មើលគេចាត់កងទ័ពក្តី មើលកងសេនាដែលចាត់ជាកងហើយក្តី ត្រូវបាចិត្តិយ ។*

សុរាបានវគ្គ ទី៦

១) សុរាចានសិក្ខាបទ *ភិក្ខុក្រេបផឹកទឹកស្រវឹង ត្រូវបាចិត្តិយ ។*

២) អង្គុលិបតោទក... *ភិក្ខុចាក់ប្រទ្បែងភិក្ខុផងគ្នា ត្រូវបាចិត្តិយ ។*

៣) ហស្សធម្ម... *កិក្ខុចុះលេងទឹកជម្រៅ ពីត្រឹមក្នែកគោរឡើងទៅ ត្រូវបាចិត្តិយ ។*

៤) អនាទរិយ... *កិក្ខុមិនអើពើក្នុងធម៌វិន័យ ដែលឧបសម្បន្ន ដាស់តឿន ត្រូវបាចិត្តិយ ។*

៥) ភឹសាបន... *កិក្ខុបន្ទាចកិក្ខុឲ្យខ្ទាច ត្រូវបាចិត្តិយ ។*

៦) ជោតិសមាទហន... *កិក្ខុមិនឈឺបង្ការត់ភ្ជើងដោយខ្ជូនឯងក្តី ឲ្យអ្នកដទៃបង្ការត់ក្តី ដើម្បីអាំង ត្រូវបាចិត្តិយ បង្ការត់ដើម្បីហេតុដទៃ មិនត្រូវអាបត្តិ ។*

៧) នហាន... *កិក្ខុនៅក្នុងមជ្ឈិមប្រទេស ១៥ថ្ងៃ ទើបងូត ទឹកបានម្តង បើមិនទាន់ដល់ ១៥ថ្ងៃហើយងូត ត្រូវបាចិត្តិយ រៀរតែមានសម័យ ៦ ប្រការគឺ៖* **ឧណ្ហសមយ** *រវលាក្តៅ ១,* **បរិឡាហសមយ** *រវលាក្រហល់ក្រហាយ ១,* **កិលានសមយ** *រវលាឈឺ ១,* **កម្មសមយ** *រវលាធ្វើការងារ ១,* **អទ្ធានគមនសមយ** *រវលាដើរផ្ទូវឆ្ងាយ ១,* **វាតវុដ្ឋិសមយ** *រវលាភ្ជៀងព្យុះ ១ ។*

បើក្នុងបច្ចន្តប្រទេសដូចប្រទេសយើងសព្វថ្ងៃនេះ ងូតបានជានិច្ច ។

៨) ឧព្ធណ្ណការណា... *កិក្ខុបានចីវរថ្មីមក គប្បីពិន្ទុដោយពណ៌ ៣យ៉ាងគឺពណ៌ខៀវក្តី ពណ៌ភក់ក្តី ពណ៌ខ្មៅក្តី ដោយពណ៌*

ឯណានីមួយមុនហើយ ទើបប្រើប្រាស់បាន បើមិនធ្វើពិន្ទុ ហើយប្រើប្រាស់ ត្រូវបាចិត្តិយ ។

*៩) **វិកប្បន**... ភិក្ខុវិកប្បចីវរ ដល់សហធម្មិកទាំង ៥គឺ ភិក្ខុ, ភិក្ខុនី, សិក្ខមានា, សាមណេរ, សាមណេរី, ឯណានីមួយហើយ មិនបានឲ្យអ្នកនោះដកវិកប្បជាមុន ប្រើប្រាស់ ត្រូវបាចិត្តិយ ។*

*១០) **អបនិធាន**... ភិក្ខុលាក់ឯង ឬប្រើគេឲ្យលាក់ នូវបរិក្ខារ គឺបាត្រ, ចីវរ, សំពត់និសីទន:, បំពង់ម្ជុល, វត្ថពន្ធចង្កេះ ឯណានីមួយរបស់ភិក្ខុដទៃ សូម្បីប្រាថ្នានឹងសើចលេង ត្រូវបាចិត្តិយ ។*

សប្បាណកវគ្គទី ៧

*១) **សញ្ចិចូចាណសិក្ខាបទ** ភិក្ខុក្ងែងសម្ងាប់សត្វតិរច្ឆាន ត្រូវបាចិត្តិយ ។*

*២) **សប្បាណក**... ភិក្ខុដឹងថាទឹកមានតួសត្វ ប្រើប្រាស់ទឹកនោះ ត្រូវបាចិត្តិយ ។*

*៣) **ឧក្កោដន**... ភិក្ខុដឹងថាអធិករណ៍នេះ សង្ឃធ្វើហើយ ដោយធម៌ ត្រឡប់រើធ្វើជាថ្មីទៀត ត្រូវបាចិត្តិយ ។*

៤) ឧជ្ជុលុបជិច្ឆាឧន... *កិក្ខុដឹងហើយកៃ្ងងជួយបិទបាំងអាបត្តិ អាក្រក់កិក្ខុដទៃ ត្រូវបាចិត្តិយ ។*

៥) ឱនវីសតិវស្ស... *កិក្ខុដឹងហើយធ្វើជាឧបជ្ឌាយ៍ ឲ្យឧបសម្ប័ទ ដល់កុលបុត្រមានអាយុខ្ទះពី ២០ឆ្នាំ ត្រូវបាចិត្តិយ ។*

៦) ថេយ្យសត្ថសិក្ខាបទ *កិក្ខុដឹងហើយបបួលឈ្មួញ ដែលបិទ បាំងគយ ដើរផ្ទូវជាមួយគ្នា សូម្បីអស់លង្វែកភូមិមួយ ត្រូវបាចិត្តិយ ។*

៧) សំវិធាន... *កិក្ខុបបួលមាតុគ្រាមដើរផ្ទូវជាមួយគ្នា សូម្បីអស់ លង្វែកភូមិមួយ ត្រូវបាចិត្តិយ ។*

៨) អវិដ្ឋ... *កិក្ខុពោលពាក្យបង្ការ៉ាច់ បង្ខិន ព្រះធម៌ទេសនា ព្រះពុទ្ធអង្គ កិក្ខុដទៃយាត់មិនស្តាប់ សង្ឆសូត្រសមនុកាសនកម្ម ចប់ ៣ដង ត្រូវបាចិត្តិយ ។*

៩) ឧក្ខិត្តសម្ភោគ... *កិក្ខុសេពគប់នឹងកិក្ខុដូច្នោះគឺ រួមបរិភោគក្តី, រួមឧបោសថសង្ឆកម្មក្តី, រួមដំណេកក្តី, ត្រូវបាចិត្តិយ ។*

១០) កណ្ឌក... *កិក្ខុប្រលោមលួងលោមសាមណេរដែល កិក្ខុដទៃ ឲ្យវិនាសហើយ ព្រោះទោសដែលពោលបង្ការ៉ាច់ព្រះធម៌ ទេសនាព្រះពុទ្ធអង្គ ឲ្យជាឧបដ្ឌាកក្តី ត្រូវបាចិត្តិយ ។*

សហធម្មិកវគ្គទី ៨

១) **សហធម្មិកសិក្ខាបទ** *កិក្ខុប្រព្រឹត្តអនាចារ កិក្ខុដទៃដាស់តឿន និយាយដៀសរាងថា យើងមិនទាន់បានសួរលោកអ្នកចេះដឹងមុនដរាបណា នឹងមិនសិក្សាក្នុងសិក្ខាបទនេះ ត្រូវបាចិត្តិយ ។*

ធម្មតាកិក្ខុអ្នកសិក្សា នៅមិនទាន់ដឹងរឿងណា គប្បីឲ្យដឹងរឿងនោះ គួរសិក្សា សាកសួរលោកអ្នកចេះ ទើបជាការល្អ ។

២) **វិលេខនសិក្ខាបទ** *កាលកិក្ខុដទៃកំពុងស្វាធ្យាយបាដិមោក្ខ កិក្ខុក្ងែងនិយាយឲ្យកិក្ខុនោះថយឧស្សាហ៍ ត្រូវបាចិត្តិយ ។*

៣) **មោហាន...** *កិក្ខុត្រូវអាបត្តិហើយក្ងែងនិយាយថា ទើបតែនឹងដឹងអម្បាញ់មិញនេះថា ធម៌នេះមានមកក្នុងបាដិមោក្ខ, បើកិក្ខុដទៃដឹងថា កិក្ខុនោះធ្លាប់ដឹងមកមុនហើយ តែក្ងែងនិយាយ កុំឲ្យគេថា គប្បីសូត្រប្រកាស "**មោហាពោបនកម្ម**" ដល់កិក្ខុនោះ កាលសង្ឆ សូត្រកម្មហើយ ក្ងែងនៅធ្វើមិនដឹងទៀត ត្រូវបាចិត្តិយ ។*

៤) **បហារទាន...** *កិក្ខុក្រោធខឹងឲ្យប្រហារកិក្ខុដទៃ ត្រូវបាចិត្តិយ ។*

៥) **តលសត្តិក...** *កិក្ខុក្រោធខឹង លើកកម្ជង់ដៃ នឹងប្រហារកិក្ខុដទៃ ត្រូវបាចិត្តិយ ។*

៦) អមូលក... *ភិក្ខុចោទភិក្ខុដទៃ ដោយអាបត្តិសង្ឆាទិសេស មិនមានមូល ត្រូវបាចិត្តិយ ។*

៧) សញ្ចិច្ច... *ភិក្ខុក្លែងធ្វើសេចក្តីអផ្សុក ឲ្យកើតដល់ភិក្ខុដទៃ ត្រូវបាចិត្តិយ ។*

៨) ឧបស្សុតិ... *កាលភិក្ខុវិវាទគ្នាហើយ ភិក្ខុលបអែបស្តាប់សេចក្តី ដើម្បីនឹងបានដឹងថា គេនិយាយអ្វីដល់ខ្លួន ឬពួកខ្លួន ត្រូវបាចិត្តិយ ។*

៩) កម្មបដិពាហាន... *ភិក្ខុឲ្យឆន្ទ: គឺសេចក្តីព្រមព្រៀងឲ្យធ្វើសង្ឆកម្មជាធម៌ហើយ គ្រាក្រោយត្រឡប់តិះដៀលលោកដែលធ្វើសង្ឆកម្មនោះ ត្រូវបាចិត្តិយ ។*

១០) ឆន្ទំ អឧត្វា គមន... *កាលសង្ឆកំពុងតែប្រជុំគ្នាវិនិច្ឆ័យសេចក្តី ភិក្ខុណានៅក្នុងទីប្រជុំនោះ នឹងចៀសទៅក្នុងខណ: ដែលវិនិច្ឆ័យមិនទាន់សម្រេច មិនឲ្យឆន្ទ:មុន ហើយក្រោកចៀសចេញទៅ ត្រូវបាចិត្តិយ ។*

១១) ឧញ្ជ... *ភិក្ខុព្រមព្រៀងនឹងសង្ឆ ឲ្យចីវរដល់ភិក្ខុដទៃហើយ គ្រាក្រោយត្រឡប់តិះដៀលភិក្ខុដទៃថា ឲ្យព្រោះតែយល់មុខគ្នា ត្រូវបាចិត្តិយ ។*

១២) **បរិណាមន...** *ភិក្ខុដឹងហើយបង្ហោនលាភដែលទាយកគេនឹង ថ្វាយដល់សង្ឆ មកដើម្បីបុគ្គល ត្រូវបាចិត្តិយ ។*

រតនវគ្គទី ៩

១) **អន្តេបុរសិក្ខាបទ** *ភិក្ខុមិនបានអនុញ្ញាតជាមុនសិន ចូលទៅអង្គុយក្នុងលែ្ងងក្រឡាបន្ទំម្ចាស់ផែនដី ដែលគង់នៅជាមួយនឹងព្រះមហេសី ត្រូវបាចិត្តិយ ។*

២) **រតន...** *ភិក្ខុរើសខ្លួនឯង ឬប្រើគេឲ្យរើស នូវរបស់គ្រហស្ថដែលធ្លាក់នៅខាងក្រៅអាវាស ត្រូវបាចិត្តិយ រៀងតែធ្លាក់ក្នុងអាវាស ឬទីលំនៅរបស់ខ្លួន គប្បីរើសទុកឲ្យម្ចាស់គេ បើមិនរើស ត្រូវទុក្កដ ។*

៣) **វិកាលតាមប្ឆវេសន...** *ភិក្ខុមិនបានលាភិក្ខុដែលមាននៅក្នុងអាវាស ហើយចូលទៅកាន់ភូមិ ក្នុងវេលាវិកាល ត្រូវបាចិត្តិយ រៀងតែមានកិច្ចប្រញាប់ ។*

៤) **សូចិឃរសិក្ខាបទ** *ភិក្ខុធ្វើបំពង់ម្ជុល ដោយធ្នឹងក្តី ដោយក្ងុកក្តី, ដោយស្នែងក្តី, ត្រូវកេទនកបាចិត្តិយ គប្បីទម្លាយមុនហើយ ទើបសម្តែងអាបត្តិធ្លាក់ ។*

៥) **មញ្ច...** *ភិក្ខុធ្វើគ្រែ ឬតាំង គប្បីធ្វើឲ្យមានជើងខ្ពស់ ប្រមាណ ៨ធ្នាប់ព្រះសុគត រៀងតែមេគ្រែ បើធ្វើឲ្យលើសកំណត់នេះ ត្រូវឆេទនកបាចិត្តិយ, គប្បីកាត់ឲ្យបានប្រមាណមុនហើយ ទើបសម្តែង*

អាបត្តិធ្លាក់ ។

៦) តូលោនទ្ធ... *ភិក្ខុធ្វើគ្រែឬតាំង ញាត់ដោយគរ សំឡី ត្រូវបាចិត្តិយ, គប្បីរើចេញមុនហើយ ទើបសម្តែងអាបត្តិធ្លាក់ ។*

៧) និសីទន... *ភិក្ខុធ្វើនិសីទន: គឺសំពត់រងអង្គុយ គប្បីធ្វើឲ្យ បានប្រមាណៗនោះ ដោយប្រវែង ២ចំអាមព្រះសុគត, ទទឹង ១ចំអាមកន្ទុះ ជាយ ១ចំអាម, បើធ្វើឲ្យលើសប្រមាណនោះ ត្រូវឆេទនកបាចិត្តិយ ។*

៨) កណ្ឌុបដិច្ឆាទិ... *ភិក្ខុធ្វើសំពត់បិទបូស គប្បីធ្វើឲ្យបាន ប្រមាណៗ នោះ ដោយប្រវែង ៤ចំអាមព្រះសុគត, ទទឹង ២ចំអាម, បើធ្វើឲ្យលើសប្រមាណនោះ ត្រូវឆេទនកបាចិត្តិយ ។*

៩) វស្សិកសាដក... *ភិក្ខុធ្វើសំពត់ងូតទឹកភ្លៀង គប្បីធ្វើឲ្យបាន ប្រមាណៗនោះ ដោយប្រវែង ៦ចំអាមព្រះសុគត, ទទឹង ២ចំអាមកន្ទុះ បើធ្វើឲ្យលើសប្រមាណនោះ ត្រូវឆេទនកបាចិត្តិយ ។*

១០) ឆន... *ភិក្ខុធ្វើចីវរប្រមាណប៉ុនចីវរព្រះសុគតក្តី លើសជាង នោះក្តី ត្រូវឆេទនកបាចិត្តិយ ។ ប្រមាណចីវរព្រះសុគតនោះ ដោយប្រវែង ៩ចំអាម ទទឹង ៦ចំអាមព្រះសុគត ។*

ចប់សុទ្ធិកបាចិត្តិយ

បាដិទេសនីយ ៤

១) **សហត្ថបដិគ្គហណសិក្ខាបទ** *ភិក្ខុទទួលខាទនីយ-*
ភោជនីយាហារ អំពីដៃនាងភិក្ខុនីមិនជាញាតិ ដោយដៃខ្លួនឯងមក
បរិភោគ ត្រូវបាដិទេសនីយ: ។

២) **អបសាទន**... *ភិក្ខុកំពុងធាន់ក្នុងត្រកូលដែលគេនិមន្ត ហើយ*
មានភិក្ខុនី មកបង្គាប់ទាយកឲ្យយកវត្ថុនោះវត្ថុនេះ មកប្រគេន
ភិក្ខុនោះគប្បីបណ្តេញនាងភិក្ខុនីនោះឲ្យថយចេញទៅ បើមិនដេញ
ត្រូវបាដិទេសនីយ: ។

៣) **សេខសម្មត**... *ភិក្ខុមិនឈឺ ទាយកគេមិនបាននិមន្តទទួល*
ខាទនីយភោជនីយាហារ ក្នុងត្រកូលដែលសង្ឃសន្មត ជាសេខបុគ្គល
មកធាន់ ត្រូវបាដិទេសនីយ: ។

៤) **អារញ្ញិក**... *ភិក្ខុនៅក្នុងសេនាសន:ព្រៃស្ងាត់ ដែលប្រកប*
ដោយអន្តរាយ មិនឈឺទទួលខាទនីយភោជនីយាហារ ដែលទាយក
មិនបានផ្ទៀងជាមុន ដោយដៃខ្លួនមកធាន់ ត្រូវបាដិទេសនីយ: ។

ចប់ បាដិទេសនីយ:

សេខិយវត្ត

វត្តដែលភិក្ខុគប្បីសិក្សាហៅថា «សេខិយវត្ត» ។ នោះ ចាត់ជា ៤ ពួក, ពួកទី ១ ហៅថា **សារូប**, *ពួកទី២ ហៅថា* **ភោជនបដិសំយុត្ត**, *ពួកទី ៣ ហៅថា* **ធម្មទេសនាបដិសំយុត្ត** *ពួកទី ៤ ហៅថា* **បកិណ្ណកៈ** ។

សារូបទី ១ មាន ២៦

១, ២ ភិក្ខុគប្បីសិក្សាថា យើងនឹងស្ងៀក ដណ្តប់ឲ្យបរិមណ្ឌល ។

៣, ៤ ភិក្ខុគប្បីសិក្សាថា យើងនឹងបិទកាយឲ្យប្រពៃ ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

៥, ៦ ភិក្ខុគប្បីសិក្សាថា យើងនឹងសង្រួមឲ្យប្រពៃ ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

៧, ៨ ភិក្ខុគប្បីសិក្សាថា យើងនឹងដាក់ភ្នែកចុះ ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

៩, ១០ ភិក្ខុគប្បីសិក្សាថា យើងនឹងមិនសើយចីវរ ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

១១
១២ } ភិក្ខុគប្បីសិក្សាថា យើងនឹងមិនសើចខ្លាំង ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

១៣
១៤ } ភិក្ខុគប្បីសិក្សាថា យើងនឹងមិននិយាយ សំឡេងខ្លាំង ដើរ អង្គុយក្នុងលង្វែកផ្ទះ ។

១៥
១៦ } ភិក្ខុគប្បីសិក្សាថា យើងនឹងមិនឃ្លាងកាយ ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

១៧
១៨ } ភិក្ខុគប្បីសិក្សាថា យើងនឹងមិនបង់ពោយ ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

១៩
២០ } ភិក្ខុគប្បីសិក្សាថា យើងនឹងមិនដោកក្បាល ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

២១
២២ } ភិក្ខុគប្បីសិក្សាថា យើងនឹងមិនច្រត់ចង្កេះ ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

២៣
២៤ } ភិក្ខុគប្បីសិក្សាថា យើងនឹងមិនទទួរក្បាល ដើរ អង្គុយ ក្នុងលង្វែកផ្ទះ ។

២៥) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនដើរចំអើតជើង ក្នុងលង្វែកផ្ទះ ។

២៦) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនអង្គុយ ត្រចោមក្បាលជង្គង់ក្នុងលង្វែកផ្ទះ ។

ភោជនបដិសំយុត្តទី ២ មាន ៣០

១) ភិក្ខុគប្បីសិក្សាថា យើងគប្បីទទួលបិណ្ឌបាតដោយគោរព ។

២) ភិក្ខុគប្បីសិក្សាថា កាលទទួលបិណ្ឌបាត យើងសម្គាល់តែក្នុងបាត្រ ។

៣) ភិក្ខុគប្បីសិក្សាថា យើងទទួលសម្ង ឲ្យល្មមនឹងបាយ ។

៤) ភិក្ខុគប្បីសិក្សាថា យើងទទួលបិណ្ឌបាតឲ្យស្មើមាត់បាត្រ ។

៥) ភិក្ខុគប្បីសិក្សាថា យើងនឹងធាន់បិណ្ឌបាតដោយគោរព ។

៦) ភិក្ខុគប្បីសិក្សាថា កាលធាន់បិណ្ឌបាត យើងនឹងសម្គាល់តែក្នុងបាត្រ ។

៧) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនចូកបាយឲ្យខ្ជងធាន់ ។

៨) ភិក្ខុគប្បីសិក្សាថា យើងនឹងធាន់សម្ងឲ្យល្មមនឹងបាយ ។

៩) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់សង្កត់ចុះត្រង់កណ្ដាល ។

១០) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនយកបាយបិទសម្ង និងអន្ទក់ព្រោះចង់បានច្រើន ។

១១) ភិក្ខុគប្បីសិក្សាថា យើងមិនឈឺនឹងមិនសូមសម្ង និងបាយដើម្បីប្រយោជន៍ខ្លួនមកធាន់ ។

១២) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនមើលបាត្រភិក្ខុដទៃ ព្រោះគិតនឹងលើកទោស ។

១៣) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធ្វើចំណុកបាយឲ្យធំពេក ។

១៤) ភិក្ខុគប្បីសិក្សាថា យើងនឹងធ្វើចំណុកបាយឲ្យបរិមណ្ឌល ។

១៥) ភិក្ខុគប្បីសិក្សាថា កាលចំណុកបាយមិនទាន់ដល់មាត់ យើងនឹងមិនហាមាត់ទុកមុន ។

១៦) ភិក្ខុគប្បីសិក្សាថា កាលកំពុងតែធាន់ យើងនឹងមិនយកម្រាមដៃទាំងអស់ដាក់ក្នុងមាត់ ។

១៧) ភិក្ខុគប្បីសិក្សាថា កាលចំណុកបាយនៅក្នុងមាត់ យើងនឹងមិននិយាយ ។

១៨) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនបោះចំណុកបាយធាន់ ។

១៩) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់ខាំកាត់ចំណុកបាយ ។

២០) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់ធ្វើថ្នក់ថ្ពាល់ឲ្យទូញ ។

២១) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់រលាស់ដៃ ។

២២) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់ ធ្វើគ្រាប់បាយឲ្យធ្លាក់រោយរាយ ។

២៣) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់លៀនអណ្តាត ។

២៤) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់ធ្វើសំឡេងពុផ្ទប់ ៗ ។

២៥) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់ធ្វើសំឡេងឮគ្រូកៗ ។

២៦) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់លិទ្ធដៃ ។

២៧) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់កោសបាត្រ ។

២៨) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនធាន់លិទ្ធបបូរមាត់ ។

២៩) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនយកដៃប្រឡាក់អាមិស ចាប់ភាជនៈទឹក ។

៣០) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនចាក់ទឹកលាងបាត្រ ទាំងគ្រាប់ចាយក្នុងលង្វែកផ្ទះ ។

ធម្មទេសនាបដិសំយុត្តទី ៣ មាន ១៦

១) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនសម្តែងធម៌ដល់មនុស្សមិនឈឺ មានច័ត្រក្នុងដៃ ។

២) ---- ---- មានដំបងក្នុងដៃ ។

៣) ---- ---- មានសស្ត្រាក្នុងដៃ ។

៤) ---- ---- មានអាវុធក្នុងដៃ ។

៥) ---- ---- ពាក់ស្បែកជើងឈើ ។

៦) ---- ---- ពាក់ស្បែកជើងស្បែក ។

៧) ---- ---- នៅលើយាន ។

៨) ---- ---- ដេក ។

៩) ភិក្ខុគប្បីសិក្សាថា យើងនឹងមិនសម្តែងធម៌ដល់មនុស្សមិនឈឺ អង្គុយត្រចោមក្បាលជង្គង់ ។

១០) ---- ---- ជូតក្បាល ។

១១) ---- ---- ទទួរក្បាល ។

១២) -------- យើងអង្គុយលើផែនដី នឹងមិនសម្តែងធម៌ដល់មនុស្សមិនឈឺអង្គុយលើអាសនៈ ។

១៣) -------- យើងអង្គុយលើអាសនៈទាប នឹងមិនសម្តែងធម៌ដល់មនុស្សមិនឈឺ អង្គុយលើអាសនៈខ្ពស់ ។

១៤) -------- យើងឈរនឹងមិនសម្តែងធម៌ ដល់មនុស្សមិនឈឺអង្គុយ ។

១៥) -------- យើងដើរខាងក្រោយ នឹងមិនសម្តែងធម៌ដល់មនុស្សមិនឈឺដើរខាងមុខ ។

១៦) -------- យើងដើរក្រៅផ្លូវ នឹងមិនសម្តែងធម៌ដល់មនុស្សមិនឈឺដើរក្នុងផ្លូវ ។

បកិណ្ណកៈទី ៤ មាន ៣

១) ភិក្ខុគប្បីសិក្សាថា យើងមិនឈឺមិនឈរបន្ទោឧច្ចារបស្សាវៈ ។

២) ភិក្ខុគប្បីសិក្សាថា យើងមិនឈឺមិនបន្ទោឧច្ចារបស្សាវៈ, ស្តោះទឹកមាត់ដាក់លើស្មៅស្រស់ ។

៣) ភិក្ខុគប្បីសិក្សាថា យើងមិនឈឺ នឹងមិនបន្ទោឧច្ចារបស្សាវៈ ស្ពោះទឹកមាត់ក្នុងទឹក ។

ចប់ សេខិយវត្ត

អធិករណសមថៈ ៧

ធម៌ជាគ្រឿងរម្ងាប់អធិករណ៍ទាំង ៤ ឈ្មោះថាអធិករណសមថៈ មាន ៧ប្រការគឺ៖

*១) **សម្មុខាវិនយៈ** សេចក្តីរម្ងាប់អធិករណ៍ទាំង ៤នោះក្នុងទីចំពោះមុខសង្ឆ ចំពោះមុខបុគ្គល ចំពោះមុខវត្ថុ ចំពោះមុខធម៌ ។*

*២) **សតិវិនយៈ** សេចក្តីដែលសង្ឆសូត្រប្រកាស ឲ្យសម្មតព្រះអរហន្ត ថាជាអ្នកមានសតិបរិបូណ៌ ដើម្បីមិនឲ្យគេចោទលោកដោយអាបត្តិ ។*

*៣) **អមុឬ្ហវិនយៈ** សេចក្តីដែលសង្ឆសូត្រប្រកាសឲ្យសម្មត ភិក្ខុដែលបាត់ធ្លួតហើយ ដើម្បីមិនឲ្យគេចោទដោយអាបត្តិ ដែលលោកធ្វើក្នុងវេលាធ្លួត ។*

*៤) **បដិញ្ញាតការណៈ** សេចក្តីដែលកាត់អាបត្តិ តាមបដិញ្ញា ។*

*៥) **យេភុយ្យសិកា** សេចក្តីដែលវិនិច្ឆ័យ យកតាមពាក្យមនុស្សច្រើនជាប្រមាណ ។*

๖) តស្សចាបិយសិកា *សេចក្តីដែលធ្វើទោស ដល់អ្នកប្រព្រឹត្ត ខុសនោះ ។*

๗) តិណវត្ថារកៈ *សេចក្តីដែលឲ្យសំរួបសំរួមនូវគ្នានឹងគ្នា មិនបាច់ ជម្រះរករឿងដើម ។*

ចប់អធិករណសមថៈ ៧

សិក្ខាបទក្រៅពីនោះ ដែលលើកឡើងជាឈ្មោះអាបត្តិថុល្ចច្ច័យខ្ចះ ទុក្កដខ្ចះ ទុព្ភាសិតខ្ចះ ជាសិក្ខាបទមិនមានមកក្នុងព្រះបាដិមោក្ខ ។

ចប់សិក្ខាបទ ២២៧

ក្នុងសិក្ខាបទទាំង ២២៧ នោះគឺ

*សំឃាទិសេសសិក្ខាបទ ទី ៥, ៦, ៧ និស្សគ្គិយបាចិត្តិយសិក្ខាបទ ទាំងអស់ រៀរតែសិក្ខាបទទី ៥, ១០ នៃបត្តវគ្គ, សុទ្ធិកបាចិត្តិយ មុសាវាទវគ្គសិក្ខាបទទី ៤,៥,៦,៧,៨, ភូតគាមវគ្គ សិក្ខាបទទី ៤,៥,៨,៩ ឱវាទវគ្គ សិក្ខាបទទី ១,២,៣,៥,៦,៧,៨, ភោជនវគ្គ សិក្ខាបទទី ១,២,៣, ៤,៥,៧,៨,៩,១០, អចេលកវគ្គ សិក្ខាបទទី ១,៦,៧,៨,៩,១០, សុរាបានវគ្គសិក្ខាបទ ទី ១,៦,៧,៨,៩, សប្បាណកវគ្គ សិក្ខាបទ ទី៧ រតនវគ្គទាំង ១០សិក្ខាបទ, បាដិទេសនីយទាំង ៤ សិក្ខាបទ, នេះ ជា "**អចិត្តកៈ**" ។ ពួកសិក្ខាបទក្រៅពីនេះជា "**សចិត្តកៈ**" ។*

*មួយវិញទៀតគប្បីដឹងថា សិក្ខាបទឯណាជា "**សចិត្តកៈ**" សិក្ខាបទនោះជា "**សញ្ញាវិមោក្ខ**" ។ សិក្ខាបទឯណាជា "**អចិត្តកៈ**" សិក្ខាបទនោះជា "**នោសញ្ញាវិមោក្ខ**" ។*

បារាជិកនោះ ភិក្ខុប្រព្រឹត្តកន្ទងហើយនឹងនៅរួមសំវាស ដោយភិក្ខុផងគ្នាមិនបានគឺ ត្រូវវិនាសចាកភេទ ។

សំឃាទិសេស ភិក្ខុប្រព្រឹត្តកន្ទងហើយ គប្បីប្រាប់ដល់ភិក្ខុដទៃ បើបិទទុកប៉ុន្មានថ្ងៃ ត្រូវនៅបរិវាសកម្មប៉ុណ្ណោះ, កាលនៅបរិវាសហើយ ត្រូវប្រព្រឹត្តមានត្តទៀត ៦រាត្រី ហើយសុំអព្ភានកម្មអំពីសង្ឆ យ៉ាងតិចត្រឹម ២០ អង្គឡើងទៅ ។

និស្សគ្គិយបាចិត្តិយនោះ ភិក្ខុប្រព្រឹត្តកន្ទងហើយ ត្រូវលះវត្ថុដែលនិស្សគ្គិយនោះ ដល់ភិក្ខុដទៃជាមុន ទើបសម្តែងអាបត្តិជ្ញាក់ ។

សុទ្ធិកចាចិត្តិយចែកជា ២ ពួក

១ពួកមានវត្ថុនឹងគប្បីទម្ងាយ គប្បីកាត់ជាវិនយកម្ម, គឺកាលភិក្ខុប្រព្រឹត្តកន្ទង ត្រូវទម្ងាយកាត់ឲ្យបានប្រមាណជាមុន ទើបសម្តែងអាបត្តិជ្ញាក់ បាននឹងរតនវគ្គតាំងពីសិក្ខាបទទី ៤ដល់ទី ១០ ។

១ពួកទៀត គ្រាន់តែសម្តែងអាបត្តិប៉ុណ្ណោះក៏បរិសុទ្ធ ។

សេខិយវត្តនោះ កាលភិក្ខុប្រព្រឹត្តកន្ទងគប្បីដឹងថាត្រូវអាបត្តិទុក្កដ ។

បដិបត្តិមុខសិក្ខាបទ: ចប់

ទី៤- អភិសមាចារបព្វ:[1]

ពោលដោយក្បួនទំនៀមទម្ងាប់ ដែលភិក្ខុគួរប្រព្រឹត្ត មានមកក្រៅចាក ព្រះបាដិមោក្ខ ។

*សិក្ខាបទ ក្រៅចាកព្រះបាដិមោក្ខហៅថា "**អភិសមាចារ:**" ។ នោះមាន ២យ៉ាងគឺ **អនុញ្ញាត ១ បញ្ញត្តិ ១** ។*

*ឯ **អនុញ្ញាត**នោះគឺ ដូចទ្រង់អនុញ្ញាតសំពត់វស្សិកសាដក និងអនុញ្ញាតឲ្យភិក្ខុដេកក្នុងវេលាថ្ងៃបិទបាំងទ្វារបង្អួចជាដើម ។*

*ឯ**បញ្ញត្តិ**នោះគឺ ហាមហើយកាត់អាបត្តិផង ដូចនឹងពោលតទៅនេះ ៖*

ទុក្កដ

កុំស្ងៀកដណ្តប់ដូចគ្រហស្ត, កុំទ្រង់សំពត់មានពណ៌ផ្សេងៗ មានពណ៌ខៀវជាដើម, កុំទ្រង់សំពត់មានជាយវែងមិនបានកាត់ នូវសំពត់មានជាយជាផ្ការឈើ, កុំអង្ក្ឌុយត្របោមក្បាលជង្គង់ទាំងសំពត់សង្ឃាដី, កុំនៅប្រាសចាកសំពត់និសីទន:យូរដល់ ៤ខែ, កុំមានតែស្បង់ និងចីពរចូលស្រុក, មិនឈឺកុំទៅដោយយាន, កុំពាក់ស្បែកជើងចូលស្រុក កុំពាក់ស្បែកជើង ២, ៣ ជាន់ ស្បែកជើងស្រោបកែង-ស្រោបខ្នងជើង

---

1) អភិសមាចារបព្វ:នេះ តាមបុព្វសិក្ខាវណ្ណនា រួមចូលក្នុងបព្វ:ទី ៣, បុព្វសិក្ខាសង្ខេបដូចនេះ ។

ស្បែកជើងស្មៅ-ឈើ និងស្បែកជើងពណ៌ផ្សេងៗ ។ កុំលាបផាត់បន្ទំមុខ
បន្ទំខ្ជូន ដោយគ្រឿងលាប គ្រឿងបន្ទំផ្សេងៗ, កុំទ្រង់គ្រឿងប្រដាប់
មានការនិងចិញ្ជៀនជាដើម, កុំឲ្យគេដកសក់ស្ពូវ កាត់សក់ កាត់
ពុកមាត់, មិនឈឺកុំឆ្ងុះមុខ ដោយកញ្ចក់និងភាជន:ដាក់ទឹក, កុំសម្ងឹង
មើលនិមិត្តស្ត្រី, កុំងូតទឹកដុសកាយនឹងដើមឈើ នឹងសសរ នឹងជញ្ជាំង
កុំយកខ្នងនឹងខ្នងដុសគ្នា, មិនឈឺកុំបាំងឆ័ត្រក្រៅឧបចារវត្ត, កុំឲ្យគេគូរ
រូបភាពខ្ជូន ។ កុំដាក់បាត្រលើទីដែលប្រទុសរ៉ាយបាត្រ គឺលើគ្រែ-តាំង
លើទីជង្ហុក ទីមុខម្ខាង លើភ្នែន លើក្រប ។ កុំញ្ជូរបាត្រ
កុំយករបស់សំណល់ដាក់ក្នុងបាត្រ, កុំហាលបាត្រឲ្យយូរពេក, កុំហាល
បាត្រទុកបាត្រទាំងទទឹក ។ កុំអង្គុយលើអាសន:រ៉ែងនឹងស្ត្រី នឹងខ្ទើយ
នឹងឧភតោព្យញ្ជនក: ។ ភិក្ខុមានវស្សាចាស់ខ្ចីជាងគ្នាពី ៣ វស្សាទៅ
កុំអង្គុយលើគ្រែ-តាំងជាមួយគ្នា, កុំដេកអង្គុយលើគ្រែតាំងមានជើងខ្ពស់
ហួសប្រមាណ នូវពូកច្រកគរសំឡី នូវកម្រាលធ្វើដោយរោមសត្វវិចិត្ត
រចនាផ្សេងៗ, កុំកើយខ្នើយធំប្រមាណកន្ទះកាយ, អាសន:គេក្រាលទុក
មិនបានពិចារណាមុនកុំអង្គុយ, កុំដេកលើដំណេកដែលគេរោយផ្ការ,
កុំឃាត់អាសន:ភិក្ខុចាស់, កុំក្រាបសំពះអវន្ទីយបុគ្គល ១០ ចំពូក
គឺភិក្ខុខ្ចីជាង ១ អនុបសម្បន្ន ១ នានាសំវាសដែលជាអធម្មវាទី ១ ភិក្ខុ
ដែលនៅបរិវាស ឬប្រព្រឹត្តមានត្ត និងអញ្ជានកម្មគឺសង្ឆលើកទោស ១

ភិក្ខុដែលអាក្រាតកាយគ្មានសំពត់ស្មៀកដណ្តប់ ១ ភិក្ខុកំពុងចូលស្រុកភូមិ ១ ភិក្ខុដែលនៅក្នុងទីងងឹតមើលគ្នាមិនឃើញ ១ ភិក្ខុដែលដេកលក់ ឬកំពុងធ្វើការ ១ វេលាធាន់អាហារ ១ វេលាបន្ទោបង់ឧច្ចារ-បស្សាវៈ ។ កុំយកសេនាសនៈរបស់សង្ឆទៅប្រើប្រាស់ក្នុងទីដទៃ, ភិក្ខុជាលំដាប់កំពុងធាន់កុំអាលក្រោកចេញ, កុំបណ្តេញភិក្ខុឈឺចាកអាសនៈ, គប្បីឧបដ្ឋាកភិក្ខុឈឺ, ភិក្ខុមានជំងឺបន្ទិចបន្ទួចកុំខាំងខា សេនា-សនៈ, កុំខាំងខាសេនាសនៈអស់កាលទាំងពួង ម្នាក់ឯងកុំខាំងខាសេនាសនៈ ២-៣ដំបន់ ។ កុំទទួល កុំធាន់សាច់ឆៅ, កុំធាន់ឧទ្ទិសមំសៈ គឺត្រីសាច់ដែលគេសម្លាប់ចំពោះសហធម្មិកៈ ។ ព្រះថេរៈមិនបានអនុញ្ញាតមុន កុំសម្តែងធម៌ក្នុងទីប្រជុំសង្ឆ, កុំស្រែកសូត្រសម្តែងធម៌ដោយសំឡេងរលាក់រែង, មិនមានសំពត់ត្រងទឹក កុំដើរផ្ទូវធ្លាយ, ភិក្ខុខ្វីសំពត់ត្រងទឹកកុំកំណាញ់, កុំឲ្យអនាមដ្ឋបិណ្ឌបាត គឺរបស់ដែលមិនទាន់ធាន់ដល់គ្រហស្ថ រៀរលែងតែមាតាបិតា, កុំប្រព្រឹត្តអនាចារមានដើមថា លេងល្បែងក្ដាល់ លេងចត្រង្គ ដុតព្រៃលេង ប្រមៀលថ្មលេង ឡើងដើមឈើ សូត្រធម៌ សម្តែងធម៌កំប្ចែង ក្រងផ្កាឈើ រៀន ឬប្រាប់តិរច្ឆានវិជ្ជាមានស្នេហ៍ ឬ ធ្ងប់ជាដើម ។ កុំប្រព្រឹត្តបាបសមាចារមានដើមថាឲ្យថ្នាំ នាំសំបុត្រ ឲ្យផ្កាឈើ ផ្ទែឈើជាដើម, និងដាំឯង ឬប្រើគេឲ្យដាំ ស្រោចឯង ឬ ប្រើគេឲ្យស្រោច បេះផ្កាឯង ឬប្រើគេ

ឲ្យបេះ ដើម្បីប្រចុបគ្រហស្ថ ។ កុំប្រើអកប្បិយបរិក្ខារផ្សេងៗ គឺតាំងយូ បាត្រ ដើងបាត្រ គ្រឿងចីវរ ក្ដុំ ក្រវិលក្ដុំ ធម្មក្រក វត្ថុពន្ធចង្កេះ ក្រវិលក្បាលវត្ថុពន្ធ ស្រោមសោ មេសោ កាំបិតដែលវិចិត្ររចនាផ្សេងៗ, កុំទ្រង់ផ្ទិតងយ ធ្វើដោយរោមទ្រាយ រោមចាមរី កុំប្រើឈើស្ពន់ដែងជាង ៨ធ្នាប់ ខ្ទីជាង ៦ ធ្នាប់, កុំសន្ធ្ងំ គ្រឿងលោហៈ គ្រឿងសំរិត, កុំបបួលសហធម្មិកក្នុងការមិនគួរ, ធ្វាប់ជាងការកាត់សក់មកពីដើម កុំរក្សាកាំបិតការទុក, កុំចាប់វត្ថុដែលជាអនាមាស គឺស្ត្រី រូបស្ត្រី គ្រឿងប្រដាប់ស្ត្រី តិរច្ឆានញ៉ី គ្រឿងតន្ត្រីយ៍ គ្រឿងសស្ត្រាវុធ, ផ្ទៃឈើជាប់នៅដើម កែវ ១០ប្រការ ស្រូវ៧ប្រការ, កុំចាប់ពាល់ភាជនៈ ដាក់របស់ដែលមិនទាន់ប្រគេន ។ កាលធាន់ក្នុងរោងធាន់ ភិក្ខុចាស់គប្បីតាំងអនុមោទនា, កុំឃាត់អាសនាភិក្ខុកំឡោះ កុំអង្គុយលើសំពត់សង្ឆាដីក្នុងរោងធាន់, កុំខ្ពុរទឹកឲ្យត្រូវសំពត់សង្ឆាដី របស់ភិក្ខុដែលអង្គុយជិត, កុំខ្ចាំងខ្ទប់ភិក្ខុនឹងជាយចីវរ, ទៅបិណ្ឌបាត កុំចូលចេញឲ្យធាប់ពេក កុំឈរឲ្យធ្វាយពេក ជិតពេក, កុំមើលមុខទាយក ។ កាលជម្រះសេនាសនៈ កុំទះគោះជិតភិក្ខុ ជិតវិហារ កុដិ ជិតទឹកធាន់ ទឹកប្រើ, កុំទះគោះក្នុងទីលើខ្យល់ ។ នៅកុដិជាមួយនឹងភិក្ខុចាស់ មិនសូមអនុញ្ញាតមុន កុំស្វាធ្យាយសម្ដែងធម៌ អុជប្រទីប លត់ប្រទីប បើកបិទទ្វារបង្ហួច ។ កុំចូលវច្ចកុដិ (បង្គន់) តាមលំដាប់ថេរៈ, គប្បីចូល ទៅតាមលំដាប់អ្នក

ដែលដល់មុន, កុំចូលចេញវច្ចកុដិឲ្យរួសរាន់ពេក, កុំសើយស្បង់ចូលទៅ, កុំបន្ទោឧច្ចារៈក្រៅប្រហោង, កុំបន្ទោបស្សាវៈក្រៅទ, កុំរមាត់ព្ទអ៊ឹសៗ, កុំទំពាឈើស្ទន់ក្នុងវច្ចកុដិ, កុំស្តោះទឹកមាត់ដាក់ទ, កុំជម្រះនឹងឈើមុតឈើពុក, កុំចោលឈើជម្រះក្នុងរណ្តៅឧច្ចារៈ, កុំលាងព្ទផ្ទប់ៗ, កាលទឹកមានកុំបន្ទោឧច្ចារៈមិនលាង, កុំឲ្យសល់ទឹក ក្នុងភាជនៈជម្រះ, បើវច្ចកុដិប្រឡាក់ឲ្យលាង ឲ្យបោស កុំសើយស្បង់ចេញមក ។ ជ្រលក់ចីវរហាលទឹកស្រក់មិនទាន់ដាច់ កុំជៀសចេញទៅ, កាលចូលទៅអាវាសដទៃ គប្បីដោះស្បែកជើង ដំឡោះតាំងយូ ឃ្ចុំចីវរស្ពាយធៀង, គប្បីប្រតិបត្តិឲ្យប្រពៃក្នុងឧបជ្ឈាយ៍ អាចារ្យ, ទៅធាន់ទីដទៃគប្បីលាឧបជ្ឈាយ៍ អាចារ្យជាមុន ទាំងអស់នេះ ជា "សចិត្តកៈ" ។

ភិក្ខុកុំទៅមើលទៅស្តាប់ច្រៀងរាំភ្ងេងប្រគំផ្សេងៗ, មិនចងវត្ថពន្ធចង្កេះកុំចូលស្រុក, មានបាត្រនៅដៃ កុំច្រានសន្ទឹកទ្វារ, កុំដេកលើគ្រែតាំង កម្រាលជាមួយគ្នា, កុំក្រេបធាន់ក្នុងភាជនៈជាមួយគ្នា, កុំធាន់ខ្ទឹម, កុំស្តោះទឹកមាត់ដាក់ផ្ទៃ ដែលធ្វើបរិកម្ម, ជើងប្រឡាក់ ជើងទទឹកពាក់ស្បែកជើង កុំជាន់ផ្ទៃដែលធ្វើបរិកម្ម នូវកម្រាលរបស់សង្ឆ, កុំផ្អែកនឹងជញ្ជាំងកំពែង ដែលធ្វើបរិកម្ម , បើដេកលើគ្រែតាំងរបស់សង្ឆត្រូវក្រាលសំពត់ជាមុន, កុំទុកសក់ទុកពុកមាត់នៅអោមគាងរោមច្រមុះក្រចកឲ្យវែង, កុំឲ្យគេខាត់ក្រចក, មិនបានមើលមុនកុំចោលសម្រាម

នូវវត្ថុជាសំណល់ជាដើម ក្រៅជញ្ជាំង ក្រៅកំពែង, កុំចោលរបស់ជាដើម នូវឧច្ចារ:ក្នុងស្រែចម្ការគេ, កុំធាន់អកឃ្យិយមំស: គឺសាច់ដំរី សាច់សេះ សាច់ឆ្កែ សាច់ពស់ សាច់រាជសីហ៍ សាច់ខ្វាធំ ខ្វាល្មុង ខ្វារខិន ខ្វាឃ្មុំ ទាំងអស់នេះ ជា "អចិត្តក:" ភិក្ខុប្រព្រឹត្តកន្ទងត្រូវអាបត្តិទុក្កដ ។

ថុល្លច្ច័យ

ភិក្ខុអាក្រាតកាយក្នុងទីមិនគួរ ក្នុងវេលាមិនគួរ ជាវត្តដូចយ៉ាងតិរ្ថីយ៍, កុំស្ទៀកដណ្តាប់ស្ឃូវក្រង សំបកឈើក្រង ផ្ទែឈើក្រង និងសំពត់កម្ពល ធ្វើដោយសក់មនុស្ស ដោយរោមកន្ទុយសត្វស្វាបមៀម ស្បែកខ្វា និងសំពត់ធ្វើដោយធ្មៃ ជាវត្តដូចយ៉ាងតិរ្ថីយ៍ ។ កុំលះ កុំចែករបស់សង្ឃ ដែលជាគរុភណ្ឌ, កុំឲ្យគេធ្វើសត្ថកម្ម និងវត្តិកម្ម គឺពុះចោះនិងរិតក្បាល ឬសដូងដុះ ក្នុង២ជ្នាប់អំពីទីចង្អៀត ទាំងអស់នេះជា សចិត្តក: ។ កុំធាន់សាច់មនុស្សជា "អចិត្តក:" ភិក្ខុប្រព្រឹត្តកន្ទង ត្រូវអាបត្តិថុល្ចច្ច័យ ។

ទុព្ភាសិត

ភិក្ខុក្ងែងចំអកចំអន់អនុបសម្បន្ន ដោយអក្កោសវត្ថុទាំង ១០ មានជាតិជាដើម ត្រូវអាបត្តិ "ទុព្ភាសិត" ។

អភិសមាចារបព្វ: ចប់

ទី៥- កាលិកបញ្ចៈ

ពោលដោយកាលិក របស់ដែលប្រកបដោយកាល វត្ថុដែលនឹងគប្បីលេបចូលទៅតាមកំណត់កាល ហៅថា **កាលិក** *។ នោះ មាន ៤យ៉ាងគឺ ៖*

យាវកាលិក ១ យាមកាលិក ១ សត្តាហកាលិក ១ យាវជីវិក ១ ។

យាវកាលិក

របស់សម្រាប់ធាន់ ដែលមានអាយុត្រឹមកាល គឺពីព្រឹកដល់ថ្ងៃត្រង់, សំដៅយករបស់ដែលបរិភោគជាអាហារបាន និងភោជនទាំង ៥ គឺ **ឱទនោ** *បាយ ១* **កុម្មាសោ** *នំកុម្មាស ដែលធ្វើដោយម្សៅ ឬសណ្តែកលូ ១,* **សត្តុ** *នំក្រៀម ១,* **មច្ឆោ** *ត្រី ១,* **មំសំ** *សាច់ ១ និងខាទនីយៈមានផ្ទៃឈើមើមឈើជាដើម ដែលសម្រេចជាអាហារកិច្ចបាន ហៅថា "***យាវកាលិក***" ។ របស់ជាយាវកាលិក ភិក្ខុទទួលប្រគេនផ្ទាល់ដៃហើយ ទុកធាន់បានពីព្រឹកដល់ថ្ងៃត្រង់ រសៀលហើយធាន់ ត្រូវបាចិត្តិយ ។ បើទទួលប្រគេន ទុកឲ្យកន្ទងរាត្រី ជាសន្និធិធាន់ត្រូវបាចិត្តិយ ។ បើទុកក្នុងអកប្បិយកុដិជាអន្តោវុដ្ឋិ, ចម្ងិនក្នុងអកប្បិយកុដិ ជាអន្តោបក្ខ: ចម្ងិនខ្ជូនឯងជាសាមបក្ខ: ទាំង៣នេះ ជាវត្ថុនៃទុក្កដាបត្តិ ។*

យាមកាលិក

*របស់ដែលគួរក្រេបផឹក សំដៅយក "**អដ្ឋចាន**" ទឹកដែលធ្វើ អំពីផ្លែឈើ ៨យ៉ាងគឺ ៖*

អម្ពចានំ *ទឹកផ្លែស្វាយ ១,* **ជម្ពុចានំ** *ទឹកព្រីង ១,* **ចោចចានំ** *ទឹកចេកមានគ្រាប់ ១,* **មោចចានំ** *ទឹកចេកឥតគ្រាប់ ១,* **មធុកចានំ** *ទឹកផ្លែស្រគំ ១,* **មុទ្ទិកចានំ** *ទឹកផ្លែចន្ទ ឬទំពាំងបាយជូរ ១,* **សាលុកចានំ** *ទឹកក្រអៅឈូក ១,* **ជារុសកចានំ** *ទឹកមាក់ប្រាង ឬសិរមាន់ ១ និងទឹកផ្លែឯទៀតដែលគួរអនុលោមចូលក្នុង "**អដ្ឋចាន**" នេះបានហៅថា "**យាមកាលិក**" ។ របស់ជាយាមកាលិកនេះ ទទួលប្រគេនហើយ ទុកធាន់បានកំណត់ ១ថ្ងៃ ១យប់ ហួសពីនោះ ទៅធាន់ ត្រូវទុក្កដ, (អនុបសម្បន្នធ្វើ... ពុំមែនធ្វើខ្លួនឯងទេ ។*

សត្តាហកាលិក

ភេសជ្ជ: ថ្នាំមានអាយុកាលត្រឹម ៧ថ្ងៃ គឺ៖

សប្បិ *ខ្លាញ់រាវ ១,* **នវនីត:** *ខ្លាញ់ខាប់ ១,* **តេលំ** *ប្រេង ១,* **មធុ** *ទឹកឃ្មុំ ១,* **ផាណិត:** *ស្ករអំពៅ ១, នេះហៅថា "**សត្តាហកាលិក**" ទទួលប្រគេនហើយទុកធាន់ បានកំណត់ ៧ ថ្ងៃ ហួសពីនោះទៅ*

ត្រូវនិស្សគ្គិយបាចិត្តិយ ឆាន់ត្រូវទុក្កដ ។ របស់ដែលប្រើជាថ្នាំ ក្រៅចាក
កាលិក ៣យ៉ាងនោះ ចាត់ជា "**យាវជីវិក**" ។

យាវជីវិក

*ភេសជ្ជ: ថ្នាំដែលកើតអំពីដើមឈើ ស្មៅ ដែលព្រះពុទ្ធអង្គទ្រង់
អនុញ្ញាតទុក ៥ប្រការគឺ ៖*

*ឫស ១, ទឹកអម្ចត់ ១, ស្ទឹក ១, ផ្លែ ១, ជ័រ ១ ថែមអំបិល ១ផង ត្រូវជា
៦ហៅថា "**យាវជីវិក**" ។*

*១) ដែលជាឫសឈើ ហៅថា "**មូលភេសជ្ជ:**" គឺ ៖*

ហលិទ្ទំ *រមៀត,* **សិជ្ជិវេរំ** *ខ្ចី,* **វចំ** *ប្រទាលលំពាន់,* **វចត្តំ** *ប្រស់,* **អតិវិសំ** *រាជឆ្ពឹស,* **កជុកហេហិណី** *រំដេង* **ឧសិរំ** *ស្ស្យវរណ្ណាស* **ភទ្ទមុត្តកំ** *ក្រវាញជ្រូក ។*

*២) ដែលជាទឹកអម្ចត់ ហៅថា "**កសាវភេសជ្ជ:**" គឺ ៖*

និម្ពកសាវោ *ទឹកអម្ចត់ស្ពៅ* **កុជជកសាវោ** *ទឹកអម្ចត់ក្ងែងគង់* **បដោលកសាវោ** *ទឹកអម្ចត់ពោះអំបែងឫពុលឯក* **បក្ករកសាវោ** *ទឹកអម្ចត់បណ្ណូលពេជ* **ឆត្តមាលកសាវោ** *ទឹកអម្ចត់សំបួរទេស ។*

៣) ដែលជាស្លឹក ហៅថា "**បណ្ណាភេសជ្ជ:**" គឺ ៖

និម្ពបណ្ណា ស្លឹកស្ពៅ, **ការ៉ជ**ជ**បណ្ណា** ស្លឹកក្ងែងគង់, **ប**ដោ**ល**ប**ណ្ណា** ស្លឹកពោះអំបែងឬពុលឯក, **ការ**ុ**ល**ិ**ប**ណ្ណា ស្លឹកម្រះព្រៅឬជីរ ស្លឹកគ្រៃ, **ការ**ុ**ប្ប**ាសការ**ប**ណ្ណា ស្លឹកការ៉ុប្ប**ាស** ។

២) ដែលជាផ្លែ ហៅថា "**ផ**ល**ភេ**ស**ជ្ជ:**" គឺ ៖

ពិល**ង្គ**ំ ផ្លែពិលង្គាសា, **ប**ិ**ឍ**ិ ដីប្ញ, **ម**ារ**ិ**ចំ ម្រេច ឬម្ទេស **ហ**ារ**ីត**ី ស្រម៉ **វ**ិ**ភ**ីត**ក**ំ ស្រម៉ពិភេកសារ៉ **អ**ាម**ล**ก ក**ន**្ធ**ត**ម្ព្រៃ **ค**ោ**ช**ฉ**ล**ํ ផ្លែកោដ្ឋ ។

៥) ដែលជាជ័រហៅថា " **ช**ตุ**ภ**ेส**ช**ฺ**:**" គឺ ៖

ហិ**ङ**ฺ**ค**ุ ជ័រដើមហិङ្គុ, **ห**ิ**ङ**ฺ**ช**ตุ ជ័រដែលស្ងួតជាតិហិङ្គុ **ห**ิ**ङ**ฺ**ค**ุ**ส**ิ**ท**ฺ**ธ**ิ**ก**า ជ័រដែលស្ងួតស្លឹកហិङ្គុ, **ต**ก**ฺ**ก ជ័រដែលចេញពីចុងឈើ ត្រួយឈើ, **ต**ก**ฺ**ก**ป**ตฺ**ต**ิ ជ័រដែលចេញពីស្លឹក **ต**ก**ฺ**ก**ป**ณฺ**ณ**ิ ជ័រដែលចេញពីទង ឬជាង **ส**ช**ฺ**ช**ุ**ล**ส**ํ កំញាន ។

៦) អំបិល ដែលកើតអំពីជាតិឯណានីមួយទាំងអស់ ហៅថា "**ล**ោ**ณ**ภ**ภ**ेส**ช**ฺ**:**" ។

ឫស ស្លឹក ផ្លែ ផ្កា ជ័រឈើ ដែលសម្រេចជាអាហារកិច្ចមិនបានក៏អនុលោមចូលក្នុងយ៉ាវជីវិត ។ ទទួលប្រគេនហើយ ទុកធាន់បានដរាបដល់អស់ ។

កាលិកទាំង ៤ នេះ បើចូលច្រឡំគ្នាឯណានីមួយ គប្បីដឹងថាកាលិកដែលមានអាយុខ្វី រមែងទាញកាលិកដែលមានអាយុវែងឲ្យខ្វីតាមខ្លួនផង, ដូចយាវកាលិកទៅលាយច្រឡំនឹងយាមកាលិកជាដើម រមែងទាញកាលិកនោះៗ ឲ្យក្លាយទៅជាយាវកាលិក (បាន) ។

កាលិកបព្វៈ ចប់

ទី៦- ពិន្ទ្វាធិដ្ឋានាទិបព្វៈ[១]

ពោលដោយវិធីមានពិន្ទុ អធិដ្ឋានជាដើម

វិធីពិន្ទុ

ទំនៀមរបស់ភិក្ខុ នឹងប្រើប្រាស់ស្បៀកដណ្តប់ចីវរថ្មី ត្រូវធ្វើពិន្ទុគឺគូសវង់ ត្រង់ជាយឬមុមចីវរនោះ (ជាគ្រឿងសម្គាល់) ដោយវត្ថុពណ៌ខៀវ, ក្រហម, ខ្មៅ បីយ៉ាងនេះ ឯណានីមួយមុនហើយទើបប្រើប្រាស់បាន បើមិនធ្វើដូច្នោះ ប្រើប្រាស់ ត្រូវបាចិត្តិយ ។

*កាលនឹងពិន្ទុ គប្បីកាន់យកនូវខ្មៅដៃជាដើម ហើយបញ្ចេញវាចា ឬតាំងចិត្តក្នុងខណៈ ដែលធ្វើពិន្ទុថា "**ឥមំ ពិន្ទុកប្បំ ករោមិ**" យើងធ្វើ*

---

(១) បុព្វសិក្ខាវណ្ណនាញែកជា ៣គឺ ពិន្ទ្វាធិដ្ឋានាទិបព្វៈ វិជហនាទិបព្វៈ អាបត្តិ-ទេសនានាមាទិបព្វៈ ។ បុព្វសិក្ខាសង្ខេបដូចនេះ ។

កំណត់នេះជាគ្រឿងសម្គាល់ ។ ចីវរមួយធ្វើតែម្តងស្រេច សូម្បីរលុបបាត់ទៅ ក៏មិនត្រូវធ្វើទៀត ។

វិធីពិន្ទុចប់

វិធីអធិដ្ឋាន

ទំនៀមរបស់ភិក្ខុ មានបរិក្ខារចំពូកខ្លះ ដូចបាត្រនិងចីវរ កាលបានហើយ ត្រូវធ្វើពិធីអធិដ្ឋានវិកប្ប (គឺសម្រេចចិត្តថា តាំងទុកបរិក្ខារឈ្មោះនេះ។) ជាមុន, បើពុំបានធ្វើទេ បាត្រ ចីវរនោះទៅជាអតិរេកបាត្រ អតិរេកចីវរ ភិក្ខុទុកបានយ៉ាងយូរត្រឹម ១០ថ្ងៃ ទុកឲ្យកន្ទ្រង ១០ថ្ងៃទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។ បើបានធ្វើអធិដ្ឋានរួចហើយ ទុកប្រើប្រាស់រហូតទៅបាន កុំឲ្យតែនៅប្រាសចាកត្រៃចីវរឲ្យកន្ទ្រងរាត្រី ។

បរិក្ខារដែលគួរអធិដ្ឋាននោះ មាន ១០ យ៉ាង ដូចមានឈ្មោះតាមដែលឲ្យអធិដ្ឋានតទៅនេះ ។

អធិដ្ឋានមាន ២យ៉ាងគឺ អធិដ្ឋានដោយកាយ ១ ដោយវាចា ១ ។ អធិដ្ឋានដោយកាយនោះគឺ យកដៃចាប់អង្អែលបរិក្ខារនោះ។ ហើយតាំងចិត្តនឹកតាមពាក្យអធិដ្ឋានខាងក្រោមនេះ, មិនចាំបញ្ចេញវាចា ។ អធិដ្ឋានដោយវាចានោះគឺ បញ្ចេញវចីភេទដោយសូត្របាលី កាយមិន

ចាប់ អង្ហែលបរិក្ខារក៏បាន ចែកជា ២យ៉ាងគឺ ក្នុងហត្ថបាស ១ ក្រៅហត្ថបាស ១ ។

ក្នុងហត្ថបាស

ត្រូវយកបរិក្ខារមកដាក់ក្នុងអន្ទាក់ដៃ គឺចាប់អង្ហែលឬដាក់ពីមុខក៏បាន រួចសូត្របាលីអធិដ្ឋានទាំងនឹកពាក្យប្រៃ ដូចតទៅនេះ ៖

បើសង្ឆាដីថា "ឥមំ សំឃាដឺ អធិដ្ឋាមិ" យើងតាំងទុកនូវសំពត់នេះជាសង្ឆាដី ។

បើចីវរថា	"ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ"
បើស្បង់ថា	"ឥមំ អន្តរវាសកំ អធិដ្ឋាមិ"
បាត្រថា	"ឥមំ បត្តំ អធិដ្ឋាមិ"
និសីទន៍ថា	"ឥមំ និសីទនំ អធិដ្ឋាមិ"
សំពត់បិទបូស	"ឥមំ កណ្ឌុបដិច្ឆាឌឺ អធិដ្ឋាមិ"
សំពត់ជូតទឹកភ្នែ	"ឥមំ វស្សិកសាដកំ អធិដ្ឋាមិ"
សំពត់ក្រាលដេក	"ឥមំ បច្ចត្ថរណំ អធិដ្ឋាមិ"
សំពត់ជូតមុខ មាត់	"ឥមំ មុខបុញ្ឆនចោឡ អធិដ្ឋាមិ"
សំពត់បរិក្ខារចោឡ:	"ឥមំ បរិក្ខារចោឡ អធិដ្ឋាមិ"

នេះពាក្យ អធិដ្ឋានចំពោះសំពត់មួយៗ បើសំពត់ច្រើនត្រូវផ្ទាស់ថា

"**ឥមានិ បច្ចត្ថរណានិ អធិដ្ឋামি**" យើងទុកនូវសំពត់អម្បាលនេះ ជាសំពត់ក្រាលដេក, គឺផ្ទាស់ "**ឥមំ**" ជា "**ឥមានិ**" "**បច្ចត្ថរណំ**" ជា "**បច្ចត្ថរណានិ**" ។ សំពត់ជូតមុខ មាត់ក្តី សំពត់បរិក្ខារចោទ្ធ: (គឺសំពត់សម្រាប់ប្រើប្រាស់បន្ទិចបន្ទួច)ក្តី គប្បីផ្ទាស់ដូចគ្នា ។

ក្រៅហត្ថបាសថាដូចគ្នា ប្លែកតែផ្ទាស់ "**ឥមំ**" ជា "**ឯតំ** " "**ឥមានិ**" ជា "**ឯតានិ**" ។

បរិក្ខារបីយ៉ាងគឺ សំពត់ក្រាលដេក, សំពត់ជូតមុខ-មាត់, សំពត់បរិក្ខារ-ចោទ្ធ: នេះមិនមានកំណត់ អធិដ្ឋានច្រើនក៏បាន ក្រៅពីនេះ អធិដ្ឋានបានតែមួយៗប៉ុណ្ណោះ ។ ត្រៃចីវរ៣ នោះជ្រលក់ឲ្យបានពណ៌ជាមុនហើយ ទើបអធិដ្ឋានបាន ។ បរិក្ខារដែលបានអធិដ្ឋានមកហើយនោះប្រើប្រាស់ចាស់ទៅ នឹងផ្ទាស់បរិក្ខារថ្មី គប្បីដកអធិដ្ឋានបរិក្ខារចាស់នោះចេញជាមុន ហៅថា "**បច្ចុទ្ធរណ:**" ពាក្យដកថា "**ឥមំ សំឃាដឺ បច្ចុទ្ធរামি**" យើងដកលើកលែងសំពត់នេះ ថាជាសំពត់សង្ឃាដី ។

បរិក្ខារក្រៅពីនេះ ៩ គប្បីផ្ទាស់តាមវិធីដែលពោលមកហើយ ក្នុងអធិដ្ឋាន ។

វិធីអធិដ្ឋាន ចប់

វិធីដាច់អធិដ្ឋាន

បរិក្ខារដែលកិក្ខុ អធិដ្ឋានហើយ នឹងដាច់អធិដ្ឋានទៅវិញ ដោយ ហេតុ ៩ យ៉ាង ៖

ឲ្យទៅគេ១ ចោរដណ្តើមយកទៅ១ មិត្រកាន់យកដោយវិស្សាស១ ត្រូវអាបត្តិបារាជិក ឬចូលសាសន៍តិរ្ថីយ៍១ លាសិក្ខា១ ធ្វើកាលកិរិយា១ ភេទត្រឡប់១ ដកអធិដ្ឋាន១ ធ្លុះប្រហោង១ ។ ធ្លុះប្រហោងនេះ ពោលចំពោះតែបាត្រនិងត្រៃចីវរប៉ុណ្ណោះ ។

វិធីដាច់អធិដ្ឋាន ចប់

វិធីវិកប្ប

សំពត់ក្រៅចាករបស់អធិដ្ឋាន មានកំណត់ប្រវែង ៨ផ្នាប់ ទទឹង ៤ផ្នាប់ ឡើងទៅ ត្រូវវិកប្ប (គឺសម្រេចពិសេស គប្បីធ្វើរបស់មួយ ឲ្យមានម្ចាស់ពីរ ក្នុងចន្ទោះខ្ជួននិងកិក្ខុដទៃ) ទើបទុកប្រើប្រាស់បានរហូតទៅ បើពុំបានវិកប្បទេ ទុកឲ្យកន្ទង ១០ថ្ងៃទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

វិកប្បមាន ២គឺ ក្នុងហត្ថបាស ១ ក្រៅហត្ថបាស ១ ។

*ក្នុងហត្ថបាសនោះ គឺយកសំពត់ដែលនឹងត្រូវវិកប្បនោះមកដាក់ក្នុងហត្ថបាសចំពោះមុខ សហធម្មិក ដែលជាអ្នកទទួលវិកប្ប បើសំពត់ ១ថា "**ឥមំ ចីវរំ តុយ្ហំ វិកប្បេមិ**" យើងវិកប្បចីវរនេះដល់លោក ។*

*បើសំពត់ច្រើនថា "**ឥមានិ ចីវរានិ តុយ្ហំ វិកប្បេមិ**" ។ បើបាត្រ ១ថា "**ឥមំ បត្តំ តុយ្ហំ វិកប្បេមិ**" បាត្រច្រើនថា "**ឥមេ បត្តេ តុយ្ហំ វិកប្បេមិ**" ។*

*ក្រៅហត្ថបាសនោះ គឺសំពត់មិនបាននៅជិតខ្លួន បញ្ចេញតែវាចាចំពោះសហធម្មិក, វិធីវិកប្បដូចវិកប្បក្នុងហត្ថបាស, ប្លែកតែប្រើបទថា "**ឯតំ**" ជួស "**ឥមំ**" "**ឯតានិ**" ជួស "**ឥមានិ**" ប៉ុណ្ណោះ ។ ក្នុងវិកប្បទាំងពីរនោះ បើវិកប្បនឹងភិក្ខុចាស់ជាង ប្រើបទ "**អាយស្មតោ**" ជួស "**តុយ្ហំ**" ក៏គួរ ។ ចីវរដែលវិកប្បចំពោះអ្នកណា ត្រូវឲ្យអ្នកនោះដកជាមុន ទើបប្រើប្រាស់បាន ។ បើមិនទាន់ឲ្យដកហើយប្រើប្រាស់ ត្រូវបាចិត្តិយ រៀរតែស្និទ្ធស្នាលគ្នា អាចនឹងកាន់យកបានដោយវិស្សាស: ។*

ពាក្យដកវិកប្បក្នុងហត្ថបាស

*ចីវរមួយថា "**ឥមំ ចីវរំ មយ្ហំ សន្តកំ បរកុញ្ជ ក វិសជ្ជេហិ ក យថាបច្ចយំ ក ករោហិ** ។*

*បើអ្នកដកខ្ចីជាងថា "**ឥមំ ចីវរំ មយ្ហំ សន្តកំ បរិកុញ្ជថ ក វិសជ្ជេថ ក យថាបច្ចយំ ក ករោថ** ។ សេចក្តីដូចគ្នា គ្រាន់តែផ្ទាស់ពាក្យសម្រាប់ប្រើ សេចក្តីគោរព ប្រែថា លោកចូរប្រើប្រាស់ក្តី លះបង់ក្តី ធ្វើតាមបច្ច័យក្តី នូវចីវរជារបស់ខ្ញុំនេះ ។ បើច្រើនថា*

"ឥមានិ ចីវរានិ មយ្ហំ សន្តកានិ" ជួស "ឥមំ ចីវរំ មយ្ហំ សន្តកំ" ។

ក្រៅហត្ថបាសថា "ឯតំ" ជួស "ឥមំ" "ឯតានិ" ជួស "ឥមានិ" ។

បាត្រគប្បីដកតាមបាលីដែលដកចីវរនោះ ប្លែកតែបាត្រច្រើន ត្រូវប្រើថា "ឥមេ បត្តេ មយ្ហំ សន្តកេ" ជួស "ឥមានិ ចីវរានិ មយ្ហំ សន្តកានិ" ប៉ុណ្ណោះ ។ ក្រៅហត្ថបាសថា "ឯតេ" ជួស "ឥមេ" ។

វិធីវិកប្ប ចប់

វិធីសម្តែងអាបត្តិ

ទោសដែលកើតឡើង ព្រោះល្មើសពុទ្ធបញ្ញត្តិ ហៅថា អាបត្តិ ។ នោះចាត់ដោយពួកមាន ២ពួកគឺ៖ គរុកាបត្តិ ១ លហុកាបត្តិ ១ ។ វិធីចេញចាកគរុកាបត្តិនោះ ចូរមើលក្នុងបុព្វសិក្ខាវណ្ណនាចុះ ក្នុងទីនេះនឹងពោលតែវិធីចេញចាកលហុកាបត្តិ ។

ភិក្ខុត្រូវលហុកាបត្តិហើយ គប្បីគ្រងចីវរធ្វើងស្មាម្ខាងចូលទៅរកភិក្ខុមួយអង្គ អង្គុយលុតជង្គង់លើកដៃប្រណម្យ សម្តែងអាបត្តិតាមដែលមានឈ្មោះតទៅនេះ អាបត្តិតែមួយតួ ដូចជាអាបត្តិទុក្កដមួយ, ហើយអ្នកសម្តែងខ្ជីជាង គប្បីសម្តែងថា ៖

"**អហំ ភន្តេ ឯកំ ឧក្ក្លដំ អាបត្តឹ អាបន្នោ តំ បដិទេសេមិ**" ព្រះករុណា ខ្ញុំត្រូវអាបត្តិទុក្កដមួយហើយ ខ្ញុំសម្តែងចំពោះអាបត្តិនោះ ។ អ្នកទទួលសម្តែងគប្បីសួរថា "**បស្សសិ អាវុសោ**" លោកឃើញឬ? អ្នកសម្តែងឆ្វើយថា "**អាម ភន្តេ បស្សាមិ**" ព្រះករុណា ខ្ញុំឃើញ អ្នកទទួលថា "**អាយតឹ អាវុសោ សំវរេយ្យាសិ**" អាវុសោ លោកគប្បីសង្រួមតទៅ ។ អ្នកសម្តែងគប្បីថា " **សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ**[(๑)]" ។ សាធុព្រះករុណា ខ្ញុំនឹងសង្រួមដោយប្រពៃ ។

បើត្រូវអាបត្តិណា គប្បីយកអាបត្តិឈ្មោះនោះ ទៅបញ្ចូលត្រង់បទថា "**ឧក្ក្លដំ**" ។ បើអាបត្តិថុល្ចច្ច័យថា "**ថុល្ចច្ចយំ**" ។ បាចិត្តិយដែលឲ្យលះរបស់ថា "**និស្សក្តិយំ ចាចិត្តិយំ**" ។ សុទ្ធិកបាចិត្តិយ ថា "**ចាចិត្តិយំ**" ។ ទុញ្ភាសិតថា "**ឧញ្ភាសិតំ**" ។

បើអ្នកសម្តែងចាស់ជាងគប្បីថា "**អាវុសោ**" ជួស "**ភន្តេ**" អ្នកទទួលថា "**បស្សថ ភន្តេ**" ជួស "**បស្សសិ អាវុសោ**" "**អាយតឹ ភន្តេ សំវរេយ្យាថ**" ជួស "**អាយតឹ អាវុសោ សំវរេយ្យាសិ**" ។ សេចក្តីប្រែដូចគ្នា ផ្ទាស់តែវោហារដោយឋាន:មួយចាស់ មួយខ្ចី ។

---

(๑) ធ្លាប់ធ្វើមកត្រូវថា "សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ" ៣ដង។

អាបត្តិដែលត្រូវមានរឿងជាមួយគ្នា មានឈ្មោះជាមួយគ្នា ដូចជាភិក្ខុទុកអតិរេកចីវរច្រើនតួឲ្យហួស ១០ថ្ងៃ ត្រូវនិស្សគ្គិយបាចិត្តិយគ្រប់តួចីវរ ឬ ដូចភិក្ខុហុតសម្ង ព្ទសូរគ្រូកៗ ហុតព្ទប៉ុន្មានដងក៏ត្រូវអាបត្តិទុក្កដប៉ុណ្ណោះ ហៅថាអាបត្តិ មានវត្ថុជាមួយគ្នា មានឈ្មោះជាមួយគ្នា ។ អាបត្តិដទៃក៏គប្បីដឹងដូចន័យនេះ ប្រមូលសម្តែងជាមួយគ្នា តែម្តងបានត្រូវផ្ងាស់ប្រើបទថា "**សម្ពហុលា**" ប្រែថាច្រើនថាដូច្នេះ "**អហំ ភន្តេ សម្ពហុលា ឧក្ក្ពជាយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ**" ។ បើត្រូវអាបត្តិណា គប្បីយកឈ្មោះអាបត្តិនោះមកបញ្ចូលត្រង់បទថា "**ឧក្ក្ពជាយោ**" ដូចវិធីមុន ។ អាបត្តិថុល្ចច្ច័យថា "**ថុល្ចច្ចយាយោ**" ។ បាចិត្តិយសុទ្ធថា "**ចាចិត្តិយាយោ**" បើទុព្ភាសិតថា "**ឧព្ភាសិតាយោ**" ។

នេះគប្បីចូលចិត្តថា ត្រូវតាំងពី៣ តួឡើងទៅ ។ បើត្រូវតែពីរតួត្រូវថា "**ទ្វេ**" ជួស "**សម្ពហុលា**" ។ អាបត្តិដែលត្រូវមានឈ្មោះជាមួយគ្នា តែផ្សេងរឿងគ្នា ដូចភិក្ខុត្រូវអាបត្តិទុក្កដ ព្រោះមិនសង្រួមចក្ខុក៏មាន, ព្រោះស្ងៀកដណ្តាប់មិនបរិមណ្ឌលក៏មាន, ព្រោះសើយចីវរចូលស្រុកក៏មាន, ដូច្នេះជាដើម យ៉ាងនេះឈ្មោះថា មានវត្ថុផ្សេងគ្នា ប្រមូលសម្តែងជាមួយគ្នាតែម្តងក៏បាន, ត្រូវប្រើបទថា " **សម្ពុហុលា**

ជាជាវត្ថុកាយោ" ប្រែថា មានវត្ថុផ្សេងគ្នា ។ ច្រើនថាដូច្នេះ "**អហំ ភន្តេ សម្ពហុលា ជាជាវត្ថុកាយោ ឧក្ក្ជាយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ**" ។ ឬមួយភិក្ខុត្រូវអាបត្តិតាំងពីបីតួឡើងទៅ តែរឿងផ្សេងគ្នាពីរយ៉ាងប៉ុណ្ណោះ ក៏គប្បីសម្តែងយ៉ាងនេះ ។ បើត្រូវអាបត្តិដទៃមានវត្ថុផ្សេងគ្នា ក៏គប្បីសម្តែងតាមវិធីនេះ ។

បើត្រូវអាបត្តិជាមួយគ្នាពីរតួ វត្ថុដែលកន្ងងក៏ផ្សេងគ្នាទាំងពីរយ៉ាងត្រូវថា "**ទ្វេ ជាជាវត្ថុកាយោ**" ។

អាបត្តិទុព្ភាសិត ត្រូវព្រោះចំអកអនុបសម្បន្នលេង, ម្យ៉ាងទៀតសូម្បីរឿងដែលយកមកចំអកផ្សេងគ្នា លោកពោលថា មានកំណត់ជាមួយគ្នា ត្រូវសម្តែងយ៉ាងបែបអាបត្តិច្រើន មានរឿងជាមួយគ្នា ។

ភិក្ខុពី ២ អង្គឡើងទៅ ត្រូវអាបត្តិមានរឿងជាមួយគ្នា ដូចភិក្ខុត្រូវអាបត្តិ ព្រោះអង្គុយក្នុងទីកំបាំងភ្នែកនឹងមាតុគ្រាមតែមួយនឹងមួយដូចគ្នា ហៅថា "**សភាតាបត្តិ**" ប្រែថា អាបត្តិមានភាគស្មើគ្នា, អាបត្តិដូច្នេះហាមមិនឲ្យសម្តែង មិនឲ្យទទួលគ្នា ឲ្យសម្តែងនឹងភិក្ខុដទៃ ដែលគ្មាន "**សភាតាបត្តិ**" បើប្រព្រឹត្តត្រូវអាបត្តិទុក្កដ ទាំងអ្នកទទួលទាំងអ្នកសម្តែង ។ ហេតុនេះកាលសម្តែងអាបត្តិនឹងភិក្ខុណា ត្រូវប្រាប់វត្ថុរឿងដែលខ្ជួនត្រូវអាបត្តិ ដល់ភិក្ខុនោះជាមុន, កាលមិនដូចគ្នា ទើបសម្តែង

*បាន អាបត្តិនោះ លោកឲ្យសម្តែងដោយគួរដល់ឈ្មោះ ដល់វត្ថុ ដល់ចំនួន សម្តែងខុសឈ្មោះមិនបាន ខុសវត្ថុ ខុសចំនួន គឺខាងច្រើន ត្រឡប់ជាតិចក៏មិនបាន បើខាងតិចត្រឡប់ភ្ជាត់មាត់ថា ច្រើននេះបាន ដូចអាបត្តិ ១តួ ឬ ២តួ ភ្ជាត់មាត់ថា "**សម្ពហុលា**" វត្ថុ ១ សម្តែងថា "**ឆាឆាវត្ថុកាយោ**" ដូច្នេះបាន ។ អាបត្តិផ្សេងឈ្មោះគ្នា ហាមមិន ឲ្យសម្តែងរួមគ្នា ។*

ដល់ថ្ងៃឧបោសថ នឹងចូលកាន់ទីប្រជុំសង្ឃ ស្តាប់ព្រះបាដិមោក្ខ គប្បីសម្តែងអាបត្តិធ្វើខ្ជូនឲ្យបរិសុទ្ធជាមុន វេលាសម្តែងព្រះបាដិមោក្ខ គប្បីធ្វើសេចក្តីគោរព តាំងចិត្តស្តាប់ កុំនិយាយគ្នាជាដើម ដោយពុំមាន អន្តរាយ ។

វិធីសម្តែងអាបត្តិ ចប់

ពិន្ទ្ធាធិដ្ឋានាទិបព្វៈ ចប់

ទី ៧-ឧបោសថាទិបព្វៈ

ពោលដោយកម្ម មានឧបោសថកម្មជាដើម

វិធីធ្វើឧបោសថកម្ម

ទំនៀមរបស់សង្ឃ កន្ទះខែត្រូវប្រជុំគ្នាម្តង ក្នុងថ្ងៃពេញបូណ៌មី ១ ក្នុងថ្ងៃដាច់ខែ ១ ដោយប្រក្រតី ដើម្បីសូត្រព្រះបាដិមោក្ខ ហៅថា

"ធ្វើឧបោសថ" ភិក្ខុតាំងអំពី ៦ រូបឡើងទៅ ប្រជុំគ្នាធ្វើឧបោសថ ជាការសង្ឃបាន ហៅថា "**សជ្ឈឧចោសថ**" ។

ហេតុដូច្នេះ បានជាដល់ថ្ងៃឧបោសថហើយ ភិក្ខុទាំងឡាយត្រូវ ទៅប្រជុំគ្នា នៅរោងឧបោសថ (តាមពេលកំណត់) ហើយធ្វើកិច្ច ៦ យ៉ាងនេះជាមុនគឺ ៖

តដ្ឋានសមជ្ជនំ បោសច្រាសក្នុងទីនោះ ១, **តត្ត បជីបុជ្ជលនំ** បើយប់ឲ្យអុជប្រទីបក្នុងទីនោះ ១, **អាសនបញ្ញាបនំ** តាំងអាសន: ទុក ១, **ចានីយបរិភោជនីយូបជ្ជបនំ** តាំងទឹកធាន់ទឹកប្រើ ១ ។

កិច្ច ៦យ៉ាងនេះ ហៅថា **បុព្វការណ:** ប្រែថាកិច្ចគប្បីធ្វើមុន ។

នៅមានកិច្ចដែលនឹងត្រូវធ្វើមុនសូត្របាដិមោក្ខ ៥យ៉ាងទៀតគឺ៖

ឆន្ទាហរណំ នាំឆន្ទ: គឺសេចក្តីព្រមឲ្យធ្វើសង្ឃកម្មនៃភិក្ខុឈឺ មក១ **ចារិសុទ្ធិអាហរណំ** នាំបរិសុទ្ធិគឺសេចក្តីបរិសុទ្ធ នៃភិក្ខុឈឺ នោះមក ១, **ឧតុក្ខានំ** ប្រាប់រដូវ ១, **ភិក្ខុតណនា** រាប់ភិក្ខុ ឲ្យដឹងចំនួន ១, **ភិក្ខុនីនមោវាទោ** ប្រដៅនាងភិក្ខុនី ១ ។

កិច្ច៥យ៉ាងនេះ ហៅថា **បុព្វកិច្ច** ប្រែថា ធុរ:គប្បីធ្វើមុនសូត្រ បាដិមោក្ខ ។

ក្នុងកិច្ច ៥យ៉ាងនេះ កិច្ច ២យ៉ាងខាងដើម ប្រើចំពោះកិក្ខុ ដែលនៅក្នុងសីមាជាមួយគ្នា កិច្ចមួយខាងចុងនោះ ឥឡូវនេះ ពុំបានប្រើព្រោះពុំមាននាងភិក្ខុនី ។

កាលនឹងចូលស្តាប់ព្រះបាដិមោក្ខ ត្រូវជម្រះខ្លួនឲ្យបរិសុទ្ធចាកអាបត្តិ ដែលជាទេសនាគាមិនីជាមុន ដឹងថាខ្លួនមានអាបត្តិ ចូលស្តាប់បាដិមោក្ខត្រូវទុក្កដ ។ កាលកំពុងស្តាប់ បើនឹកឃើញឡើងត្រូវប្រាប់ភិក្ខុដែលអង្គុយជិតថា ខ្ញុំត្រូវអាបត្តិឈ្មោះនេះ ក្រោកពីនេះហើយនឹងសម្តែង ។

ឧបោសថពោលដោយថ្ងៃមាន ៣គឺ

ចាតុទ្ទសីឧបោសថ ថ្ងៃ ១៤, បណ្ណរសីឧបោសថ ថ្ងៃ ១៥, សាមគ្គី-ឧបោសថ ថ្ងៃភិក្ខុព្រមព្រៀងគ្នា ។

ដោយអាការៈមាន ៣គឺ

សូត្របាដិមោក្ខ ១, ប្រាប់បរិសុទ្ធិ ១, អធិដ្ឋាន ១ ។

ដោយការកៈអ្នកធ្វើមាន ៣គឺ

សង្ឆ ១, គណៈ ១, បុគ្គល ១ ។

ភិក្ខុប្រជុំគ្នាពី ៤អង្គឡើងទៅ ហៅថាសង្ឆ ត្រូវសូត្របាដិមោក្ខ ។ បើមានតែ ២-៣អង្គ ហៅថា គណ: ត្រូវប្រាប់សេចក្តីបរិសុទ្ធរបស់ខ្លួន ដល់គ្នានឹងគ្នា ។ បើមួយអង្គហៅថា បុគ្គល ត្រូវតាំងចិត្តអធិដ្ឋាន ។

សង្ឆឧបោសថនោះ ប្រកបដោយអង្គ ៤ ទើបសូត្របាដិមោក្ខបាន អង្គ ៤នោះគឺ ៖

ថ្ងៃនោះជាថ្ងៃ ១៤-១៥ ថ្ងៃសាមគ្គី ឯណានីមួយ ១ ភិក្ខុប្រជុំគ្នាយ៉ាងតិចពី ៤អង្គឡើងទៅ ១ ភិក្ខុអម្បាលនោះ មិនមានសភាគាបត្តិ (គឺអាបត្តិមានចំណែកស្មើគ្នា) ១ វជ្ជនីយបុគ្គល បុគ្គលដែលគួរវៀរ ២១ មិនមានក្នុងហត្ថបាស ១ ។

កាលកំពុងសូត្របាដិមោក្ខ បើមានភិក្ខុអាគន្តុក:មកដល់ បើអាគ-ន្តុក:ច្រើនជាង ត្រូវសូត្របាដិមោក្ខសាដើមជាថ្មី បើស្មើគ្នាឬតិចជាង មិនបាច់សាដើមជាថ្មី ឲ្យពួកអាគន្តុក:នោះ ស្តាប់បាដិមោក្ខ ដែលសូត្រសល់នៅតទៅ, បើមកក្នុងវេលាសូត្រចប់ហើយ សូម្បីច្រើនជាងក៏ មិនត្រូវត្រឡប់សូត្រឡើងជាថ្មី ។ ភិក្ខុអាគន្តុក:នោះ គប្បីប្រាប់បរិសុទ្ធិ នឹងសង្ឆដែលធ្វើឧបោសថរួចហើយនោះ ។ បើដឹងជាមុនថា នឹងមានភិក្ខុមកទៀត ហើយក្ងែងធ្វើ ត្រូវអាបត្តិថុល្ងច្ច័យ បើធ្វើដោយមាក់ងាយ គឺគិតថា មកដល់កាលណា ក៏ស្តាប់កាលនោះទៅចុះ ដូច្នេះត្រូវទុក្កដ ។

ក្នុងអាវាសមានភិក្ខុ ២-៣ អង្គ គប្បីធ្វើបារិសុទ្ធិឧបោសថ។ នោះ ភិក្ខុប្រជុំគ្នាក្នុងរោងឧបោសថ ហើយភិក្ខុមួយអង្គ គប្បីសូត្រប្រកាស ដោយ ញត្តិថា **សុណាតុ មេ ភន្តេ អាយស្មន្តា អជ្ជុចោសថោ បណ្ណរសោ យទាយស្មន្តានំ បត្តកល្ល មយំ អញ្ញមញ្ញ ចារិសុទ្ធិ ឧចោសថំ ករេយ្យាម ។**

បពិត្រព្រះករុណាទាំងឡាយ ឧបោសថថ្ងៃនេះ ជាថ្ងៃ ១៥ បើសេចក្តីព្រមព្រៀងនៃព្រះករុណាទាំងឡាយ ដ៏សមគួរហើយ យើងខ្ញុំ ទាំងឡាយ គប្បីធ្វើបារិសុទ្ធិឧបោសថជាមួយគ្នា ។ បើអ្នកសូត្រចាស់ ជាងថា "**អាវុសោ**" ជួស "**ភន្តេ**" បើថ្ងៃ១៤ថា "**ចាតុទ្ទសោ**" ជួស "**បណ្ណរសោ**" ។

តពីនេះទៅ ភិក្ខុចាស់គប្បីអង្គុយលុតជង្គង់លើកដៃប្រណម្យ ប្រាប់សេចក្តីបរិសុទ្ធរបស់ខ្លួនថា "**បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេថ**" ៣ដង ។

ខ្ញុំបរិសុទ្ធហើយលោក ពួកលោកចូរចាំទុកថា "ខ្ញុំជាអ្នកបរិសុទ្ធ" ភិក្ខុក្រៅនេះ គប្បីថាដូចគ្នារៀងតាមលំដាប់វស្សា គ្រាន់តែផ្ទាស់ថា "**ភន្តេ**" ជួស "**អាវុសោ**" ។

បើមានតែពីរអង្គ មិនបាច់ញត្តិ គ្រាន់តែប្រាប់បរិសុទ្ធិដល់គ្នា អ្នកចាស់ជាងថា "**បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេហិ**"

*៣ដង ។ ខ្ទីជាង់ថា "**បរិសុទ្ធោ អហំ ភន្តេ បរិសុទ្ធោតិ មំ ជានេថ**" ៣ដង ។*

*បើនៅតែមួយអង្គ ដល់ថ្ងៃឧបោសថ ត្រូវបង្អង់ចាំមើលភិក្ខុ អាគន្ត្ពុក: ដរាបដល់ល្ងាច បើឃើញថាមិនមានមកគប្បីអធិដ្ឋានថា "**អជ្ជ មេ ឧចោសថោ**" ថ្ងៃនេះជាថ្ងៃឧបោសថរបស់យើង ។*

ធ្វើឧបោសថកម្មត្រូវប្រកបដោយអង្គ ៣

១- **កាយសាមក្ក**ី	*អង្គុយជាប់ហត្ថបាស*
២- **ចិត្តសាមក្ក**ី	*ពុំមានឈ្លោះប្រកែកគ្នា*
៣- **ទិដ្ឋិសាមក្ក**ី	*មានការឃើញស្របគ្នា ។*

វិធីធ្វើឧបោសថកម្ម ចប់

វិធីចូលវស្សា[(១)]

ទំនៀមរបស់ភិក្ខុ កាលដល់រដូវភ្ជៀង ត្រូវឈប់នៅតែ១កន្ថែង មិនទៅកាន់ទីដទៃឲ្យកន្ធង់រាត្រី អស់ ៣ខែ ដើមរដូវ ហៅថាចាំវស្សា ។ ចូលវស្សានោះមាន ២គឺ ៖

(១) វិនយបិដក មហាវគ្គ វស្សូបនាយិកក្ខន្ធក: ។

១- **បុរិមិកាវស្សូបនាយិកា** *ចូលវស្សា ឬ(អធិដ្ឋានវស្សា) ដំបូងគឺថ្ងៃ ១រោច ខែអាសាធ ។*

២- **បច្ឆិមិកាវស្សូបនាយិកា** *ចូលវស្សាក្រោយ គឺ ១រោច ខែស្រាពណ៌ ។*

កិច្ចដែលគប្បីធ្វើមុនចូលវស្សានោះ គឺជួសជុលបោសច្រាសសេនាសនៈដែលខ្លួននៅឲ្យស្អាត ហើយចាត់ចែងបរិក្ខារនៃសេនាសនៈឲ្យមានរបៀបរៀបរយល្អ រហូតដល់តម្កល់ទឹកប្រើប្រាស់ឲ្យស្រេចជាមុន, ដល់ថ្ងៃចូលវស្សា គប្បីចូលកាន់ទីប្រជុំ អធិដ្ឋានវស្សាព្រមជាមួយសង្ឆក្នុងវិហារ ពាក្យអធិដ្ឋានព្រមគ្នាថា ៖

ឥមស្មឺ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិ *។ ៣ដង ។*

យើងចូលកាន់រដូវភ្ជៀង ក្នុងអាវាសនេះអស់ ៣ខែ ។ លោអធិដ្ឋាន ត្រូវតាំងចិត្តថា នឹងនៅក្នុងវស្សានេះអស់ ៣ខែ ។ បើកិក្ខុធ្វើកុដិចាំវស្សានៅក្នុងព្រៃចំពោះម្នាក់ៗ គប្បីកំណត់ខេត្តចំពោះកុដិនិងបរិវេណ ពាក្យអធិដ្ឋានថា ៖

ឥមស្មឺ វិហារេ ឥមំ តេមាសំ វស្សំ ឧបេមិ *។ ៣ដង ។*

កិក្ខុចូលវស្សាហើយ ត្រូវនៅក្នុងទីដែលខ្លួនចូល កំណត់អស់ ៣ខែ កុំនៅក្នុងទីក្រៅខែត្រឲ្យកន្ទងរាត្រី កាលមានកិច្ចដែលគួរនឹងទៅ, ទ្រង់

អនុញ្ញាតឲ្យទៅបាន តែត្រូវត្រឡប់ក្នុងរវាង ៧ថ្ងៃ ដោយចងចិត្តថា នឹងត្រឡប់មកក្នុងរវាងនេះ ហៅថា "**សត្តាហការណីយកិច្ច**" ។

ទៅដោយមិនគិតត្រឡប់ ឬគិតនឹងត្រឡប់ តែហួសពី ៧ថ្ងៃទៅ វស្សាដាច់ ។ ភិក្ខុមិនចាំវស្សា ឬវស្សាដាច់ ដោយមិនមានអន្តរាយ ត្រូវអាបត្តិទុក្កដ ។ ទាំងមិនត្រូវបានសង្ឃលាភ ដែលកើតឡើងដល់ សង្ឃ ។

សូមខមាទោស

ទំនៀមក្នុងព្រះពុទ្ធសាសនា អ្នកឯណាប្រព្រឹត្តល្មើសអ្នកដទៃ កាលដឹងខ្ជួនហើយ ត្រូវសូមអនុញ្ញាតទោស ហៅថា សូម "**ខមា**" ប្រែថា ឲ្យអត់ទោស ។ អ្នកដែលគេសូម "**ខមា**" នោះ គប្បីអត់ទោស ឲ្យ ហៅថា ទទួល "**ខមា**" ។ ការ "**ខមាឧោស**" នេះ ច្រើនធ្វើ ក្នុងវេលាចាំវស្សា បើនៅក្នុងអារាសជាមួយគ្នា គប្បីធ្វើក្នុងថ្ងៃ ចូលវស្សា គឺក្នុងវេលាសូត្របាលីអធិដ្ឋានវស្សាចប់ហើយ ។ កាលនឹងសូម "**ខមា**" គប្បីឃ្ជុំចីវរ ឆៀងស្មាថ្វាយបង្គំ លុតជង្គង់ ឬអង្គុយ ច្រហោង លើកដៃប្រណម្យបញ្ចេញវាចាថា ៖

អាយស្មន្តេ បមាឧេន ឧារត្តយេន កតំ សព្ចំ អបរាជំ ខមថ មេ ភន្តេ ។ ព្រះការុណា សូមព្រះការុណា អត់ទោសទាំងពួង

ដល់ខ្ញុំ ដែលបានធ្វើហើយដោយទ្វារទាំងបី ព្រោះសេចក្តីភ្ងាំងភ្ងាត់ក្នុង ព្រះករុណា ។ លោកអ្នកទទួលគប្បីពោលថា " **អហំ ខមាមិ តយាបិ មេ ខមិតព្វំ**" ។ ខ្ញុំអត់ឲ្យលោក លោកគប្បីអត់ដល់ខ្ញុំផង ។ អ្នកសូម "**ខមា**" តបថា "**ខមាមិ ភន្តេ**" ព្រះករុណា ខ្ញុំអត់ឲ្យ ។

សូមខមាព្រមគ្នាច្រើនអង្គក៏បាន ច្រើនថា "**ឆោ** ជួស **មេ**" ។ អ្នកទទួលថា "**តុម្ហេហិបិ**" ជួស "**តយាបិ**" ។ អ្នកសូមគ្នាច្រើនថា "**ខមាម ភន្តេ**" ។

វិធីចូលវស្សា ចប់

វិធីបវារណា(១)

ទំនៀមរបស់ភិក្ខុអ្នកនៅចាំវស្សាអស់ត្រៃមាសហើយ កាលដល់ថ្ងៃពេញបូណ៌មីខែអស្សុជ មានពុទ្ធានុញ្ញាតឲ្យពោលពាក្យ សុំឲ្យជួយដាស់តឿនគ្នា ហៅថា "**បវារណា**" ប្រែថា ព្រមសុខចិត្ត ឲ្យរើសថាភិក្ខុតាំងពី ៥អង្គឡើងទៅទើបបវារណាជាសង្ឆបាន ។ បើមាន តែ ២-៣-៤ អង្គ គប្បីធ្វើបវារណាជាគណ: ។ បើមួយអង្គ គប្បី បវារណាជាបុគ្គល ។

កិច្ចដែលគប្បីធ្វើមុនបវារណានោះ ដូចកិច្ចនៃឧបោសថកម្ម ប្លែកតែក្នុងបុព្វកិច្ច ត្រូវនាំ **បវារណា** ជួសនាំ **ចារិសុទ្ធិ** ។ នឹងធ្វើបវារណា

(១) វិនយបិដក មហាវគ្គ បវារណាក្ខន្ធក: ។

ជាសង្ឆ គប្បីប្រជុំគ្នាក្នុងរោងឧបោសថ ភិក្ខុមួយអង្គ សូត្របុព្វកិច្ច បុព្វការណហើយគប្បីតាំងញត្តិ ប្រកាសដល់សង្ឆមុន ទើបបវារណា ខាងក្រោយ បើភិក្ខុមានវស្សាស្មើគ្នា ឲ្យបវារណាព្រមៗគ្នា ក៏បាន ។ បើបវារណា ៣ដង ត្រូវតាំងញត្តិថា ៖

សុណាតុ មេ ភន្តេ សំឃោ អជ្ជ បវារណា បណ្ណរសី យទិ សំឃស្ស បត្តកល្ឃំ សំឃោ តេវាចិកំ បវារយ្យ ។

*បពិត្រព្រះសង្ឆ សូមព្រះសង្ឆចូរស្តាប់ខ្ញុំ បវារណាថ្ងៃនេះជាថ្ងៃ ១៥ បើសេចក្តីព្រមព្រៀងនៃសង្ឆដ៏សមគួរហើយ ព្រះសង្ឆគប្បីបវារណា ៣ដង, នេះហៅថា "**តេវាចិកញត្តិ**" ។*

*បើបវារណា ២ដង គប្បីតាំងញត្តិដូចគ្នា ផ្ទាស់តែពាក្យខាងចុងថា "**សំឃោ ទ្វេវាចិកំ បវារយ្យ**" ។ សង្ឆគប្បីធ្វើបវារណា ២ ដង នេះហៅថា "**ទ្វេវាចិកញត្តិ**" ។*

*បើបវារណាតែមួយដង គប្បីតាំងញត្តិផ្ទាស់ពាក្យខាងចុងថា "**សំឃោ ឯកវាចិកំ បវារយ្យ**" ។ សង្ឆគប្បីបវារណា មួយដង នេះហៅថា "**ឯកវាចិកញត្តិ**" ។*

*បើចាត់ភិក្ខុវស្សាស្មើគ្នា ឲ្យបវារណាព្រមគ្នា គប្បីតាំងញត្តិផ្ទាស់ពាក្យខាងចុងថា "**សំឃោ សមានវស្សិកំ បវារយ្យ**" ។ សង្ឆគប្បី*

